BBC MEDIA ACTION
TRANSFORMING LIVES THROUGH MEDIA AROUND THE WORLD

WINROCK INTERNATIONAL

# ឯកសារអប់រំ វីនរ៉ក់
## កូនសៀវភៅមគ្គុទេសក៍សម្រាប់អ្នកប្រតិបត្តិ



# មាតិកា


សេចក្ដីផ្ដើម ............ ៣
ការណែនាំអំពីឯកសារអប់រំ ............ ៤
សេចក្ដីសង្ខេបអំពីខ្លឹមសារ នៃឯកសារអប់រំ ............ ៥
បញ្ជីផ្ទៀងផ្ទាត់មេរៀនសម្រាប់វគ្គបណ្ដុះបណ្ដាល ............ ៨
**ជំពូក១៖ សេចក្ដីផ្ដើមអំពីសិក្ខាសាលា** ............ ៩
១.១. កិច្ចស្វាគមន៍ និង ការបើកកម្មវិធីសិក្ខាសាលា ............ ១០
សកម្មភាពីទី១: ការណែនាំខ្លួន ដើម្បីឲ្យសិក្ខាកាមបានស្គាល់គ្នា ............ ១១
ជំពូក២៖ ការងារ ............ ១២
សកម្មភាពីទី២: ល្បែងកំសាន្ត ខុស ឬ ត្រូវ ............ ១៤
សកម្មភាពទី៣: ករណីសិក្សា: ប្រភេទ នៃការងារ ............ ១៦
សកម្មភាពទី៤: ករណីសិក្សា: ភ្ញាក់ឡើង ............ ១៨
ជំពូក៣៖ ការទទួលបានការងារធ្វើ ............ ២១
៣.១. កន្លែងទទួលព័ត៌មានអំពីការងារ ............ ២៣
សកម្មភាពទី៥: ករណីសិក្សា: ស្វែងរកការងារមួយ ............ ២៤
សកម្មភាពទី៦: សេចក្ដីប្រកាសផ្សាយអំពីការងារ ............ ២៦
៣.២. ត្រូវមានសុវត្ថិភាពនៅពេលស្វែងរកការងារធ្វើ ............ ២៨
សកម្មភាពទី៧: ករណីសិក្សា: ចំណាកស្រុក ............ ២៨
សកម្មភាពទី៨: ការស្វែងរកការងារដែលមានសុវត្ថិភាព ............ ៣០
**ជំពូក៤៖ ជំនាញ** ............ ៣៥
សកម្មភាពទី៩: ករណីសិក្សា: ជំនាញទន់: ............ ៣៧
៤.១. ការអប់រំបណ្ដុះបណ្ដាលជំនាញបច្ចេកទេស និង វិជ្ជាជីវៈ (TVET Skills) ............ ៣៨
សកម្មភាពទី១០: ករណីសិក្សា: ការងារកាត់ដេរ ............ ៣៨
សកម្មភាពទី១១: សាលាអប់រំបណ្ដុះបណ្ដាលជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈ ឬ សាកលវិទ្យាល័យ តើអ្នកគួរជ្រើសរើសយកសាលាមួយណា? តើសាលាមួយណាដែលអ្នកគួរជ្រើសរើស? ............ ៣៩
សកម្មភាពទី១២: ការងារជំនាញ ............ ៤០
៤.២. ជំនាញទន់ ............ ៤៣
សកម្មភាពទី១៣: កែប្រែជំនាញឲ្យទៅជាការធ្វើការងារ ............ ៤៣
សកម្មភាពទី១៤: ការយកជំនាញទៅអនុវត្តជាក់ស្ដែង ............ ៤៧
សកម្មភាពទី១៥: សម្ភាសន៍ការងារ ដែលបានដាក់ពាក្យនោះ ............ ៥២
**ជំពូក៥៖ ការគ្រប់គ្រងប្រាក់របស់អ្នក** ............ ៥៥
៥.១. ការបែងចែកថវិកា ............ ៥៧
សកម្មភាពទី១៦: ករណីសិក្សា: ការធ្វើផែនកាថវិកា ............ ៥៧
៥.២. ការសន្សំលុយ ............ ៦០
សកម្មភាពទី១៧: ករណីសិក្សា: ចំណុចគន្លឹះសម្រាប់ជាជំនួយស្មារតីក្នុងការសន្សំប្រាក់ ............ ៦០
៥.៣. ប្រាក់បំណុល និង ប្រាក់កម្ចី ............ ៦២
សកម្មភាពទី១៨: ប្រាក់បំណុល និង ប្រាក់កម្ចី ............ ៦២
៥.៤. ការបែងចែកថវិកា: ............ ៦៥
សកម្មភាពទី១៩: ការចំណាយតាមតម្រូវការ និង ការចំណាយតាមការចង់បាន ............ ៦៥
ជំពូក៦៖ ជំណាក់កាលបន្ទាប់ក្នុងការសម្រេចគោលដៅរបស់អ្នក ............ ៦៨
សកម្មភាពទី២០: ផែនការសកម្មភាពរបស់ខ្ញុំ ............ ៦៩

# សេចក្តីផ្តើម

## អង្គការ BBC Media Action

អង្គការ BBC Media Action គឺជាអង្គការសប្បុរសធម៌អន្តរជាតិ ដើម្បីអភិវឌ្ឍន៍ ហើយ អង្គការនេះ បានធ្វើការនៅប្រទេសកម្ពុជា តាំងពីឆ្នាំ២០០៣ មកម្ល៉េះ ។ យើងប្រើអំណាច នៃព័ត៌មាន និង ការទំនាក់ទំនង ក្នុងការលើកកម្ពស់ និង ជួយកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការគាំទ្រដល់ពលរដ្ឋ ដើម្បីឲ្យពួកគេ បានយល់ពីសិទ្ធិរបស់ពួកគេ ។ គោលបំណងចំបងរបស់យើង គឺផ្តល់ព័ត៌មាន ភ្ជាប់ទំនាក់ទំនង និង ពង្រឹងការយល់ដឹងអំពីសិទ្ធិដល់មនុស្សនៅទូទាំងពិភពលោក ។ យើងធ្វើការជាមួយស្ថានីយវិទ្យុ ទូរទស្សន៍ផ្សេងៗ ស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និង ម្ចាស់ជំនួយនានា ក្នុងការផ្តល់ព័ត៌មានដើម្បីជម្រុញឲ្យមានការផ្លាស់ប្តូរជាវិជ្ជមានតាមរយៈ កម្មវិធីផ្សេងៗ ដូចជា កម្មវិធី រស់ជាតិជីវិត ឡូយ9 ស្នេហ៍9 និង ក្លាហាន9 (Taste of Life, Loy9, Love9, and Klahan9) ។

## អង្គការ WINROCK

អង្គការ Winrock International និង ដៃគូរបស់ខ្លួន នឹងលើកស្ទួយផ្នែកសិទ្ធិមនុស្ស ក្នុងការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (CTIP) នៅប្រទេសកម្ពុជា តាមរយៈកម្មវិធីរយៈពេលបួនឆ្នាំ ហើយមានលក្ខណៈសន្តនិយម និង ពហុវិស័យ ក្នុងការពង្រឹងសមត្ថភាពសហគមន៍ និង មន្ត្រីរាជការដែលមានតួនាទីក្នុងការសម្របសម្រួលជាមួយនឹងផ្នែកឯកជន និង ដៃគូអភិវឌ្ឍន៍ ។

## កម្មវិធីក្លាហាន9

**កម្មវិធីក្លាហាន9** គឺជាកម្មវិធីកំសាន្តសប្បាយតាមបែបការផ្តល់ព័ត៌មានអប់រំ និង ពាក់ព័ន្ធជាមួយនឹងគំនិតផ្តួចផ្តើមឲ្យមានការចាក់ផ្សាយតាមទូរទស្សន៍ៗ និង បណ្តាញផ្សព្វផ្សាយសង្គម ។ កម្មវិធីនេះមានគោលបំណង ជួយគាំទ្រដល់យុវជនខ្មែរ ក្នុងការធ្វើឲ្យជីវិតរបស់ពួកគេកាន់តែប្រសើរឡើង តាមរយៈ ការផ្តល់នូវព័ត៌មាន អំពីឱកាសការងារ និង ស្ថិរភាពសេដ្ឋកិច្ច ។ យុវជនខ្មែរជាច្រើនប្រឈមនឹងការអត់ការងារធ្វើ និង ការប្រជែងគ្នារកការងារធ្វើក្នុងកំរិតខ្ពស់ ខ្វះនូវមគ្គុទេសក៍ណែនាំពីមុខរបរ និង ការមិនទទួលបានការអប់រំបណ្តុះបណ្តាលលើជំនាញពាក់ព័ន្ធ ។ ការផ្តល់ព័ត៌មានការគាំទ្រ និង ការដាក់ផ្លាកសញ្ញា ដើម្បីបង្កើនការងារ និង ភាពជាសហគ្រិនភាព គឺជាចំណុចគន្លឹះ ។

កម្មវិធីក្លាហាន9 មានគោលបំណងជម្រុញ និង លើកទឹកចិត្ត ដល់យុវជននៅពេសពេញ ប្រទេសកម្ពុជា ដែលមានវ័យចន្លោះពី ១៥ ទៅ ៣០ ឆ្នាំ ឲ្យបានយល់អំពីខ្លឹមសារ នៃសំណុំឯកសារមេរៀននេះ ។ ខ្លឹមសារនៃសំណុំឯកសារមេរៀននេះរួមមាន រឿងបំផុសគំនិត វីដេអូអប់រំខ្លីៗ ល្បែងកំសាន្ត រឿងភាគ និង កម្មវិធីសំដែងតាមទូរទស្សន៍ ។

កម្មវិធីក្លាហាន9 ផលិតឡើងដោយអង្គការ **BBC Media Action** ជាមួយនឹងក្រុមយុវជន ដែលទទួលបានការបណ្តុះបណ្តាលលើការងារជាងបីឆ្នាំហើយ ។ ក្រុមយុវជន នៃកម្មវិធីក្លាហាន9 មានវ័យជាមធ្យមត្រឹមតែម្ភៃប្រាំប៉ុណ្ណោះ ។

# សេចក្តីណែនាំអំពីឯកសារអប់រំនេះ

តម្រូវការការងារសម្រាប់យុវជននៅក្នុងប្រទេសកម្ពុជា មានការកើនឡើងគួរឲ្យកត់សម្គាល់ (គឺមានការកើនឡើងជាង ៩០%) បើទោះជាកម្រិត នៃតម្រូវការការងារកើនឡើងខ្ពស់យ៉ាងនេះក្តី ក៏នៅមានយុវជនជាច្រើន ត្រូវធ្លាក់ចូលក្នុងស្ថានភាព នៃការងារ ដែលមិនមានសុវត្ថិភាព ។ ការចូលយ៉ាងសកម្មរបស់យុវជននៅក្នុងទីផ្សារការងារ ទាមទារឲ្យយុវជនទាំងនោះ មានចំណេះដឹង និង ជំនាញក្នុងការស្វែងរកការងារ ដែលពាក់ព័ន្ធ ប្រកបដោយសុវត្ថិភាព ។ ដើម្បីដាក់ពាក្យរកការងារធ្វើ ឬ សុំធ្វើកម្មសិក្សា ដើម្បីឲ្យខ្លួនអាចទទួលបានមុខតំណែងបែបនោះ សំខាន់ យុវជនទាំងនៅទីក្រុង និង នៅជនបទ ជាពិសេស យុវតីដែលពុំមានការងារធ្វើ ឬ មានការងារធ្វើដែរ តែជាការងារ ដែលងាយរងគ្រោះ ត្រូវមានចំណេះដឹង ជំនាញទន់ និង ការជឿជាក់លើសមត្ថភាពរបស់ខ្លួន ក្នុងការកំណត់យកការងារ ដែលខ្លួនជ្រើសរើស និង ស្វែងរកការគាំទ្រពីមនុស្ស ដែលមានឥទ្ធិពលរបស់ខ្លួន ដូចជា សមាជិកគ្រួសារ ជាដើម ។

## តើឯកសារអប់រំនេះចង់បានអ្វី?

ឯកសារអប់រំនេះ ផលិតឡើងសម្រាប់អង្គការអភិវឌ្ឍន៍ ស្ថាប័នអប់រំ និង អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការជាមួយអ្នកស្វែងរកការងារ ដែលមានជំនាញទាប ។

ការស្វែងរកការងារ អាចជាដំណើរការដ៏លំបាកមួយសម្រាប់មនុស្សជាច្រើន ដែលទើបតែចាប់ផ្តើមរកការងារធ្វើ ។ ឯកសារអប់រំនេះ ទុកគ្រាន់ជាមគ្គុទេសក៍អនុវត្តសម្រាប់អ្នកសម្របសម្រួល ក្នុងការជួយដល់យុវជននៅជនបទ ដើម្បីប្រើប្រាស់ជាមាគ៌ាមួយរបស់ខ្លួន ក្នុងការស្វែងរកឱកាសការងារមួយឲ្យបានពេញលេញ ។

ឯកសារអប់រំ និង ធនធានផ្សេងៗ ដែលបានចែកជូនគ្រូឧទ្ទេសនៅទីនេះ គឺជាអ្វីដែលពួកគេត្រូវយកទៅបំពាក់ឲ្យយុវជន ដើម្បីឲ្យគេះ

- កំណត់គោលដៅ និង សកម្មភាពក្នុងការជួយឲ្យខ្លួនអាចសម្រេចគោលដៅនេះ
- ក្រេបជញ្ជក់យកជំនាញសម្រាប់ស្វែងរកការងារដែលពាក់ព័ន្ធដោយសុវត្ថិភាព
- ស្វែងយល់ពីជំនាញទន់ និង យកជំនាញទាំងនេះទៅអនុវត្តតាមការដែលអាចធ្វើបាន
- គិតគូពីភាពចាំបាច់ក្នុងការគ្រប់គ្រង និង ចាត់ចែងលុយរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព
- មានការជឿជាក់លើខ្លួនឯង ក្នុងការស្វែងរកការគាំទ្រពីមនុស្ស ដែលមានឥទ្ធិពលរបស់ខ្លួន
- ប្រមូលចំណេះដឹងពីធនធានដែលមាន សម្រាប់ជួយគាំទ្រដល់ពួកគេ

កម្មវិធីបណ្តុះបណ្តាល ដែលមាននៅក្នុងឯកសារ នៃមេរៀននេះ គឺសម្រាប់យុវជន ដែលមិនមានការងារធ្វើ ឬ អ្នកកំពុងធ្វើការងារ ដែលងាយរងគ្រោះ ។ ឯកសារនេះ មិនត្រូវបានចងក្រងឡើងដើម្បីអប់រំដល់ក្រុមមនុស្សមានវ័យចំណាស់ ដែលកំពុងមានការងារធ្វើនោះទេ ។

# សេចក្តីសង្ខេបអំពីខ្លឹមសារឯកសារអប់រំ

## តើមាតិកា នៃកម្មវិធីក្លាហាន9 នេះជាអ្វីទៅ?

មាតិកា នៃកម្មវិធីក្លាហាន9 គួរប្រើរួមគ្នាជាមួយឯកសារនេះ ធ្វើដូច្នេះវាបន្ថែមនូវគំនិតអប់រំពីបរិបទខ្មែរទៅក្នុងវគ្គបណ្តុះបណ្តាល។ មាតិកានៃកម្មវិធីក្លាហាន9 ដូចជារឿងភាគតាម ទូរទស្សន៍ និង រឿងអប់រំខ្លីៗតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលត្រូវជ្រើសរើសមកធ្វើជាឧទាហរណ៍ លើប្រធានបទដែលបាន យកមកពិភាក្សា ។ ចំណុចដែលត្រូវលើកយកមកពិភាក្សា និង ចម្លើយ អមដោយគំនិតអប់រំស្របតាមមាតិកានីមួយៗនឹងត្រូវ បានផ្តល់ជូន ។

សកម្មភាពជាច្រើន ត្រូវបានដាក់បញ្ចូលនៅក្នុងមេរៀននីមួយៗក្នុងគោលបំណងឆ្លុះបញ្ចាំង ពីការសិក្សារៀនសូត្ររបស់សិក្ខា កាម និង ការបំពេញបន្ថែមចំណុចខ្វះខាតផ្សេងៗនៅក្នុងវគ្គ បណ្តុះបណ្តាល ។

នៅក្នុងឯកសារអប់រំនេះ អ្នកនឹងរកឃើញនូវៈ
សកម្មភាពចំនួន ២០
រឿងវីដេអូអប់រំបំផុសគំនិតចំនួន ៥
អង្គាំ ៥ ពណ៌ ដែលមានដោតខ្សែរបស់វា
គំនូរជីវចលចំនួន៦ ដើម្បីនាំអ្នកទៅតាមជំពូកនិមួយៗ

នៅចុងបញ្ចប់ នៃឯកសារអប់រំនេះ វានៅមានឧបសម្ព័ន្ធ ដែលមានព័ត៌មានអប់រំបន្ថែមមួយចំនួនទៀត ដែលអ្នកអាចប្រើ ដើម្បីសិក្សាស្វែងយល់អំពីប្រធានបទនីមួយៗ ។

## តើនៅក្នុងឯកសារអប់រំនេះ មានអ្វីខ្លះ?

ឯកសារអប់រំនេះ ណែនាំអំពីការស្វែងរកការងារធ្វើ អំពីជំនាញទន់ និង ការគ្រប់គ្រងហិរញ្ញវត្ថុ។ សំណុំឯកសារនេះរៀបចំឡើងទុក ជាមាគ៌ា សម្រាប់អប់រំសិក្ខាកាម ក្នុងការស្វែងរកការងារធ្វើពីកម្រិតមូលដ្ឋាន ទៅដល់កម្រិត នៃតម្រូវការការងារ ដែលមានលក្ខណៈស្មុគស្មាញដូចជា ជំនាញក្នុងការចរចារ និងការសម្ភាសន៍ជាដើម។ គម្រោងមេរៀននេះ បង្ហាញការណែនាំពីលំដាប់លំដោយទូទៅ នៃឯកសារអប់រំ ហើយវាបង្ហាញ ពីការបំពេញបន្ថែមនូវគំនិតអប់រំ នៃ "ផែនការសកម្មភាពរបស់ខ្ញុំ" ដែលស្របទៅតាមឯកសារអប់រំនេះ តាំងពីដើមរហូតដល់ចប់ ។ ដូច្នេះ គេអាចនិយាយបានថា គ្រូឧទ្ទេសអាចអនុវត្តតាមគំរូមេរៀន និង សកម្មភាពទាំងនេះបាន ដោយអាស្រ័យទៅលើសមត្ថភាពនៃក្រុមគោលដៅរបស់ពួកគេផងដែរ ។

## តើគេអាចប្រើឯកសារអប់រំនេះដោយរបៀបណា?

មានវគ្គបណ្តុះបណ្តាលចំនួន ៥ ជំពូក នៅក្នុងឯកសារអប់រំនេះ ។ រាល់វគ្គបណ្តុះបណ្តាលនីមួយៗ ចាប់ផ្តើមជាមួយនឹងវគ្គនៃការធ្វើ សេចក្តីផ្តើមនៅក្នុង ប្រធានបទនៃមេរៀន អមដោយករណីសិក្សាខ្លីៗ និង មាតិកាកម្មវិធី ក្លាហាន9 ។ រួមជាមួយសកម្មភាពជាច្រើន ការបំផុសសំណួរពិភាក្សា និង រំលឹកមេរៀនឡើងវិញ ។

មេរៀននីមួយៗ មានពណ៌ ជាសំគាល់ ហើយមុននឹងបញ្ចប់មេរៀននីមួយៗ សិក្ខាកាម ត្រូវធ្វើបទបង្ហាញជាមួយនឹង គ្រាប់អង្កាំ ដែលត្រូវស្របគ្នាជាមួយនឹង ពណ៌មេរៀននោះ ។ យើងសូមលើកទឹក ចិត្តអ្នក និង ក្រុមរបស់អ្នកចែករំលែកនូវការវិវត្ត នៃការប្រមូលគ្រាប់អង្កាំ ជា មួយនឹង បណ្តាញសង្គម ឬ មិត្តភក្តិ និង សមាជិកគ្រួសាររបស់ខ្លួន ។

ទម្រង់ផែនការ សកម្មភាពរបស់ខ្ញុំ រៀបចំឡើងក្នុងគោលបំណងជួយដល់សិក្ខាកាមក្នុងការប្រមូលចំណេះដឹងរបស់ពួកគេក្នុងវគ្គបណ្តុះបណ្តាល និង ជួយពួកគេឲ្យចេះដាក់បញ្ចូលនូវអ្វី ដែលគេបានរៀនចូលទៅក្នុងផែនការ ការងារ ដើម្បីសម្រេចនូវគោលដៅ របស់ពួកគេ។ ឆ្លងកាត់វគ្គបណ្តុះ បណ្តាលនេះនិមួយៗ គេត្រូវមានការណែនាំមួយថាតើនៅពេលណា និង ត្រូវបំពេញផែនការសកម្មភាពរបស់ខ្ញុំ ដោយរបៀបណា ។ នៅចុងបញ្ចប់ យើងលើកទឹកចិត្តឲ្យសិក្ខាកាមម្នាក់ៗ ចម្លង/ថត ឬកត់ត្រាទុក នូវផែនការសកម្មភាពរបស់ខ្លួនក្នុងទូរស័ព្ទដៃ និង/ឬ ចែកចាយវាជាមួយនឹងមិត្តភក្តិ និងសមាជិកគ្រួសារ។

ដើម្បីជ្រាបព័ត៌មានបន្ថែមពី កម្មវិធីក្លាហាន9 និង ការចូលមើលវីដេអូកម្មវិធីក្លាហាន9 សូមចូលមើល៖

https://www.facebook.com/klahan9cambodia

https://www.youtube.com/klahan9cambodia

http://klahan9.com.kh

រយៈពេល នៃម៉ោងសិក្ខាសាលាសរុបទាំងអស់ចំនួន ៩ ទៅ ១០ម៉ោង ។ ខាងក្រោមនេះ ជាពេលវេលាដែលអ្នកគួរចំណាយក្នុងវគ្គសិក្ខាសាលានីមួយៗ ។ នេះគ្រាន់តែជាមាគ៌ា នៃការណែនាំរបស់អ្នកប៉ុណ្ណោះ ។

# អំពីពេលវេលា

| តម្រូវការ នៃពេលវេលា | |
|---|---|
| **ពេលវេលា ជាអតិបរិមា** | **សកម្មភាព** |
| **ជំពូក១៖ សេចក្តីផ្តើម** | |
| ១០នាទី | សុន្ទរកថាស្វាគមន៍ និង ការបើកកម្មវិធី |
| ១៥នាទី | សកម្មភាពទី១: ការណែនាំខ្លួន ដើម្បីឲ្យសិក្ខាកាមបានស្គាល់គ្នា |
| **ជំពូក២៖ ការងារ** | |
| ៣០នាទី | សកម្មភាពទី២: ល្បែងកំសាន្ត ខុស ឬ ត្រូវ |
| ៣០នាទី | សកម្មភាពទី៣: ករណីសិក្សា៖ ប្រភេទ នៃការងារ |
| ៣០នាទី | សកម្មភាពទី៤: ករណីសិក្សា |
| **ជំពូក៣៖ ការទទួលបានការងារធ្វើ** | |
| | កន្លែងទទួលព័ត៌មានអំពីការងារ |
| ១៥នាទី | សកម្មភាពទី៥: ករណីសិក្សា៖ ការពិភាក្សាជាមួយទីភ្នាក់ងារជាតិមុខរបរ និង ការងារ (NEA) |
| ២០នាទី | សកម្មភាពទី៦: សេចក្តីប្រកាសផ្សាយអំពីការងារ |
| | ត្រូវមានសុវត្ថិភាពនៅពេលស្វែងរកការងារធ្វើ |
| ២០នាទី | សកម្មភាពទី៧: ករណីសិក្សា៖ ចំណាកស្រុក |
| ៣០នាទី | សកម្មភាពទី៨: ការស្វែងរកការងារ ដែលមានសុវត្ថិភាព |
| **ជំពូក៤៖ ជំនាញ** | |
| ២០នាទី | សកម្មភាពទី០៩: ករណីសិក្សា៖ ជំនាញទន់ |
| | ការអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និង វិជ្ជាជីវៈ (TVET Skills) |
| ១០នាទី | សកម្មភាពទី១០: ករណីសិក្សា៖ ជំនាញកាត់ដេរ |
| ១៥នាទី | សកម្មភាពទី១១: ករណីសិក្សា៖ TVET ឬសាកលវិទ្យាល័យ, តើអ្នកគួរជ្រើសរើសយកសាលាមួយណា? |
| ៣០នាទី | សកម្មភាពទី១២: ជំនាញក្នុងការងារ |
| | ជំនាញទន់ |
| ៣០នាទី | សកម្មភាពទី១៣: ការប្រែក្លាយជំនាញឲ្យទៅជាការធ្វើការងារ |
| ៦០នាទី | សកម្មភាពទី១៤: ការយកជំនាញទៅអនុវត្តការងារជាក់ស្តែង |
| ៣០នាទី | សកម្មភាពទី១៥: សម្ភាសន៍ការងារ ដែលបានដាក់ពាក្យនោះ |
| **ជំពូក៥៖ ការគ្រប់គ្រងប្រាក់របស់អ្នក** | |
| | ការធ្វើផែនការថវិកា |
| ២០នាទី | សកម្មភាពទី១៦: ករណីសិក្សា៖ ការធ្វើផែនការថវិកា |
| | ការសន្សំប្រាក់ |
| ១៥នាទី | សកម្មភាពទី១៧: ករណីសិក្សា៖ គន្លឹះក្នុងការសន្សំប្រាក់ |
| | ប្រាក់បំណុល និង ប្រាក់កម្ចី |
| ៣០នាទី | សកម្មភាពទី១៨: ករណីសិក្សា៖ ប្រាក់បំណុល និងប្រាក់កម្ចី |
| | ការបែងចែកថវិកា |
| ២០នាទី | សកម្មភាពទី១៩: តម្រូវការ និង ចំណង់ |
| **ជំពូក៦៖ ជំណាក់កាលបន្ទាប់ក្នុងការសម្រេចគោលដៅរបស់អ្នក** | |
| ៤៥នាទី | សកម្មភាពទី២០: ផែនការសកម្មភាពរបស់ខ្ញុំ |

# បញ្ជីផ្ទៀងផ្ទាត់វគ្គបណ្តុះបណ្តាល

## ក្នុងការបណ្តុះបណ្តាល អ្នកត្រូវការ៖

- ☐ ប័ណ្ណសកម្មភាពី ១ ដល់ ២១
- ☐ កាតសកម្មភាពនីមួយៗ
- ☐ សេណារីយ៉ូរបស់សកម្មភាព
- ☐ ក្រដាស់សរសេរផ្ទាំងធំ (Flip chart)
- ☐ ហ្វឺតសរសេរ
- ☐ ប៊ិចពណ៌/ខ្មៅដៃ
- ☐ ក្រដាស់សរសេរចំណាំ (Note pad)
- ☐ ក្រដាស់ពណ៌
- ☐ ស្កុត ឬស្កុតមុខពីរ
- ☐ កន្ត្រៃ
- ☐ វីដេអូ និង គេហទំព័រ ដែលមានរាយមុខក្នុងឧបសម្ព័ន្ធ
- ☐ តន្ត្រីកំដរអារម្មណ៍ (Music to play in the background)
- ☐ ទម្រង់សកម្មភាពរបស់ខ្ញុំ (My ACTION worksheet)
- ☐ ការចូលប្រើប្រាស់ប្រព័ន្ធអ៊ិនធើណែត (ប្រសិនបើមាន)
- ☐ ទាញយកនូវឯកសារអប់រំ (Tablet with toolkit downloaded)
- ☐ វីដេអូ និង គេហទំព័រ ដែលបានរាយមុខនៅក្នុងឯកសារអប់រំ ដែលបានទាញយក (Videos and webpages listed in the toolkit downloaded on tablet)
- ☐ ការកាត់យកព័ត៌មាន នៃសេចក្តីប្រកាសផ្សាយអំពីការងារ (Job adverts cut out)
- ☐ បៃកគ្រាប់អង្កាំ ៥ ពណ៌ ដែលមានខ្សែឲ្យសិក្ខាកាមម្នាក់ៗ

០១

# សេចក្តីផ្តើម
# អំពីសិក្ខាសាលា



# ១.១. កិច្ចស្វាគមន៍ និង ការបើកកម្មវិធីសិក្ខាសាលា

ការចាក់បញ្ចាំងរឿងវីដេអូបំផុសគំនិត (Inspirational video)
https://www.facebook.com/klahan9cambodia/videos/986034271533571/

**គោលបំណង៖**

- សុន្ទរកថាស្វាគមន៍ សិក្ខាកាម
- ពន្យល់អំពីកម្មវិធីក្លាហាន9 ជាអ្វី
- កំណត់លទ្ធផលរំពឹងទុក និង គោលការណ៍ណែនាំ ពីសិក្ខាសាលា




ថ្លែងសុន្ទរកថាស្វាគមន៍ សិក្ខាកាម ដែលមានវត្តមានក្នុងអង្គសិក្ខាសាលា និង ពន្យល់ថាអង្គសិក្ខាសាលានេះ ជាផ្នែកមួយ នៃកម្មវិធីក្លាហាន9 (សូមមើលសារជារូបភាពខាងលើ ដើម្បីជាប្រព័ត៌មានបន្ថែម) ។

កុំភ្លេចកំណត់នូវលទ្ធផលរំពឹងទុក ពីអង្គសិក្ខាសាលាសម្រាប់ថ្ងៃនេះ ដោយសួរសិក្ខាកាមថា
តើអ្នកគិតថាមានចំណុចអ្វីដែលធ្វើអោយថ្ងៃសិក្ខាសាលានេះមានសារៈសំខាន់ និង រីករាយ?
(សូមលើកដៃឡើង ប្រសិនបើអ្នកចង់និយាយ លឿនឡើង កុំលេងទូរស័ព្ទ និង សុំស្តាប់សិក្ខាកាមគ្រប់ៗគ្នា) ។
សុំសរសេរខ្លឹមសារទាំងអស់នេះ នៅលើផ្ទាំងក្រដាស់ធំមួយ ដើម្បីឲ្យសិក្ខាកាមម្នាក់ៗ
បានមើលក្នុងវគ្គសិក្ខាសាលាថ្ងៃនេះ ។

# សកម្មភាពទី ១

## ការធ្វើការណែនាំខ្លួន ដើម្បីឲ្យសិក្ខាកាមបានស្គាល់គ្នា

រយៈពេល នៃការធ្វើលំហាត់នេះ : ១៥ នាទី



### គោលបំណង នៃការធ្វើលំហាត់:

- ដើម្បីឲ្យសិក្ខាកាមបានរៀនបន្ថែមទៀតពីសិក្ខាកាមដទៃនៅក្នុងវគ្គបណ្តុះបណ្តាល
- ដើម្បីឲ្យសិក្ខាកាមបានអនុវត្តជំនាញក្នុងការស្តាប់

### សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ នៃមេរៀន)

សិក្ខាកាម អាចត្រូវការក្រដាស ឬ ប៊ិច ដើម្បីសរសេរទុកនូវចម្លើយ នៃសិក្ខាកាម ដែលជាដៃគូរបស់ពួកគេ ។

### ដំណើរការ នៃការធ្វើលំហាត់:

- អ្នកសម្របសម្រួល ត្រូវពន្យល់ក្រុមសិក្ខាកាមថា ឥឡូវនេះ ពួកគេនឹងបានស្គាល់គ្នាច្បាស់ជាងមុនបន្តិចហើយ ។
- អ្នកសម្របសម្រួល ត្រូវពន្យល់ប្រាប់សិក្ខាកាមថា ពួកគេត្រូវសួរគ្នានូវសំណួរមួយចំនួន ហើយនៅចុងបញ្ចប់ នៃសកម្មភាពនេះ អ្នកសម្របសម្រួលត្រូវប្រាប់សិក្ខាកាមឲ្យណែនាំដៃគូរបស់ពួកគេទៅប្រាប់ក្រុមសិក្ខាកាមទាំងអស់បានដឹង ។
- អ្នកសម្របសម្រួល ត្រូវបែងចែកក្រុមសិក្ខាកាមឲ្យទៅជាក្រុមតូចៗ ដែលក្នុងមួយក្រុមៗ ត្រូវមានគ្នាពីពីរ ទៅ បីនាក់ ។
- អ្នកសម្របសម្រួល ត្រូវសួរសិក្ខាកាមឲ្យបានពួៗ និង សួរសំណួរទាំងបីខាងក្រោម ម្តងមួយសំណួរៗ ។ យ៉ាងហោចណាស់ក៏ក្នុងសំណួរនីមួយៗ ត្រូវទុកពេលឲ្យពួកគេពី ២ ទៅ ៣ នាទី ដើម្បីឲ្យសិក្ខាកាមសួរសំណួរ និង ស្តាប់ចម្លើយរបស់សមាជិកដ៏ទៃទៀតក្នុងក្រុម ។

### សំណួរ:

- តើអ្នកឈ្មោះអ្វី និង មកពីណា?
- អ្វីដែលជាការពិតហើយចាប់អារម្មណ៍របស់អ្នក, បទចម្រៀង ឬ របាំអ្វីដែលអ្នកចូលចិត្ត
- តើការងារអ្វីជាការងារក្នុងក្តីសុបិន្តរបស់អ្នក?

### ការបញ្ចប់កម្មវិធីធ្វើលំហាត់:

- អ្នកសម្របសម្រួល ត្រូវហៅក្រុមទាំងអស់ឲ្យមកជួបជុំគ្នាវិញ ហើយសុំឲ្យសិក្ខាកាមណែនាំដៃគូរបស់គេទៅកាន់ក្រុម ដែលក្រុមនីមួយៗមានរយៈពេល ៣០ វិនាទី ។

០២

# អំពីការងារ



ការចាក់បញ្ចាំងរឿងវីដេអូបំផុសគំនិត (Inspirational video)

https://www.facebook.com/klahan9cambodia/videos/1032509140219417/

**គោលបំណង៖**

- តើហេតុអ្វីបានជាវាសំខាន់សម្រាប់ខ្ញុំ?
- តើមានជម្រើសការងារអ្វីខ្លះសម្រាប់ខ្ញុំ?
- ដើម្បីជួយសិក្ខាកាមឲ្យកំណត់នូវគោលបំណង នៃអាជីពផ្ទាល់ខ្លួនរបស់ពួកគេ



# សកម្មភាពទី ២

## ល្បែងកំសាន្ត ខុស ឬ ត្រូវ

រយៈពេល នៃការធ្វើលំហាត់នេះ : ៣០ នាទី



## គោលបំណង នៃការធ្វើលំហាត់:

- ដើម្បីឲ្យសិក្ខាកាមយល់បន្ថែមទៀតអំពីអ្វីដែលសិក្ខាកាមបានដឹងអំពីការងារ
- ដើម្បីឲ្យសិក្ខាកាមយល់អំពីព័ត៌មាននៅក្នុងឯកសារអប់រំនេះ បានយល់អំពីអ្វីដែលពួកគេនឹងរៀន និង អំពីសារៈសំខាន់ នៃព័ត៌មានសម្រាប់ពួកគេ ។

## សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

- ប័ណ្ណផ្តល់ចម្លើយសម្រាប់សំណួរពី ១ ដល់ សំណួរទី ១៤
- ក្រដាស
- ប៊ិច/ខ្មៅដៃ

## ដំណើរការ នៃការធ្វើលំហាត់:

- ពន្យល់សិក្ខាកាមក្នុងក្រុមថា អ្នកត្រូវចាប់ផ្តើមវគ្គនេះនូវសំណួរល្បងប្រាជ្ញាខ្លីៗ
- ពន្យល់ប្រាប់សិក្ខាកាមថា អ្នកត្រូវសួរពួកគេនូវសំណួរជាបន្តបន្ទាប់ ហើយអ្នកចង់ឲ្យពួកគេឆ្លើយនូវចម្លើយ ថា បាទ/ចាស ទេ ឬ មិនដឹង
- សុំប្រាប់សិក្ខាកាមឲ្យឱនក្បាលចុះបន្តិច និង បិទភ្នែកផង
- សុំអានសំណួរទី១ខាងក្រោមនេះ និង សុំឲ្យសិក្ខាកាមលើកដៃឡើង ប្រសិនបើចម្លើយរបស់ពួកគេឆ្លើយថា បាទ/ចាស
- រាប់ និង កត់ទុកនូវចំនួន នៃការលើកដៃនោះ
- ក្រោយមក សុំឲ្យពួកគេលើកដៃជាថ្មី ប្រសិនបើចម្លើយរបស់ពួកគេឆ្លើយថា ទេ
- រាប់ និង កត់ទុកនូវចំនួន នៃការលើកដៃនោះ
- បន្ទាប់មកទៀត សុំឲ្យសិក្ខាកាមលើកដៃឡើងទៀត ប្រសិនបើចម្លើយរបស់ពួកគេឆ្លើយថា មិនដឹង
- រាប់ និង កត់ទុកនូវចំនួន នៃការលើកដៃនោះ ។ ធ្វើរបៀបនេះ ឲ្យបានគ្រប់សំណួរខាងក្រោម (ចាប់ពី សំណួរទី១ រហូតដល់ ១៤) ។
- ត្រូវធ្វើយ៉ាងណាឲ្យសិក្ខាកាមម្នាក់ៗឆ្លើយគ្រប់សំណួរ និង ពិនិត្យថា ពួកគេនៅតែបិទភ្នែកដដែល នៅពេល ឆ្លើយ ។

## សំណួរ:

១) ការងារ គឺជាពេល ដែលអ្នកចាកចេញពីផ្ទះរាល់ថ្ងៃនៅពេលដំណាលគ្នា ។
២) មានការងារធ្វើ មានន័យថា អ្នកមានលុយចាយ ។
៣) ការនៅជាសិស្ស មានន័យថា អ្នកមានការងារធ្វើ ។
៤) អ្នកនឹងមានកិច្ចសន្យាការងារជានិច្ច ប្រសិនបើមានការងារធ្វើ ។
៥) អ្នកអាចត្រូវគេជួលឲ្យធ្វើការបាន តែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ។
៦) សហគ្រិនភាព មិនមែនជារូបភាព នៃភាពមានការងារធ្វើនោះទេ ។
៧) ការទទួលការបណ្តុះបណ្តាលមុខវិជ្ជាជីវៈជាអ្នកសំណង់ នឹងមិនធ្វើឲ្យខ្ញុំរកចំណូលបានច្រើនប៉ុន្មាននោះទេ ។
៨) ការជាប់បំណុលគេ មានន័យថា ខ្ញុំមានប្រាក់សម្រាប់ប្រើប្រាស់ ។
៩) ការសន្សំប្រាក់ អាចជួយខ្ញុំឲ្យមានអនាគត ។
១០) ការទទួលបានការអប់រំ អាចជួយដល់ការរីកចម្រើនខាងមុខរបរវិជ្ជាជីវៈ ។
១១) ការដែលមានធនធានជាច្រើននៅក្នុងភូមិរបស់ខ្ញុំ អាចធ្វើឲ្យពលរដ្ឋដូចរូបខ្ញុំ រកបានការងារសមរម្យធ្វើ ។
១២) ការរកប្រាក់ចំណូលបាន អាចជួយឲ្យខ្ញុំអាចសម្រេចគោលដៅរបស់ខ្ញុំបាន ។
១៣) មានតែប្រជាជននៅរាជធានីភ្នំពេញទេ ដែលមានគោលដៅរបស់ខ្លួន ។
១៤) មានតែឪពុកម្តាយរបស់ខ្ញុំទេ ដែលអាចសម្រេចថា អ្វីដែលខ្ញុំត្រូវធ្វើចំពោះការងាររបស់ខ្ញុំ ។

- បន្ទាប់ពីបញ្ចប់ការសួរសំណួរទាំងអស់នេះហើយ និង ធ្វើការកត់ទុកចម្លើយចាប់តាំងពីសំណួរទី១មក
- ប្រើប័ណ្ណផ្តល់ចម្លើយសម្រាប់សកម្មភាពទី២ ដោយប្រើពេលប្រមាណជាពីរនាទី ក្នុងការឆ្លើយសំណួរនីមួយៗ
- ត្រូវប្រាកដថាបានសួរសិក្ខាកាមថាតើពួកគេមានសំណួរអ្វីចំពោះចម្លើយនេះដែរឬទេ
- ត្រូវធ្វើតាមជំហានខាងលើនេះ សម្រាប់ការឆ្លើយសំណួរទាំងអស់ ដោយត្រូវធ្វើយ៉ាងណាឲ្យប្រាកដថាសិក្ខាកាមបានយល់សំណួរនីមួយៗ និង ផ្តល់ឱកាសឲ្យពួកគេបានសួរសំណួរប្រសិនបើពួកគេត្រូវការសួរ

### ការបញ្ចប់កម្មវិធីធ្វើលំហាត់:

សុំពន្យល់ប្រាប់សិក្ខាកាមថា អ្នកមិនគួរមានការថ្នាំងថ្នាក់ក្នុងចិត្តអ្វីទេ ប្រសិនបើអ្នកឆ្លើយសំណួរ “ខុស” ព្រោះថា ឯកសារអប់រំនេះ នឹងបង្ហាញអ្នកនូវអ្វីដែលអ្នកចង់ដឹងអំពីសំណួរខាងលើនោះ ហើយវាក៏នឹងបង្ហាញអ្នកអំពីវិធីទទួលបានការងារល្អៗដែរ ។

# សកម្មភាពទី ៣



**ករណីសិក្សា៖**
**ប្រភេទ នៃការងារ**

រយៈពេល នៃការធ្វើលំហាត់នេះ : ៣០ នាទី

## គោលបំណង នៃការធ្វើលំហាត់:

- ដើម្បីឲ្យសិក្ខាកាមចាប់ផ្តើមគិតអំពីការងារ ដែលខ្លួនចង់ធ្វើដោយរបៀបណា និង នៅកន្លែងណា
- ដើម្បីឲ្យសិក្ខាកាមបានរៀនបន្ថែមទៀតអំពីគំនិត នៃការទទួលបានការងារសមរម្យ

## សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

នេះជាវីដេអូខ្លីដែលមានរយៈ ៣០ នាទី ប្រសិនបើអ្នកគ្មានពេលគ្រប់គ្រាន់ក្នុងការមើលវីដេអូខ្លីនេះ ឲ្យបានចប់ចុងចប់ដើមជាមួយនឹងក្រុមរបស់អ្នកទេ សុំមើលវាម្នាក់ឯងសិន មុននឹងចាក់បង្ហាញឲ្យក្រុមរបស់អ្នកមើល និង សុំកំណត់ចំណាំដោយយកតែកន្លែងណាដែលអ្នកគិតថាជាផ្នែកសំខាន់ៗសម្រាប់ចាក់បង្ហាញឲ្យក្រុមរបស់អ្នកមើលក៏បានដែរ ។

https://www.facebook.com/klahan9cambodia/videos/881447425325590/

## ដំណើរការ នៃការធ្វើលំហាត់:

អ្នកសម្របសម្រួល ត្រូវពន្យល់ប្រាប់សិក្ខាកាមថា ពួកគេនឹងត្រូវមើលវីដេអូខ្លី ស្តីពី ប្រភេទ នៃការងារ ។ ពន្យល់ប្រាប់ពួកគេបន្ថែមទៀតថា បន្ទាប់ពីមើលវីដេអូខ្លីនេះរួចមក នឹងមានការពិភាក្សាជាក្រុម ដោយទុកឲ្យសិក្ខាកាមម្នាក់ៗ បានគិតរៀងៗខ្លួន និង ប្រើប្រាស់នូវចំណេះដឹង ដែលពួកគេបានរៀននៅថ្ងៃនេះ ។ សូមមើលនៅក្នុងករណីសិក្សា និង ត្រូវទទួលយកគំនិតពីអ្នកដទៃទៀតនៅក្នុងបន្ទប់នេះ ។

អ្នកសម្របសម្រួល ត្រូវចាក់បញ្ចាំងវីដេអូខ្លីៗពីក្នុងបណ្តាញវេបសាយខាងលើ (អាស័យដ្ឋាន នៃបណ្តាញនេះក៏មាននៅក្នុងឯកសារអប់រំដែរ) ។

អ្នកសម្របសម្រួល ត្រូវបំបែកក្រុមឲ្យទៅជាក្រុមតូចៗ ឬ ក្នុងមួយក្រុម ដែលមានគ្នាត្រឹមតែពីរនាក់ ។
អ្នកសម្របសម្រួល ត្រូវសុំឲ្យក្រុមនីមួយៗពិភាក្សានូវប្រធានបទ ដូចខាងក្រោម ។ ផ្តល់ឱកាសឲ្យក្រុមនីមួយៗ ចំនួន ៣ នាទី ក្នុងការឆ្លើយសំណួរនីមួយៗ៖

- ហេតុអ្វីបានជាការទទួលបានការងារធ្វើសមរម្យ គឺជារឿងសំខាន់
- វិធី នៃការទទួលបានការងារធ្វើ - តើនៅទីនោះមានការងារប្រភេទណាខ្លះ ជាការងារ ដែលនៅមានប៉ុស្តិ៍ទំនេរ និង ជាការងារ ដែលពួកគេចង់ធ្វើ ។
- ត្រូវប្រៀបធៀប និង រកចំណុចខុសគ្នាអំពីអត្ថប្រយោជន៍ នៃប្រភេទការងារ ដែលខុសគ្នា
- បង្កើតនូវលក្ខណៈវិនិច្ឆ័យសម្រាប់ការងារ ដែលពួកគេចូលចិត្តធ្វើ - ឧទាហរណ៍ ចំណុចទាំងនេះអាចផ្តើមជាមួយនឹងពាក្យថា តើការងារនោះនៅកន្លែងណា ជាការងារអ្វី ត្រូវធ្វើនៅពេលណា តើថ្លៃឈ្នួលប៉ុន្មាន លក្ខខ័ណ្ឌការងារដូចម្តេច តើត្រូវធ្វើការងារប៉ុន្មានម៉ោងក្នុងមួយថ្ងៃ/មួយសប្តាហ៍ ។ល។

## ការបញ្ចប់កម្មវិធីធ្វើលំហាត់:

អ្នកសម្របសម្រួល ត្រូវប្រមូលសិក្ខាកាមឲ្យមកជួបជុំគ្នាវិញ និង សុំឲ្យសិក្ខាកាមចែករំលែកនូវគំនិតយោបល់របស់ពួកគេជាមួយនឹងសិក្ខាកាមផ្សេងទៀតនៅក្នុងក្រុមធំ ។

នៅពេលអ្នកបានបញ្ចប់ការពិភាក្សាអំពីប្រភេទនៃការងាររួចហើយ នេះជាឱកាសល្អមួយក្នុងការធ្វើការលើកទី១ ទៅលើតារាង ផែនការសកម្មភាពរបស់ខ្ញុំ ។ សុំឲ្យសិក្ខាកាមម្នាក់ៗធ្វើលំហាត់នេះ ដោយខ្លួនឯង តែទោះជាត្រូវធ្វើយ៉ាងនេះក៏ដោយ ក៏សុំលើកទឹកចិត្តឲ្យសិក្ខាកាមធ្វើការពិភាក្សាក្នុងក្រុម ដើម្បីឲ្យសិក្ខាកាមដទៃទៀត ចែករំលែង និង បង្ហាញពីអ្វីដែលពួកគេបានរៀន ។ សុំមើលតារាងផែនការរបស់ខ្ញុំខាងក្រោមនេះ ដើម្បីបានជ្រាបនូវព័ត៌មានលំអិត ។

## ផែនការសកម្មភាពរបស់ខ្ញុំ

ការកំណត់គោលដៅ និង ផែនការសម្រាប់អនាគត អាចជួយយើងឲ្យទទួលបាននូវអ្វីដែលយើងចង់បាន និងជាហេតុ នាំឲ្យយើងបញ្ចូលផែនការសកម្មភាពសម្រាប់ឲ្យសិក្ខាកាមបំពេញកិច្ចការឲ្យរួចក្នុងរយៈពេល នៃការរៀនពេញមួយថ្ងៃនេះ ។ នេះជារបៀប ដែលត្រូវប្រើ ផែនការសកម្មភាព នេះ ៖

ផែនការសកម្មភាពរបស់ខ្ញុំ អាចត្រូវបញ្ចប់ក្នុងរយៈពេលមួយថ្ងៃ ។
វាជួយសិក្ខាកាមឲ្យមើលឃើញ និង កំណត់នូវផែនការរបស់ពួកគេ ។
មែកឈើមួយមែកៗ នៃដើមឈើមួយ គឺជាផ្នែកមួយសម្រាប់ឲ្យពួកគេបំពេញការងារឲ្យបានចប់សព្វគ្រប់ ។

ឯកសារអប់រំ នឹងបង្ហាញផ្លូវអ្នកបាន ពេលដែលក្រុមសិក្ខាកាមរបស់អ្នកអាចបញ្ចប់នូវផែនការនេះ ។
គោលបំណង នៃផែនការសកម្មភាពនេះ គឺជួយធ្វើឲ្យសិក្ខាកាមទទួលបាននូវអ្វី ដែលពួកគេបានរៀនពីមេរៀនទាំងនេះ និង អាចកំណត់នូវវាសនា នៃជីវិតរបស់ពួកគេផ្ទាល់ ។ គេក៏សង្ឃឹមផងដែរថា ផែនការនេះអាចនឹងជួយបង្ហាញផ្លូវអ្នកក្នុងការស្វែងរកការងារធ្វើ ការគ្រប់គ្រង់លុយកាក់ប្រាក់កាស និង ការរៀនសូត្រ នូវជំនាញ ថ្មីៗ ប៉ុន្តែ វាមិនមែនជាការធ្វើដំណើរដ៏វែងឆ្ងាយមួយលើខ្សែបន្ទាត់ត្រង់រហូតនោះទេ ។

ក្នុងនាមជាអ្នកសម្របសម្រួល អ្នកអាចជួយពួកគេឲ្យបំពេញផែនការនេះ ក្នុងរយៈពេល នៃការបណ្តុះបណ្តាលនេះ ។ សិក្ខាកាម ត្រូវគិតថា ពួកគេទទួលបានការគាំទ្រនៅពេលពួកគេត្រូវការ ដើម្បីឲ្យពួកគេអាចបំពេញផែនការសកម្មភាពនេះបាន ។ អ្នកអាចនឹងនិយាយពីរឿងនេះ ជាមួយពួកគេ ឬ ធ្វើការជាក្រុមរួមគ្នា ដើម្បីពិភាក្សា ពីផែនការផ្សេងៗគ្នា ។

ប្រសិនបើអ្នកគិតថា ក្រុមរបស់អ្នកអាចធ្វើការងារនេះបាន ដូច្នេះ ត្រូវទុកពេលឲ្យសិក្ខាកាមចំនួន ១០ នាទី ដើម្បីឲ្យពួកគេដាក់បញ្ចូលនូវការងារគំរូ និង លក្ខណៈវិនិច្ឆ័យចូលទៅក្នុងឯកសារ "ផែនការសកម្មភាពរបស់ខ្ញុំ" ។ ប្រសិនបើពួកគេមានការជឿជាក់ជួនល្មម ពួកគេអាចចែករំលែកគំនិតទាំងនេះជាមួយនឹងក្រុមសិក្ខាកាមទាំងអស់ ។ ប្រសិនបើពួកគេមិនអាចសរសេរបានទេ អ្នកសម្របសម្រួល ត្រូវជួយពួកគេក្នុងការបំពេញទម្រង់បែបបទនេះ ។

# សកម្មភាពទី ៤

## ករណីសិក្សា៖ ភ្នាក់ឡើង



រយៈពេល នៃការធ្វើលំហាត់នេះ : ៣០ នាទី

## គោលបំណង នៃការធ្វើលំហាត់:

- ជួយសិក្ខាកាមឲ្យបានយល់អំពីអ្វីទៅជាគោលដៅ
- ដើម្បីកំណត់មើលថាតើពួកគេមានគោលដៅដែរឬទេ
- លើកទឹកចិត្តឲ្យពួកគេធ្វើការកំណត់គោលដៅ
- ជួយសិក្ខាកាមឲ្យបង្កើតសកម្មភាព ដើម្បីធ្វើឲ្យពួកគេអាចសម្រេចគោលដៅ

## សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

https://www.facebook.com/klahan9cambodia/videos/836541076482892/

តារាងសកម្មភាពសម្រាប់សកម្មភាពទី៤

## ដំណើរការ នៃការធ្វើលំហាត់:

- អ្នកសម្របសម្រួល ត្រូវចាក់បញ្ចាំងវីដេអូខ្លីៗ ពីបណ្តាញវេបសាយខាងលើឲ្យសិក្ខាកាមទាំងអស់ បាន មើល (ហើយអាសយដ្ឋាន នៃវេបសាយនេះក៏មាននៅក្នុងឯកសារអប់រំដែរ) ។
- បន្ទាប់ពីបានមើលវីដេអូខ្លីៗរួច អ្នកសម្របសម្រួល ត្រូវសួរសិក្ខាកាមនូវសំណួរទាំងអស់ខាងក្រោមនេះ ។
- តើការចាក់វីដេអូនេះ ធ្វើឲ្យសិក្ខាកាមមានអារម្មណ៍យ៉ាងណា?
- តើពួកគេដឹងថាតើអ្វីទៅជាគោលដៅ?

- អ្នកសម្របសម្រួល ត្រូវសុំឲ្យសិក្ខាកាមមើលចំណុចទាំងអស់ ដែលនិយាយអំពីគោលដៅ ដូចតទៅនេះ៖
    - មិនថាអ្នកចង់ធ្វើការផ្លាស់ប្តូរដ៏ធំមួយក្នុងជីវិតរបស់អ្នក ឬ អ្នកគ្រាន់តែចង់ធ្វើការកែលំអរក្នុងចំណុចណាមួយនោះ អ្នកត្រូវកំណត់គោលដៅរបស់អ្នកមុនពេលអ្នកចាប់ផ្តើមការងារអ្វីមួយ ។
    - គោលដៅ គឺជាអ្វី ដែលអ្នកពិតជាចង់បាន និង ជាអ្វីដែលអ្នកត្រូវយកចិត្តទុកដាក់ឲ្យបានហ្មត់ចត់ ។
    - គោលដៅណាមួយដែលមានប្រយោជន៍ គឺជាគោលដៅដែលមានកាលវិភាគ ហើយកាលវិភាគនោះ នឹងធ្វើឲ្យអ្នកអាចអនុវត្តនូវសកម្មភាពរបស់អ្នកបាន ។
    - សុបិន្តនឹងក្លាយជាគោលដៅ នៅពេលអ្នកយកសកម្មភាពនោះ ទៅអនុវត្តដើម្បីឈានទៅដល់ការសម្រេចនៃក្តីសុបិន្តនោះ ។
    - គោលដៅ គឺជាក្តីសុបិន្តមួយ ដែលមានកាលកំណត់ច្បាស់លាស់ ។
    - សួរសិក្ខាកាមមើលថាតើពួកគេមានសំណួរអ្វីអំពីគោលដៅ និង ការកំណត់គោលដៅដែរឬទេ ។

- អ្នកសម្របសម្រួល ត្រូវសុំឲ្យសិក្ខាកាមចំណាយពេលពីរបីនាទីក្នុងការគិតរៀងៗខ្លួនអំពីសំណួរមួយចំនួន ដូចខាងក្រោមនេះ ៖
    - តើអ្នកមានគោលដៅ ដែលអ្នកចង់ធ្វើឲ្យវាបានសម្រេចហើយឬនៅ?
    - តើនៅពេលណាទើបអ្នកចង់សម្រេចគោលដៅនោះ?
    - តើអ្នកគិតថា អ្នកត្រូវការអ្វី ដើម្បីធ្វើឲ្យបានសម្រេចគោលបំណងរបស់អ្នក?
    - តើអ្នកត្រូវការជំនួយពីនរណា ដើម្បីជួយអ្នកឲ្យបានសម្រេចដល់គោលដៅរបស់អ្នក?

- ស្រិនបើក្រុម ឬ សិក្ខាកាមម្នាក់ៗ មានការលំបាកក្នុងការគិតអំពីគោលដៅ អ្នកសម្របសម្រួល ត្រូវសុំឲ្យពួកគេបំពេញតាមតារាង ដូចខាងក្រោមនេះ ។

- ដើម្បីជាគំនិត អ្នកត្រូវសរសេរវានៅក្នុងប្រអប់ក្នុងការបញ្ជាក់ថា អ្នកជំនាញខាងអ្វី និង ចូលចិត្តអ្វី អ្នកជំនាញខាងអ្វី និង មិនចូលចិត្តអ្វី អ្នកមិនជំនាញខាងអ្វី និង ចូលចិត្តអ្វី និង អ្នកមិនជំនាញខាង និង មិនចូលចិត្តអ្វី ។

- ជាគោលការណ៍ អ្នកគួរសាកធ្វើ និង កំណត់គោលដៅថា អ្នកជំនាញខាងអ្វីមួយ និង ចូលចូលចិត្តអ្វីមួយ ដោយត្រូវជៀសវាងការខាតពេល ឬ ការចំណាយពេលតិចទៅលើអ្វីមួយ ដែលអ្នកមានជំនាញខាងនោះ ប៉ុន្តែអ្នកមិនចូលចិត្តវាទេ ។

| | ជំនាញខាង | មិនជំនាញខាង |
|---|---|---|
| ចូលចិត្ត | | |
| មិនចូលចិត្ត | | |

- ប្រសិនបើអ្នកមានក្រុមណាមួយ ដែលមិនអាចសរសេរគោលដៅនេះបានទេ ប្រហែលជាអ្នកអាចសរសេរវាបញ្ចូលទៅក្នុងក្រដាសផ្ទាំងធំ ធ្វើវាទាំងអស់គ្នាជាក្រុម ឬ ជួយសិក្ខាកាមក្នុងការបំពេញតារាងនេះ ។

- អ្នកសម្របសម្រួល ត្រូវសុំឲ្យសិក្ខាកាមសញ្ជឹងគិតពីចម្លើយរបស់ពួកគេ ។ តើលំហាត់នេះ បានប្តូរគោលដៅដែលពួកគេចង់សម្រេចវាដែរឬទេ ឬ ធ្វើឲ្យពួកគេគិតអំពីគោលដៅទាំងនោះផ្សេងពីនេះ ?

## ការបញ្ចប់កម្មវិធីធ្វើលំហាត់:

អ្នកសម្របសម្រួល ត្រូវប្រមូលសិក្ខាកាមឲ្យមកជួបជុំគ្នាវិញ និង សួរមើលថាតើសិក្ខាកាមមានចិត្តចង់ចែករំលែកនូវគំនិតយោបល់របស់ខ្លួន ជាមួយនឹងសិក្ខាកាមផ្សេងទៀតក្នុងក្រុមដែរឬទេ ។ អ្នកសម្របសម្រួល អាចសរសេរចំណុច នៃគោលដៅទាំងនោះចូលទៅក្នុងក្រដាសផ្ទាំងធំ ។

## ផែនការសកម្មភាពរបស់ខ្ញុំ

អ្នកសម្របសម្រួល ត្រូវធ្វើយ៉ាងណាឲ្យសិក្ខាកាម បំពេញគោលដៅរបស់ពួកគេចូលទៅក្នុង តារាងផែនការសកម្មភាពរបស់ខ្ញុំ ។

## ចំណុចគន្លឹះសម្រាប់ជាជំនួយស្មារតីក្នុងការបណ្តុះបណ្តាល

អ្នកសម្របសម្រួល ត្រូវជម្រុញឲ្យសិក្ខាកាមហ៊ាននិយាយក្នុងពេលពិភាក្សាគ្នា ។ រំលឹកពួកគេថា នេះជាឱកាសមួយ ដែលយើងអាចជួយគ្នាបាន ហើយក្នុងពេលសិក្សា មិនមាននរណាជាអ្នកមានកំហុសក្នុងការនិយាយស្តីនោះទេ ។

# គ្រាប់អង្កាំ (ពណ៌បៃតង)

នៅចុងបញ្ចប់ នៃមេរៀននេះ ចែកខ្សែឲ្យសិក្ខាកាមម្នាក់មួយខ្សែ និង គ្រាប់អង្កាំពណ៌បៃតង និង សុំឲ្យពួកគេដោតអង្កាំនោះចូលទៅក្នុងខ្សែ ។ អ្នកត្រូវរំលឹកដល់សិក្ខាកាមថា ការដែលមានអង្កាំពណ៌បៃតង មានន័យថា ពួកគេយល់ហើយថាហេតុអ្វីបានជាការមានការងារធ្វើជារឿងសំខាន់សម្រាប់ពួកគេ ហើយវាគឺជាអ្វីដែល ពួកគេបានគិតអំពីអ្វីទៅដែលជា “ក្តីស្រមៃ នៃអាជីព” របស់ពួកគេនោះ ។ លើកទឹកចិត្តឲ្យសិក្ខាកាមធ្វើការជាមួយអ្នកដោយអង្គុយជិតពួកគាត់ក្នុងការដោតគ្រាប់អង្កាំចូលទៅក្នុងខ្សែនោះ ហើយសិក្ខាកាមត្រូវជួយគ្នាទៅវិញទៅមកក្នុងការចងខ្សែអង្កាំនោះ ព័ទ្ធកដៃរបស់ពួកគេ និង ត្រូវពិភាក្សាគ្នាដើម្បីរកឲ្យឃើញថា វាមានន័យអ្វីសម្រាប់ពួកគេ ។



០៣

# ការទទួលបាន ការងារធ្វើ



ការចាក់បញ្ចាំងរឿងវីដេអូបំផុសគំនិត (Inspirational video)
https://www.facebook.com/klahan9cambodia/videos/1061973227273008/

## គោលបំណង៖

- តើហេតុអ្វីបានជាវាសំខាន់សម្រាប់ខ្ញុំ?
- តើមានជម្រើសការងារអ្វីខ្លះសម្រាប់ខ្ញុំ?
- ដើម្បីជួយសិក្ខាកាមឲ្យកំណត់នូវគោលបំណង នៃអាជីពផ្ទាល់ខ្លួនរបស់ពួកគេ



# ៣.១. កន្លែងទទួលព័ត៌មានអំពីការងារ

ពន្យល់សិក្ខាកាមអំពីធនធានផ្សេងៗដែលមាននៅក្នុងខេត្តរបស់ពួកគេ នៅពេលដែលពួកគេស្វែងរកការងារ ។ កិច្ចការនេះ ទាមទារឲ្យអ្នកធ្វើការស្រាវជ្រាវក្នុងនាមជាអ្នកសម្របសម្រួល ដើម្បីផ្សាំខ្លួនអ្នកទៅនឹងគេហទំព័រ **បងភ័ក្រ** (Bongpheak website) និង ស្វែងរកពីស្ថាប័នពាក់ព័ន្ធ ដូចជា **មជ្ឈមណ្ឌលទីភ្នាក់ងារជាតិមុខរបរ និង ការងារ** (NEA) ឬ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) ។ អ្នកអាចសុំឲ្យតំណាងរបស់មជ្ឈមណ្ឌល់ទីភ្នាក់ងារជាតិមុខរបរ និង ការងារ និង អ្នកតំណាងគេហទំព័រ បងភ័ក្រ ដែលឋិតនៅក្នុងខេត្តរបស់អ្នក ដើម្បីមកជួយណែនាំពីសេវាទាំងនោះជូនក្រុមរបស់អ្នកស្តាប់ ។

## ទីភ្នាក់ជាតិមុខរបរ និង ការងារ (NEA)

ទីភ្នាក់ងារជាតិមុខរបរ និង ការងារ គឺជាទីភ្នាក់ងារប្រតិបត្តិការពិសេសរបស់រដ្ឋ ដែលទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មាន និង សេវារកការងារ ប្រកបដោយគុណភាពខ្ពស់ទៅឲ្យអ្នកស្វែងរកការងារធ្វើ និយោជិត និយោជក ស្ថាប័នសិក្សាអប់រំ អ្នកធ្វើគោលនយោបាយ អ្នករៀបចំយុទ្ធសាស្ត្រ និង សាធារណជន ។ ទីភ្នាក់ជាតិមុខរបរ និង ការងារ ប្រមូល រក្សាទុក និង ចែកចាយព័ត៌មានពាក់ព័ន្ធនឹងការងារទៅឲ្យសាធារណជន តាមរយៈ គេហទំព័ររបស់ខ្លួន http://www.nea.gov.kh/kh/ ឬ ចែកចាយព័ត៌មាននោះ តាមទម្រង់ជាលិខិតស្នាមជាមួយនឹងដៃគូរការងារដែលពាក់ព័ន្ធ ។

ប្រសិនបើអ្នកអាចចូលមើលតាមអ៊ិនធើណែតនៅកន្លែងសិក្ខាសាលាបានលៃយ៉ាងណា បង្ហាញសិក្ខាកាមអំពីគេហទំព័ររបស់ទីភ្នាក់ងារជាតិមុខររបរ និង ការងារ និង ប្រាប់ពួកគេឲ្យដឹងផងដែរថា តើគេហទំព័រនេះ អាចផ្តល់ព័ត៌មាន ស្តីពី ការទទួលបានការងារធ្វើដោយរបៀបណា ។ អ្នកត្រូវធ្វើយ៉ាងណា ប្រាប់ពួកគេឲ្យបានដឹងអស់អំពីគេហទំព័រដូចខាងក្រោមនេះ៖

- >> ទំព័រដើម/ការប្រកាសព័ត៌មានអំពីការងារ: http://www.nea.gov.kh/kh/nea/home_page
- >> ការធ្វើផែនការពីមុខរបរ: http://www.nea.gov.kh/kh/plan/nea_plan
- >> ការបណ្តុះបណ្តាល: http://www.nea.gov.kh/kh/training

# សកម្មភាពទី ៥



## ករណីសិក្សា៖ ស្វែងរកការងារមួយ

រយៈពេល នៃការធ្វើលំហាត់: ១៥ នាទី

## គោលបំណង នៃការធ្វើលំហាត់:

- រៀនអំពីទីភ្នាក់ងារជាតិមុខរបរ និង ការងារ
- ចេះពីរបៀបទទួលព័ត៌មាន តាមរយៈ ទីភ្នាក់ងារជាតិមុខរបរ និង ការងារ
- ចេះពីរបៀបចូលមើលវេបសាយ បងភ័ក្រ
- ចេះពីរបៀបចុះឈ្មោះបង្កើតគណនី និង ការប្រើប្រាស់វេបសាយ បងភ័ក្រ

## សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

https://www.facebook.com/klahan9cambodia/videos/837646313039035/

## ដំណើរការ នៃការធ្វើលំហាត់:

- អ្នកសម្របសម្រួល ត្រូវចាក់បញ្ចាំងវីដេអូខ្លីៗពីបណ្ដាញវេបសាយខាងលើឲ្យក្រុមសិក្ខាកាមទាំងអស់ បានមើល (ហើយអាស័យដ្ឋាន នៃបណ្ដាញវេបសាយនេះក៏មាននៅក្នុងឯកសារអប់រំដែរ) ។
- ក្រោយពីបានមើលវីដេអូខ្លីរួចហើយ អ្នកសម្របសម្រួល ត្រូវសួរសិក្ខាកាមនូវសំណួរមួយចំនួន ដូចខាងក្រោម៖
  - តើទីភ្នាក់ងារជាតិមុខរបរ និង ការងារ ជាអ្វី (NEA)?
  - តើមជ្ឈមណ្ឌលរកការងាររបស់ទីភ្នាក់ងារជាតិមុខរបរ និង ការងារ ឋិតនៅកន្លែងណាក្នុងខេត្តរបស់អ្នក?
  - ប្រសិនបើគ្មានមជ្ឈមណ្ឌលទីភ្នាក់ងារជាតិមុខរបរ និង ការងារនៅក្នុងខេត្តរបស់អ្នកទេ តើស្ថាប័នដែលជំនួសឲ្យមជ្ឈមណ្ឌលនេះ នៅកន្លែងណា ដូចជា ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT)?
  - ប្រសិនបើអ្នកមើលឃើញការងារ ដែលគេប្រកាសរើសនៅក្នុងមជ្ឈមណ្ឌលនេះ ហើយជាការងារ ដែលអ្នកពេញចិត្ត តើអ្នកដាក់ពាក្យចូលធ្វើការដោយរបៀបណា?
  - តើអ្នកត្រូវធ្វើការទំនាក់ទំនងជាមួយនរណា ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម ទៀតអំពីទីភ្នាក់ងារជាតិមុខរបរ និង ការងារនេះ?
- ក្រោយពីបានសួរសំណួរនីមួយៗរួចហើយ អ្នកសម្របសម្រួល ត្រូវធ្វើយ៉ាងណាសួរសិក្ខាកាមថាតើពួកគេមានសំណួរអ្វីដែរឬទេ ។
- ប្រសិនបើមាន ពិភាក្សាអំពីសំណួរទាំងនេះជាមួយក្រុមសិក្ខាកាមទាំងមូល ។

## ការបញ្ចប់កម្មវិធីធ្វើលំហាត់:

សុំមើលចំណុចសំខាន់ៗ ដែលអ្នកបានរៀនពីការពិភាក្សានេះ និង ត្រូវដឹងឲ្យបានច្បាស់ថា ក្រុមសិក្ខាកាមទាំងអស់យល់អំពីមេរៀននេះ និង មានជំនឿចិត្តពីរបៀប ដែលពួកគេអាចទទួលបានព័ត៌មានពីការរកការងារធ្វើ តាមរយៈ ទីភ្នាក់ងារជាតិមុខរបរ និង ការងារ (NEA) ឬ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ (MoLTV) ។

## ចំណុចគន្លឹះសម្រាប់ជាជំនួយស្មារតីក្នុងការបណ្តុះបណ្តាល:

ប្រសិនបើអ្នកមានមន្ត្រីតំណាងមកពីទីភ្នាក់ងារជាតិមុខរបរ និង ការងារ សុំឲ្យគាត់ជម្រាបឲ្យបានក្បោះក្បាយ និង ជាក់លាក់អំពីវិធីក្នុងការប្រើប្រាស់សេវារបស់ស្ថាប័ននេះ ។

## គេហទំព័របងភ័ក្រ (បង្កើតឡើងដោយវិទ្យាស្ថានបើកទូលាយ)

បងភ័ក្រ គឺជាគេហទំព័ររបស់ទីភ្នាក់ងារផ្តល់សេវាការងារ ដែលជួយដល់និយោជិត និង និយោជក ។ គេហទំព័រនេះ រៀបចំឡើងជាពិសេសសម្រាប់អ្នកស្វែងរកការងារធ្វើ ដែលមានជំនាញតិចតួចនៅក្នុងឧស្សាហកម្មផ្សេងៗ ដូចជា ការងារសំណង់ រោងចក្រកាត់ដេរ សន្តិសុខ និង សេវាបំរើភ្ញៀវ ។

អ្នកអាចសួរសិក្ខាកាមនូវសំណួរដូចខាងក្រោម អំពី គេហទំព័រ បងភ័ក្រ ដើម្បីបើកការពិភាក្សាពីបញ្ហានេះ៖

- តើមានសិក្ខាកាមណាខ្លះធ្លាប់បានឮអំពីគេហទំព័រ បងភ័ក្រ?
- ប្រសិនបើធ្លាប់បានឮ តើអ្នកអាចប្រាប់ខ្ញុំអំពីប្រភេទ នៃការងារដែលអ្នកបានឃើញគេប្រកាស ជ្រើសរើសបុគ្គលិកបានដែរឬទេ?

ប្រសិនបើអ្នកបានអញ្ជើញអ្នកតំណាងគេហទំព័រ បងភ័ក្រ ឲ្យមកចូលរួម សុំឲ្យគេជួយបើកគេហទំព័រនេះ និង ពន្យល់ឲ្យបានក្បោះក្បាយ អំពី គេហទំព័រ បងភ័ក្រ ហើយសួរថាត្រូវប្រើប្រាស់វាដោយរបៀបណា ។ ប្រសិនបើអ្នកតំណាងពីគេហទំព័រ បងភក្រ មិនមានពេលចូលរួមក្នុងសិក្ខាសាលានេះទេ សុំបន្តការងារ ដូចតទៅនេះ៖

ប្រសិនបើអ្នកអាចប្រើអ៊ិនធើណែតបាន សុំបើកគេហទំព័រ **បងភ័ក្រ** http://bongpheak.com/

អ្នកសម្របសម្រួល ត្រូវពន្យល់ប្រាប់សិក្ខាកាមថា មិត្តភក្តិរបស់អ្នកអាចចុះឈ្មោះឲ្យអ្នកក្នុងគេហទំព័រ បងភ័ក្រ បាន ប្រសិនបើអ្នកមិនមានទូរស័ព្ទsmartphone/មិនអាចប្រើអ៊ិនធើណែតបានទេ អ្នកក៏អាចចុះឈ្មោះតាមរយៈកម្មវិធីនិយាយគ្នានៅក្នុងទូរស័ព្ទ (register through talking into the phone) ។ បន្ទាប់មកទៀត អ្នកអាចទទួលសារហៅចូលជាសម្លេង តាមរយៈ សារជាសម្លេងឆ្លើយតបដោយស្វ័យប្រវត្តិ (via IVR) ក្នុងការប្រាប់អ្នកអំពីការងារសមស្រប និង ពន្យល់អំពីរបៀបដាក់ពាក្យសុំធ្វើការងារ ។ វាជារឿងសំខាន់ណាស់ដែលសិក្ខាកាមត្រូវយល់ឲ្យបានច្បាស់អំពីការប្រើប្រាស់គេហទំព័រនេះ ។

អ្នកអាចជ្រើសរើសយកជម្រើសជាច្រើន តាមរយៈ ព័ត៌មានផ្សេងៗនៅលើគេហទំព័រ ដូចជា ៖

- ឱកាសការងារជាច្រើននៅតាមរោងចក្រ ការងារសំណង់ សេវាផ្សេងៗ សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន សន្តិសុខ ការងារពាណិជ្ជកម្ម
- ករណី នៃប្រវត្តិការងារនិយោជិត
- ឈ្មោះក្រុមហ៊ុន
- ការចុះឈ្មោះ
- ចំណុចគន្លឹះជាជំនួយស្មារតីក្នុងការសម្ភាសន៍
- បទពិសោធន៍ទទួលបានជោគជ័យក្នុងការងារ
- ការទាក់ទងជាមួយគេហទំព័រ បងភ័ក្រ
- របៀបចុះឈ្មោះ ដើម្បីទទួលបានសារជាសម្លេង និង ប្រវត្តិរូបក្នុងការដាក់ពាក្យសុំការងារធ្វើ

ដាក់ឲ្យក្រុមសិក្ខាកាមពិភាក្សាគ្នាជុំវិញចំណុចមួយចំនួន ដូចខាងក្រោមនេះ៖

- ១. តើគេហទំព័រ បងភ័ក្រ ដែលបង្កើតឡើង ដោយវិទ្យាស្ថានបើកទូលាយ (OI) ផ្តល់ព័ត៌មានអំពីអ្វី?
- ២. តើអ្នកអាចចុះឈ្មោះក្នុងគេហទំព័រនេះដោយរបៀបណា?
- ៣. តើអ្នកអាចចុះឈ្មោះក្នុងគេហទំព័រនេះនៅឯណាបាន?
- ៤. តើអ្នកត្រូវធ្វើយ៉ាងណាប្រសិនបើអ្នកចង់ចុះឈ្មោះមិត្តភក្តិ ឬ សមាជិកគ្រួសាររបស់អ្នកនៅក្នុងគេហទំព័រនេះ?
- ៥. តើមានការងារប្រភេទណាខ្លះដែលបានចុះផ្សាយនៅក្នុងគេហទំព័រ បងភ័ក្រ?
- ៦. តើអ្នកគិតថាគេហទំព័រនេះផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់អ្នក?

**ចំណុចគន្លឹះសម្រាប់ជាជំនួយស្មារតីក្នុងការបណ្តុះបណ្តាល**

អ្នកសម្របសម្រួល ត្រូវជួយសិក្ខាកាមឲ្យចុះឈ្មោះក្នុងគេហទំព័រ **បងភ័ក្រ** ។

# សកម្មភាពទី ៦




## សេចក្តីប្រកាសផ្សាយអំពីការងារ

រយៈពេល នៃការធ្វើលំហាត់: ២០ នាទី

## គោលបំណង នៃការធ្វើលំហាត់:

- ដើម្បីឲ្យសិក្ខាកាមចាប់ផ្តើមគិតអំពីព័ត៌មាន ដែលពួកគេត្រូវការពីសេចក្តីប្រកាសផ្សាយអំពីការងារ
- ដើម្បីជួយដល់សិក្ខាកាមឲ្យគិតរកព័ត៌មានអ្វីបន្ថែមទៀត ដែលពួកគេត្រូវការពីសេចក្តីប្រកាសផ្សាយអំពីការងារ និង សួរនូវសំណួរអ្វីផ្សេងទៀត ដែលពួកគេត្រូវការសួររកពីការប្រកាសផ្សាយនីមួយៗនោះ

## សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

សេចក្តីប្រកាសផ្សាយអំពីការងារពិតប្រាកដមួយចំនួននៅ ទីភ្នាក់ងារជាតិមុខរបរ និង វេបសាយ បងភ័ក្រ នៅក្នុងតំបន់មួយចំនួន ។

ក្រដាស

ហ្វឺតសរសេរ

## ដំណើរការ នៃការធ្វើលំហាត់:

- អ្នកសម្របសម្រួល ត្រូវពន្យល់ក្រុមសិក្ខាកាមទាំងអស់ឲ្យបានជ្រាបថា សកម្មភាពនេះ ត្រូវបានរៀបចំឡើង ដើម្បីធ្វើឲ្យអ្នកគិតអំពីព័ត៌មាន ដែលអ្នកត្រូវការពីសេចក្តីប្រកាសផ្សាយអំពីការងារ និង ព័ត៌មានអ្វីៗផ្សេងទៀត ដែលអ្នកគួរសួររក នៅពេលអ្នកឃើញការប្រកាសផ្សាយអំពីការងារ ។
- អ្នកសម្របសម្រួល ត្រូវបែងចែកក្រុមឲ្យទៅជាក្រុមតូចៗ និង ក្នុងមួយក្រុម ត្រូវមានគ្នាចំនួនពីរនាក់ ។
- អ្នកសម្របសម្រួល ត្រូវចែកសេចក្តីប្រកាសផ្សាយអំពីការងារនេះ ដែលបានមកពីប្រភពនានា ទៅឲ្យក្រុមតូចនីមួយៗ ហើយពួកគេទើបតែបានរៀនរួចថ្មីៗអំពី (ទីភ្នាក់ងារជាតិមុខរបរ និង ការងារ និង វេបសាយបងភ័ក្រ) ។
- អ្នកសម្របសម្រួល ត្រូវសុំឲ្យក្រុមសិក្ខាកាមនីមួយៗបង្ហាញនូវបញ្ជីសំណួរ ដែលពួកគេបានសួរអំពីអ្នកជ្រើសរើសការងារ ផ្អែកលើសេចក្តីប្រកាសផ្សាយអំពីការងារ ដែលពួកគេទើបបានទទួល ។
- អ្នកសម្របសម្រួល ត្រូវប្រាប់សិក្ខាកាមថា ពួកគេមានពេល ១០ នាទី ក្នុងការពិភាក្សា និង រៀបចំបង្កើតសំណួរ ។
- អ្នកសម្របសម្រួល ត្រូវសុំឲ្យសិក្ខាកាមក្រុមតូចនីមួយៗសរសេរសំណួរទាំងនោះនៅលើផ្ទាំងក្រដាស
- អ្នកសម្របសម្រួល ត្រូវជម្រុញឲ្យពួកគេសរសេរសំណួរទាំងនេះនៅលើផ្ទាំងក្រដាស ។

## ការបញ្ចប់កម្មវិធីធ្វើលំហាត់:

- អ្នកសម្របសម្រួល ត្រូវហៅក្រុមសិក្ខាកាមឲ្យចូលមកជុំគ្នាវិញ ហើយសុំឲ្យពួកគេចែករំលែកនូវសំណួរទាំងអស់នោះជាមួយនឹងសិក្ខាកាមក្រុមធំ ។
- បន្ទាប់ពីក្រុមនីមួយៗបានចែករំលែកនូវសំណួររបស់ពួកគេហើយអ្នកសម្របសម្រួល ត្រូវសុំឲ្យសិក្ខាកាមមើលសំណួរទាំងអស់ខាងក្រោមនេះថាតើមានសំណួរណាខ្លះ ដែលពួកគេគួរសួរ ៖
  - តើសេចក្តីប្រកាសផ្សាយអំពីការងារនេះ ត្រូវផុតកំណត់នៅថ្ងៃណា?
  - តើការងារនេះ ត្រូវធ្វើនៅកន្លែងណា?
  - តើការងារនេះ មានប្រាក់បៀវត្សរ៍ដែរឬទេ?
  - តើការងារនេះ ត្រូវការអ្នកមានបទពិសោធន៍ដែរឬទេ?
  - តើជំនាញអ្វីដែលអ្នកត្រូវការសម្រាប់ការងារនេះ?
  - តើអ្នកអាចដាក់ពាក្យសុំធ្វើការងារនេះដោយរបៀបណា?
  - តើការសម្ភាសន៍ចាប់ផ្តើមនៅពេលណា និង នៅកន្លែងណា?

អ្នកសម្របសម្រួល សួរថា តើមានសំណួរប៉ុន្មានដែលក្រុមនីមួយបានធ្វើ? តើពួកគេធ្វើមាន សំណួរអ្វីផ្សេងទៀតដែរឬទេ? សំណួរដែលយើងបានសួរ អត់មានសំណួរណាមួយជាសំណួរ ដែលខុស ឬ ត្រូវនោះទេ ។ អ្នកសម្របសម្រួល គួរលើកទឹកចិត្តឲ្យសិក្ខាកាមឲ្យផ្តើមសួរនូវសំណួរទាំងនេះ ។

### ចំណុចគន្លឹះសម្រាប់ជាជំនួយស្មារតីក្នុងការបណ្តុះបណ្តាល

ប្រសិនបើសិក្ខាកាមមិនអាចអានអក្សរបានទេ ក្នុងនាមជាអ្នកសម្របសម្រួល ត្រូវដាក់ឲ្យពួកគេធ្វើការជាក្រុម ហើយអ្នកអាចអានសេចក្តីប្រកាសផ្សាយអំពីការងារឲ្យពួកគេស្តាប់ឲ្យបានឮៗ ។

# ៣.២. ត្រូវមានសុវត្ថិភាពនៅពេលស្វែងរកការងារធ្វើ

អ្វីៗដែលយើងធ្វើ រួមទាំងការធ្វើតាមក្តីស្រមៃរបស់យើងក៏អាចនាំឲ្យជួបហានិភ័យខ្លះដែរ ។ ពេលខ្លះ ការប្រថុយប្រថានអាចនាំយើងឲ្យធ្លាក់ទៅក្នុងស្ថានភាពគ្រោះថ្នាក់ ។ ឧទាហរណ៍ ក្មេងស្រីម្នាក់ស្រមៃចង់មានជីវិតល្អប្រសើរ ហើយនាងប្រថុយធ្វើដំណើរទៅឆ្ងាយជាមួយនឹងបុរសម្នាក់ ដែលបាននិយាយថា ខ្លួននឹងធ្វើឲ្យក្តីស្រមៃរបស់នាងក្លាយជាការពិត ។

មានរឿងជាច្រើនដែលយើងអាចធ្វើបានក្នុងការកាត់បន្ថយនូវហានិភ័យ និង រស់នៅដោយមានសុវត្ថិភាព ។ រឿងដែលសំខាន់ គឺត្រូវមានលទ្ធភាពអាចកំណត់ឲ្យឃើញថា នៅពេលណាអ្នកអាចនឹងជួបហានិភ័យ តើវាជាការងារសមស្របដែរឬទេ និង ត្រូវដឹងថាតើឱកាសដែលមានសម្រាប់ខ្លួនជាឱកាសមួយពិតប្រាកដដែរឬទេ ។ វគ្គនេះ និង វគ្គបន្ទាប់មកទៀត នឹងមានពន្យល់អំពីបញ្ហាទាំងនេះ រួចទុកឲ្យសិក្ខាកាមអនុវត្តផ្ទាល់ក្នុងការដោះស្រាយបញ្ហា ដែលពួកគេ មិត្តភក្តិ និង សមាជិកគ្រួសាររបស់ពួកគេ អាចប្រឈមនៅពេលដែលពួកគេកំពុងតែរកការងារធ្វើ ។

## សកម្មភាពទី ៧



**ករណីសិក្សា៖ ចំណាកស្រុក**

រយៈពេល នៃការធ្វើលំហាត់: **២០ នាទី**

### គោលបំណង នៃការធ្វើលំហាត់:

- អ្នកសម្របសម្រួល ត្រូវពន្យល់ប្រាប់សិក្ខាកាមថា អ្វីជាការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពអ្នក
- សម្របសម្រួល ត្រូវជម្រុញឲ្យសិក្ខាកាមគិតជាបឋមអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្នុងពេល នៃការស្វែងរកការងារធ្វើ
- អ្នកសម្របសម្រួល ត្រូវជួយសិក្ខាកាមឲ្យមានជំនឿចិត្តក្នុងការកំណត់សម្គាល់នូវស្ថានភាព ដែលអាចនឹងមានហានិភ័យ

### សម្ភារៈសិក្សា (រួមមាន ការប្រើសប្រាស់ខ្លឹមសារ នៃមេរៀន)

https://www.facebook.com/klahan9cambodia/videos/1084219178381746/

## ដំណើការ នៃការធ្វើលំហាត់:

- អ្នកសម្របសម្រួល ត្រូវចាក់បញ្ចាំងរឿងវីដេអូខ្លីៗពីបណ្ដាញវេបសាយខាងលើឲ្យក្រុមសិក្ខាកាម ទាំងអស់បានមើល ។
- អ្នកសម្របសម្រួល ត្រូវពិភាក្សាអំពីចំណុចខាងក្រោមនេះជាមួយនឹងក្រុមសិក្ខាកាមទាំងមូល ត្រូវទុកពេលឲ្យបានគ្រប់គ្រាន់សម្រាប់សំណួរនីមួយៗ ដើម្បីឲ្យសិក្ខាកាម អាចសួរសំណួរទាំងអស់នោះបាន៖

  - ការធ្វើចំណាកស្រុក គឺជាដំណើរការ នៃការចាកចេញពីផ្ទះក្នុងគោលបំណងទៅរកការងារធ្វើ ឬ ទៅសិក្សា ។
  - មានមូលហេតុជាច្រើនដែលត្រូវសួរថាហេតុអ្វីបានជាអ្នកចង់រកការងារធ្វើ ដែលការងារនោះ មិនមែនជាការងារនៅក្នុងប្រទេសកម្ពុជា ។ វាជាការលំបាកណាស់ក្នុងការស្វែងរកការងារនៅកន្លែងដែលអ្នកកំពុងរស់នៅ ឬ ជាការងារដែលអន្ទងចិត្តអ្នកឲ្យមើលឃើញថាជាការងារ ដែលគួរឲ្យរំភើបរីករាយ ។ វាអាចជាការងារមានប្រាក់ឈ្នួលខ្ពស់ ប៉ុន្តែវាក៏ជាការងារ ដែលមានហានិភ័យច្រើនដែរ ។ ប្រសិន បើអ្នកពិតជាដាក់ពាក្យ និង សម្រេចទទួលយកការងារនៅក្រៅប្រទេសមែន អ្នកត្រូវតែមានការត្រៀមខ្លួនឲ្យបានល្អ ។ ការត្រៀមខ្លួនទាំងនេះ រួមមាន ការទំនាក់ទំនងជាមួយមិត្តភក្ដិ ឬ អង្គការមិនមែនរដ្ឋាភិបាល ដែលនៅទីនោះ ប្រាប់ឪពុកម្ដាយ ឬ មិត្តភក្ដិឲ្យបានដឹងថា អ្នកមានគំរោងនឹងទាក់ទងជាមួយពួកគេនៅពេលដែលត្រូវឃ្លាតឆ្ងាយពីស្រុកភូមិ ដោយត្រូវយកទៅជាមួយនូវ អត្តសញ្ញាណប័ណ្ណ និង ថតចម្លងអត្តសញ្ញាណប័ណ្ណទុកមួយចំនួននៅនឹងគ្រួសាររបស់អ្នក ដែលនៅផ្ទះ ។
  - យុវជនអាចនឹងខ្វះព័ត៌មាន និង ចំណេះដឹងអំពីការធ្វើចំណាកស្រុក ដូចជា តើត្រូវធ្វើផែនការឲ្យមានប្រសិទ្ធិភាពដោយរបៀបណា តើផ្ដល់ឲ្យការងារប្រភេទណា តើការធ្វើចំណាកស្រុករបៀបណា ដើម្បីឲ្យមានសុវត្ថិភាព តើត្រូវទៅរកព័ត៌មានពីកន្លែងណា ហើយតើត្រូវចរចារអំពីសេចក្ដីសម្រេចនេះជាមួយ នឹងដៃគូរសំខាន់ៗដោយរបៀបណា ដូចជា ឪពុកម្ដាយរបស់ពួកគេ ។
  - ការចង់រកបានលុយ ដើម្បីជួយគ្រួសាររបស់យើង ឬ សិក្សានៅសាកលវិទ្យាល័យ ឬ ទិញទូរស័ព្ទថ្មីអាចទំនងជាហេតុផលល្អម្យ៉ាង ដែលរឿងទាំងអស់នេះ អាចនាំឲ្យ មានគ្រោះថ្នាក់ ។
  - ជនជួញដូរមនុស្ស អាចជាជនណាមួយក៏បាន ជននោះអាចជាបុរស ស្ត្រី ជនចម្លែក សមាជិកគ្រួសារ ឬ មិត្តភក្ដិ ។

### ការបញ្ចប់កម្មវិធីធ្វើលំហាត់:

អ្នកសម្របសម្រួល ត្រូវសុំឲ្យសិក្ខាកាមផ្ដល់និយមន័យ នៃពាក្យថា ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមគំនិតរបស់ពួកគេផ្ទាល់ ។ ពិភាក្សាគ្នាមើលថាតើពួកគេអាចមានស្ថានភាពអ្វីពាក់ព័ន្ធនឹងស្ថានភាពដូចក្នុងរឿងវីដេអូខ្លីដែរឬទេ ឬ ក៏ពួកគេស្គាល់មិត្តភក្តិ ឬ សមាជិកគ្រួសារណា ដែលឋិតក្នុងស្ថានភាពមានហានិភ័យ ដូចនៅក្នុងសាច់រឿងនេះ ។

# សកម្មភាពទី ៨

## ការស្វែងរកការងារ ដែលមានសុវត្ថិភាព

រយៈពេល នៃការធ្វើលំហាត់: ៣០ នាទី

## គោលបំណង នៃការធ្វើលំហាត់:

- ដើម្បីឲ្យសិក្ខាកាមយល់អំពីការងារ ដែលងាយរងគ្រោះនោះមានន័យដូចម្ដេច
- ដើម្បីឲ្យសិក្ខាកាមដឹងពីរបៀបការពារខ្លួនពីស្ថានភាព នៅពេលដែលពួកគេមានការងារ ដែលងាយរងគ្រោះ

## សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

- អត្ថបទ នៃសាច់រឿងអ៊ុតផ្លាស្ទិកចំនួន ៥ សន្លឹក សម្រាប់សកម្មភាពទី៨
- ផ្ទាំងក្រដាសផ្ទាំងធំ នៃគោលការណ៍ណែនាំ

## ដំណើរការ នៃការធ្វើលំហាត់:

- ពេលចាប់ផ្ដើមធ្វើលំហាត់នេះ អ្នកសម្របសម្រួល ត្រូវពន្យល់ប្រាប់សិក្ខាកាមថា នៅក្នុងសកម្មភាពនេះ សិក្ខាកាមនឹងធ្វើការដើរតួសំដែងតាមអត្ថបទ នៃសាច់រឿង៖
- សកម្មភាពនេះ នឹងធ្វើឲ្យសិក្ខាកាមគិតអំពីរបៀប ដែលពួកគេអាចធ្វើយ៉ាងណាឲ្យពួកគេ និង មិត្តភក្តិរបស់ពួកគេទទួលបានការការពារនៅពេលពួកគេទទួលបានការងារ ឬ ទំនងជាទទួលបានការងារដែលងាយរងគ្រោះ ។
- អ្នកសម្របសម្រួល ត្រូវបែងចែកសិក្ខាកាមចំនួន ៥ ក្រុម ហើយដែលក្រុមនីមួយៗត្រូវមានសមាជិកក្រុមស្មើៗគ្នា (ក្នុងមួយក្រុម ត្រូវមានសមាជិកយ៉ាងតិចចំនួន ៤ នាក់) ។
- អ្នកសម្របសម្រួល ត្រូវចែកអត្ថបទ នៃសាច់រឿងនោះឲ្យក្រុមនីមួយៗ
- អ្នកសម្របសម្រួល ត្រូវពន្យល់ប្រាប់ក្រុមសិក្ខាកាមទាំងអស់ឲ្យបានដឹងក្នុងពេលតែមួយថា ពួកគេត្រូវការធ្វើការរួមគ្នា ដើម្បីបង្កើតបានជាសាច់រឿងយកមកសំដែង និង ធ្វើការពិភាក្សាលើអត្ថបទ នៃសាច់រឿងនោះ ។
- អ្នកសម្របសម្រួល ត្រូវប្រាប់សិក្ខាកាមថា ពួកគេមានរយៈពេល ១០ នាទី ក្នុងការរៀបចំអត្ថបទ នៃសាច់រឿងរបស់ពួកគេ ។
- អ្នកសម្របសម្រួល ត្រូវពន្យល់ប្រាប់សិក្ខាកាមថា នៅពេលរៀបចំការដើរតួសំដែង គោលការណ៍ណែនាំខាងក្រោមនេះ មានសារៈសំខាន់ណាស់ (អ្នកសម្របសម្រួល ត្រូវសរសេរគោលការណ៍ណែនាំនេះនៅលើ ផ្ទាំងក្រដាស់ហ្វ៊ីបឆាតមុននឹងចាប់ផ្ដើមវគ្គបណ្ដុះបណ្ដាល និង បំពាក់ ឬ ព្យួរវានៅកន្លែងណា ដែលសិក្ខាកាមអាចមើល ឃើញគ្រប់គ្នា)៖

  - អ្នកសម្របសម្រួលត្រូវមើលឲ្យបានប្រាកដថា មិនមានសិក្ខាកាមមួយ ត្រូវសិក្ខាកាមដទៃក្នុងអង្គសិក្ខាសាលាធ្វើបាប ឬ បង្ខំឲ្យឡើងសំដែងក្នុងសាច់រឿងនេះទេ ។ យុវជនខ្លះអាចមានអារម្មណ៍ មិនស្រួលក្នុងចិត្តនឹងឡើងសំដែងទេ ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើសមាជិកក្រុមមានអារម្មណ៍ខ្មាស់អៀន ឬ មានការស្ទាក់ស្ទើរបន្តិចបន្តួច អ្នកសម្របសម្រួល គួរលើកទឹកចិត្ត សិក្ខាកាមនោះឲ្យឡើងសំដែងទៅ ។ អ្នកសម្របសម្រួល ត្រូវអញ្ជើញគាត់ឡើងសំដែងដោយទន់ភ្លន់ និង គ្មានការបង្ខំ ។

- អ្នកសម្របសម្រួល ត្រូវសុំឲ្យសិក្ខាកាមជាបុរសសំដែងជាតួស្រ្តី ហើយសិក្ខាកាមជាស្រ្តីវិញ សំដែងជាតួបុរស ម្នាក់ម្តងៗ ឲ្យបានគ្រប់ៗគ្នា ដើម្បីឲ្យពួកគេមានឱកាសសំដែងនៅក្នុងស្ថានភាព ដែលប្រឈម នឹងសមាជិកក្រុម មានភេទផ្ទុយគ្នា ។

- អ្នកសម្របសម្រួល ត្រូវអញ្ជើញក្រុមទាំងអស់ឲ្យមកជុំគ្នាវិញ ។
- អ្នកសម្របសម្រួល ត្រូវផ្តល់ឱកាសដល់ក្រុមនីមួយៗក្នុងការ "ដើរតួ" ជាអ្នកសំដែងតាមអត្ថបទ នៃសាច់រឿងនោះ ។
- អ្នកសម្របសម្រួល ត្រូវសុំឲ្យសិក្ខាកាមពិភាក្សាលើអត្ថបទនីមួយៗក្នុងក្រុម និង សំដែងតាមអត្ថបទនៃសាច់រឿងនោះ ដោយប្រើព័ត៌មាន ដែលក្នុងក្រុមទទួលបានពីរឿងវីដេអូកម្មវិធីក្លាហាន9 ។ អ្នកសម្របសម្រួល ត្រូវពិចារណាមើលថាតើស្ថានភាពនេះ ត្រូវបានដោះស្រាយតាមវិធីសមស្រប និង ជាវិធី ដែលជួយយើងដែរឬទេ ហើយថាតើអ្នកដើរតួក្នុងសាច់រឿងនោះ មានសុវត្ថិភាពដែរឬទេ ។

ខាងក្រោមនេះ គឺជាចំណុចសំខាន់ៗមួយចំនួន ដែលអ្នកសម្របសម្រួល ត្រូវមើល ឲ្យបានសព្វ និង ត្រូវធ្វើតាមឡើងវិញ នៅពេលពិភាក្សាអំពីអត្ថបទ នៃសាច់រឿងនេះ ។ ត្រូវប្រាកដថា អ្នកបានមើលចំណុចទាំងអស់នេះ ជាមួយក្រុមសិក្ខាកាម ដោយធ្វើយ៉ាងណាឲ្យពួកគេបានយល់ និង បានពិភាក្សាលើចំណុចនីមួយៗនេះ៖

- មានជំហានងាយៗមួយចំនួន ដែលអ្នកអាចធ្វើតាមបាន មុនពេលអ្នកធ្វើចំណាកស្រុក ដើម្បីការពារខ្លួនអ្នក ។ មុនពេលអ្នកទៅរកលេខសម្រាប់ទំនាក់ទំនងមនុស្ស ដែលគួរឲ្យទុកចិត្តមួយចំនួននៅទីនោះ ដូចជាមិត្តភក្តិដែលធ្វើការនៅអង្គការក្រៅរដ្ឋាភិបាល ។ ត្រូវចាំលេខទំនាក់ទំនងនេះ ក្នុងករណីអ្នក បាត់ទូរស័ព្ទរបស់អ្នក ។
- ត្រូវមានផែនការក្នុងការទំនាក់ទំនងជាមួយមិត្តភក្តិ និង សមាជិកគ្រួសាររបស់អ្នកនៅពេល ដែលអ្នកត្រូវចាកចេញ ។
- អ្នកសម្របស្រួល ត្រូវប្រាប់សិក្ខាកាមឲ្យលៃយ៉ាងណាយកអត្តសញ្ញាណប័ណ្ណរបស់ខ្លួនទៅជាមួយផង ប៉ុន្តែក៏ត្រូវថតចម្លងចំនួនប៉ុន្មានច្បាប់ទុកនៅផ្ទះផងដែរ ។ មិនត្រូវប្រគល់អត្តសញ្ញាណប័ណ្ណ ទៅឲ្យជនណាមួយដាច់ខាត លើកលែងតែជននោះ ជាមន្ត្រីរាជការ ឬ មន្ត្រីរដ្ឋការ ។ ប្រសិនបើមាននរណាមួយ ចង់បាន ឬ ត្រូវព័ត៌មាន ឬ ឯកសារអ្វីពីអ្នក សុំប្រាប់ពួកគេទៅវិញថា អ្នកនឹងផ្តល់ឲ្យពួកគេបានត្រឹមតែ ឯកសារ ជាច្បាប់ចម្លងទេ ។
- ប្រសិនបើមានជនណាមួយជួយអ្នករៀបចំការធ្វើដំណើរ កុំភ្លេចសុំឈ្មោះ និង នាមត្រកូល ព្រមទាំងលេខទំនាក់ទំនងរបស់គេផង ហើយត្រូវផ្តល់ព័ត៌មាននេះដល់ជនណាមួយ ដែលអ្នកមានការជឿទុកចិត្ត ។ ការបង់ថ្លៃឈ្នួលមេខ្យល់ក្នុងការជូនអ្នកឆ្លងដែន ដោយគ្មានលិខិតធ្វើដំណើរ ទំនងជាមានតម្លៃថោកមែន ប៉ុន្តែអ្នកប្រឈមនឹងការចាប់ខ្លួនដាក់ពន្ធនាគារ និង ក្រោយមក ត្រូវគេបណ្តេញចេញ ឬ បញ្ជូនមកស្រុកកំណើតវិញ ។
- ប្រសិនបើអ្នកធ្វើចំណាកស្រុករកការងារធ្វើ សំខាន់ អ្នកត្រូវចំណាយពេលទៅធ្វើលិខិតឆ្លងដែន សុំទិដ្ឋាការ និង សុំប័ណ្ណអនុញ្ញាតធ្វើការងារ ។

## ការបញ្ចប់កម្មវិធីធ្វើលំហាត់:

ចំណុចទាំងអស់ខាងលើ មានសារសំខាន់ណាស់ និង អាចសរសេរវាបញ្ចូលទៅក្នុងក្តាស់ហ្លីបឆាត សម្រាប់សិក្ខាកាម ទុកជាការក្រើនរំលឹកដល់ពួកគេ ។ ពួកគេក៏អាចពិភាក្សាជាមួយនឹងមិត្តភក្តិ និង សមាជិកគ្រួសាររបស់ពួកគេអំពីចំណុចទាំងនោះ ។

## គន្លឹះសម្រាប់ជាជំនួយស្មារតីដល់គ្រូឧទ្ទេស:

អ្នកសម្របសម្រួល ត្រូវធ្វើបទបង្ហាញករណីសិក្សាពីការធ្វើចំណាកស្រុកឆ្លងដែនអន្តរជាតិ តាមរយៈការយកអត្ថបទចេញពីសារព័ត៌មាន ឬ ករណីសិក្សាតែម្តង ដើម្បីសិក្ខាកាម អាន និង ពិភាក្សាគ្នាក្នុងក្រុមតូចៗ ។

អ្នកសម្របសម្របសម្រួល ត្រូវសុំឲ្យអ្នកជំនាញជាតិនិយាយក្នុងនាមជាវាគ្មិន (ដូចជា មន្ត្រីនគរបាល មេធាវី តំណាងអង្គការក្រៅរដ្ឋាភិបាលប្រឆាំងអំពើជួញដូរមនុស្ស ។ល។) អ្នកជំនាញជាតិ អាចនិយាយប្រាប់សិក្ខាកាមអំពីប្រភេទ នៃការកេងប្រវ័ញ្ច និង ការជួញដូរនៅក្នុងសហគមន៍របស់អ្នក ។

## អត្ថបទ នៃសាច់រឿងទាំងប្រាំសម្រាប់សកម្មភាពទី៨៖

### អត្ថបទ នៃសាច់រឿងទី ១

មិត្តល្អម្នាក់សម្រេចចិត្តចាកចេញពីស្រុកភូមិទៅធ្វើការនៅប្រទេសថៃ ។ ឪពុកម្តាយរបស់នាង ត្រូវការលុយ និង មានបុរសម្នាក់សន្យាថានឹងយកនាងទៅធ្វើការនៅទីនោះដោយសុំឲ្យបង់លុយមុនចំនួន ៥០០ ដុល្លារអាមេរិក សម្រាប់ចំណាយលើការធ្វើដំណើររបស់នាង ។ អ្នកជិតខាងរបស់នាងប្រាប់នាងថា វាជារឿងគួរឲ្យត្រេកត្រអាលខ្លាំងណាស់ ក្នុងការបានទៅធ្វើការនៅក្រៅប្រទេស ហើយដោយសារតែការងារនេះនាងអាចដោះស្រាយវិបត្តិថវិកាឲ្យគ្រួសារបាន ។ ប្រសិនបើអ្នកជារូបនាងនេះវិញ តើអ្នកគួរធ្វើយ៉ាងណា? តើអ្នកគួរឲ្យយោបល់អ្វីខ្លះដល់នាង?

**សិក្ខាកាមម្នាក់ អាចដើរតួជាក្មេងស្រី ហើយសិក្ខាកាមម្នាក់ទៀត ដើរតួជាមិត្តរបស់នាង ។**

### អត្ថបទ នៃសាច់រឿងទី ២

សិក្ខាកាមម្នាក់ ដើរតួជាយុវតី និង សិក្ខាកាមម្នាក់ទៀង ដើរតួជាមិត្តរបស់នាង ។សេចក្តីត្រូវការក្នុងការ រកលុយបង់ថ្លៃសាលាឲ្យកូនរបស់គាត់ ។ បុរសមកពីជនបទម្នាក់ ត្រូវគេនាំឲ្យទៅធ្វើការជាកម្មករនេសាទនៅប្រទេសថៃ ។ មេខ្យល់បានដកយក និង រក្សាទុកលិខិតឆ្លងដែនរបស់គាត់ ។ បុរសនោះ ធ្វើការ ២០ ម៉ោងក្នុងមួយថ្ងៃ ។ គេឲ្យថ្នាំគាត់លេបមួយគ្រាប់ជារៀងរាល់ថ្ងៃ ដើម្បីឲ្យគាត់អាចធ្វើការបានពេញមួយថ្ងៃ ដោយមិនចាំបាច់ដេកពួន ។ ក្នុងមួយថ្ងៃ គាត់អាចទទួលទានអាហារបានតែមួយពេលប៉ុណ្ណោះ ។ គាត់ធ្វើការលើទូកនេសាទចំនួន ២ សប្តាហ៍ជាប់ៗគ្នា ក្នុងពេលចុះទូកម្តងៗ ។ ប្រាក់ចំណូល ដែលគាត់ត្រូវទទួលបានទាំងអស់ ត្រូវថៅកែរបស់គាត់ជាអ្នករក្សាទុក ។

អ្នកសម្របសម្រួល ត្រូវឲ្យពួកគេគិតអំពីសំណួរទាំងអស់ជាក្រុម ដោយបុរសនោះ គួរសួរអ្នកជ្រើសរើសខ្លួនឲ្យបញ្ជាក់ថា តើឱកាសការងារនេះជាការងារពិតដែរឬទេ មុននឹងប្រគល់លិខិតឆ្លងដែន របស់ខ្លួនទៅឲ្យគេ ។ ក្រោយមក ទុកពេលឲ្យក្រុមគិតអំពីសំណួរ ដែលប្រពន្ធរបស់គាត់ គួរតែសួរគាត់ និង ពួកគេគួរដាក់ចេញនូវវិធីសាស្ត្រក្នុងការធ្វើយ៉ាងណាឲ្យវិធីសាស្ត្រនោះ រក្សាបាននូវសុវត្ថិភាព ។

បន្ទាប់ពីបានរៀបចំគំនិតជាគ្រោងឆ្អឹងរួចហើយ សិក្ខាកាមម្នាក់ចេញមកដើរតួជាបុរសនោះ ចំណែកសិក្ខាកាមម្នាក់ទៀត ដើរតួជាប្រពន្ធ ហើយពួកគេអាចនិយាយសារសងគ្នាអំពីថាតើពួកគេ គួររៀបផែនការរបៀបណា ដើម្បីបញ្ជាក់ថា ក្នុងឱកាសបែបនេះ មានសុវត្ថិភាព ។

## អត្ថបទ នៃសាច់រឿងទី ៣

គេបានដឹកស្ត្រីម្នាក់មកពីជនបទ ឲ្យទៅធ្វើការជាកម្មការិនីរោងចក្រនៅរាជធានី ។ ក្នុងកំឡុងពេលដែលនាងរស់នៅក្នុងរាជធានី នាងស្នាក់នៅក្នុងបន្ទប់រួមគ្នាជាមួយនឹងស្ត្រី ៥ នាក់ផ្សេងទៀត ដែលមកពីខេត្តផ្សេងៗគ្នា ហើយពួកគេតែងតែចែករំលែកម្ហូបអាហារ និង ប្រើប្រាស់សម្លៀកបំពាក់រួមគ្នា ។ នាងមិនសប្បាយចិត្តនឹងលក្ខខ័ណ្ឌការងាររបស់នាងទេ ហើយនាងមានអារម្មណ៍ថា លក្ខខ័ណ្ឌទាំងនោះ មិនយុត្តិធម៌ឡើយ ។ នាងចង់និយាយជាមួយថៅកែរបស់នាងពីបញ្ហានេះ ។

សុំឲ្យសិក្ខាកាមគិតជាក្រុមអំពីវិធី ដែលស្ត្រីនោះអាចចូលជួបថៅកែរបស់នាង និយាយអំពីលក្ខខ័ណ្ឌការងារ ដែលមិនយុត្តិធម៌នោះ ។ បន្ទាប់មកទៀត សុំឲ្យសិក្ខាកាមពិចារណាជាក្រុមថាតើមិត្តរបស់នាង អាចជួយធ្វើអ្វីបាន មុននឹងនាងធ្វើចំណាកស្រុកទៅរកការងារធ្វើ?

## អត្ថបទ នៃសាច់រឿងទី ៤

បុរសវ័យក្មេងម្នាក់សង្ឃឹមថានឹងរកការងារបានធ្វើជាកម្មករសំណង់នៅប្រទេសថៃ ។ អ្នកជិតខាងរបស់គាត់ជាមេខ្យល់ បានចំណាយពេលអស់រយៈពេលបីថ្ងៃក្នុងការបញ្ចុះបញ្ចូលគាត់ឲ្យទៅខ្ចីលុយពីធនាគារ ដើម្បីធ្វើចំណាកស្រុកជាមួយមេខ្យល់នោះ ហើយមេខ្យល់នោះ បានប្រាប់បុរសនោះថា ថៅកែរបស់គាត់ ត្រូវការកម្មករបន្ថែមទៀត ឲ្យទៅធ្វើការនៅក្នុងចំការរបស់គាត់ក្នុងពេលនេះ ។ គាត់ដឹងថា ថ្លៃធ្វើដំណើរទៅប្រទេសថៃ នឹងត្រូវចំណាយចំនួន ៣,០០០ បាត ប៉ុន្តែគេបានប្រាប់គាត់ថា គាត់នឹងរកចំណូលបានវិញចំនួន ៥០០ បាត ក្នុងមួយថ្ងៃ បូករួមនឹងឈ្នួលធ្វើការថែមម៉ោងទៀត ។ គាត់គិតថា វាពិតជារឿងល្អណាស់ប្រសិនបើបែបនេះមែន ហើយគាត់ចង់ទៅឲ្យបានកាន់តែបានឆាប់កាន់តែល្អ ។

សុំឲ្យសិក្ខាកាមធ្វើការពិចារណាជាក្រុមថាតើសមាជិកគ្រួសាររបស់ពួកគាត់គួរឲ្យដំបូន្មានអ្វីខ្លះដល់គាត់? បន្ទាប់មកទៀត ពិចារណាថាមានគុណសម្បត្តិ និង គុណវិបត្តិអ្វីខ្លះ ប្រសិនបើបុរសវ័យក្មេងរូបនេះ សម្រេចចិត្តទៅខ្ចីលុយគេ និង ព្រមទទួលយកការងារនេះ ។

## អត្ថបទ នៃសាច់រឿងទី ៥

ក្មេងស្រីនៅតាមព្រំដែនខ្មែរថៃម្នាក់ឆ្លងកាត់ព្រំដែនទៅធ្វើការនៅប្រទេសថៃជារៀងរាល់ថ្ងៃ ។ នាងក្រោកឡើងពីពេលព្រឹកព្រលឹម ដើម្បីធ្វើដំណើរទៅប្រទេសថៃ និង ត្រឡប់មកវិញនៅពេលយប់ជ្រៅ ។ នាងជាជំនួយការលក់ដូរឥវ៉ាន់ក្នុងហាង ហើយនាងមានអារម្មណ៍ថា ពេលវេលា ដែលនាងប្រើប្រាស់ក្នុងការធ្វើដំណើរទៅទីនោះ និង ត្រឡប់មកវិញ ហើយបើធៀបនឹងអ្វីជាប្រាក់ចំណូល ដែលនាងរកបានមកនោះគឺមិនសមគ្នាទេ ។ ថ្ងៃមួយ នាងបានសុំថៅកែរបស់នាងឲ្យតម្លើងប្រាក់ឈ្នួលបន្តិច ប៉ុន្តែថៅកែនោះមិនត្រឹមតែបដិសេធមិនតម្លើងប្រាក់ឈ្នួលឲ្យនាងទេ និង ថែមទាំងប្រាប់នាងឲ្យបន្តធ្វើការក្នុងលក្ខខ័ណ្ឌការងារ ដដែលនេះ ឬបើពុំនោះទេ នាងអាចសុំឈប់ពីការងារក៏បាន ។ នាងមិនសប្បាយចិត្តទាល់តែសោះ ។

អ្នកសម្របសម្រួលត្រូវសុំឲ្យក្រុមសិក្ខាកាមធ្វើបញ្ជីពីទីកន្លែងរួមគ្នា ថាតើកន្លែងណាដែលអ្នកគួរទៅ ប្រសិនបើអ្នកជាក្មេងស្រីនោះវិញ ដើម្បីឲ្យនាងប្រើប្រាស់វាគំនិតបានខ្លះ ។ បន្ទាប់មក ប្រសិនបើអ្នកជាមិត្តរបស់នាងវិញ តើអ្នកគួរផ្តល់ដំបូន្មានឲ្យនាងធ្វើអ្វីខ្លះក្នុងពេលឥឡូវនេះ?

# គ្រាប់អង្កាំ (ពណ៌ទឹកប្រាក់)

នៅចុងបញ្ចប់ នៃមេរៀននីមួយៗ សុំឲ្យសិក្ខាកាមយកអង្កាំពណ៌ទឹកប្រាក់មួយគ្រាប់ ហើយដោយវាចូលទៅក្នុងខ្សែ ។ សុំរំលឹកប្រាប់សិក្ខាកាមថា អង្កាំពណ៌ប្រាក់នេះ តំណាងឲ្យទីកន្លែង ដែលពួកគេនឹងទៅរកព័ត៌មានអំពីការងារ (ឧ. ទីភ្នាក់ងារជាតិមុខរបរ និង ការងារ/គេហទំព័រ បងភ័ក្រ មជ្ឈមណ្ឌលរកការងារឲ្យធ្វើនៅតាមខេត្ត/រាជធានី ។ល។) ។ វាក៏មានន័យម្យ៉ាងទៀតផងដែរថា ពួកគេដឹងថាត្រូវពិភាក្សាជាមួយនរណា ប្រសិនបើពួកគេចង់ធ្វើចំណាកស្រុក (ឧ. ឪពុកម្តាយ សាច់ញាតិ មិត្តភក្តិ និង អជ្ញាធរមូលដ្ឋាន ។ល។) ហើយនៅក្នុងមេរៀននេះ ពួកគេដឹងពីចំណុចគន្លឹះទាំងអស់ សម្រាប់ជាជំនួយស្មារតីក្នុងការធ្វើចំណាកស្រុកប្រកប ដោយសុវត្ថិភាព ។ ជម្រុញឲ្យសិក្ខាកាម ធ្វើការជាមួយអ្នកដែលអង្គុយក្បែរខ្លួនគាត់ ក្នុងការដោតអង្កាំចូលក្នុងខ្សែ ដោយជួយគ្នាទៅវិញទៅមកក្នុងការចងអង្កាំនៅជុំវិញកដៃរបស់ពួកគេ និង ត្រូវពិភាក្សាគ្នាថាតើវាមានន័យអ្វីចំពោះពួកគេ ។



០៨

# ជំនាញ



ការចាក់បញ្ចាំងរឿងវីដេអូបំផុសគំនិត (Inspirational video)
https://www.facebook.com/klahan9cambodia/videos/1059313010872363/

## គោលបំណង៖

- ចូរកំណត់អ្វីទៅជាជំនាញទន់ និង អ្វីទៅជាការអនុវត្តជំនាញទាំងនេះ
- ចូរគិតពីជំនាញអ្វី ដែលអ្នកត្រូវការសម្រាប់ការរកបាននូវការងារសមរម្យ
- តើការអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈជាអ្វីទៅ (TVET) ហើយតើវាអាចមានប្រយោជន៍អ្វីសម្រាប់អ្នក




សួរក្រុមសិក្ខាកាមមើលថាតើពួកគេគិតថា ពួកគេមានជំនាញអ្វីខ្លះ ឧ. ជំនាញជួសជុលទោចក្រយាន ជំនាញចុងភៅ ជំនាញសិប្បកម្ម ជំនាញក្នុងការអាន ជំនាញក្នុងការច្រៀង ។ល។ សរសេរជំនាញទាំងនេះនៅលើផ្ទាំងក្រដាស់ហ្វ្លីបឆាត ។

វិធីងាយៗក្នុងការដឹកនាំការងារនេះ គឺការសួរសិក្ខាកាមថាតើពួកគេចូលចិត្តអ្វី និង ជំនាញខាងអ្វី ។

ពន្យល់ប្រាប់សិក្ខាកាមថានៅមានជំនាញជាច្រើនផ្សេងទៀត ដែលអាចជួយពួកគេ ឲ្យទទួលបានជោគជ័យក្នុងការប្រកបរបរចិញ្ចឹមជីវិត ។ ជំនាញទាំងនេះ អាចធ្វើឲ្យចំណេះដឹងរបស់ពួកគេកាន់តែប្រសើរឡើង និង មានជំនឿចិត្តក្នុងការចរចារពីឱកាសការងារឲ្យបានកាន់តែល្អជាងមុន ហេតុដូច្នេះ ពួកគេនឹងមិនបិតក្នុងស្ថានភាពដែលមានគ្រោះថ្នាក់ទៀតទេ ។

ទាំងអស់នេះ ហៅថា ជំនាញទន់ ហើយជំនាញទាំងនោះ រួមមាន ជំនាញធ្វើផែនការ ជំនាញធ្វើទំនាក់ទំនង ជំនាញចរចារ ជំនាញដោះស្រាយបញ្ហា ជំនាញក្នុងការធ្វើឲ្យមានការជឿជាក់ និង ជំនាញក្នុងការសម្របខ្លួន ។ ជំនាញទាំងអស់នេះ គឺជាជំនាញដ៏សំខាន់ នៅពេលអ្នកស្វែងរកការងារធ្វើ ធ្វើឲ្យគេតម្លើងឋានៈ ឬ ការចាប់ផ្តើម និង ការរក្សានិរន្តរភាព នៃអាជីវកម្ម ។ ជំនាញទាំងអស់នេះ ក៏សំខាន់ផងដែរ ក្នុងពេលអ្នកធ្វើការជ្រើសរើសមាគ៌ាជីវិត និង ក្នុងពេលអ្នកធ្វើការពិភាក្សាពីជម្រើសទាំងនេះជាមួយឪពុក ម្តាយ និង សមាជិកគ្រួសាររបស់អ្នក ។

# សកម្មភាពទី ៩

## ករណីសិក្សា:
## ជំនាញទន់

រយៈពេល នៃការធ្វើលំហាត់: ៣០ នាទី



## គោលបំណង នៃការធ្វើលំហាត់:

- ដើម្បីកំណត់ឲ្យបានដឹងថាតើអ្វីខ្លះជាជំនាញទន់
- ដើម្បីបង្ហាញសិក្ខាកាមឲ្យបានដឹងអំពីសារៈសំខាន់ នៃជំនាញទន់

## សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

https://www.facebook.com/klahan9cambodia/videos/1012461945557470/

## ដំណើរការ នៃធ្វើលំហាត់:

- អ្នកសម្របសម្រួល ត្រូវចាក់បញ្ចាំងរឿងវីដេអូខ្លីៗពីវេបសាយខាងលើឲ្យក្រុមសិក្ខាកាមទាំងអស់មើល (ហើយអាស័យដ្ឋាន នៃវេបសាយនេះក៏មាននៅក្នុងឯកសារអប់រំដែរ) ។
- បន្ទាប់ពីមើលរឿងវីដេអូខ្លីៗរួច អ្នកសម្របសម្រួល ត្រូវសួរសិក្ខាកាមនូវសំណួរខាងក្រោមនេះ ដោយទុកពេលឲ្យពួកគេគ្រប់គ្រាន់ក្នុងការឆ្លើយសំណួរនីមួយៗ និង ឲ្យពួកគេពិភាក្សាគ្នាពីចម្លើយជាមួយនឹងសិក្ខាកាមក្រុមធំ ៖
  - ហេតុអ្វីបានជាអ្នកចាប់ចិត្តនឹងការបង្កើតជំនាញទន់ទាំងនេះ?
  - តើជំនាញទន់សំខាន់ៗអ្វីខ្លះ ដែលអ្នកនឹងត្រៀមខ្លួនក្នុងការរកការងារធ្វើ?
  - នេះជាមតិយោបល់មួយចំនួនសម្រាប់ឲ្យអ្នកបានដឹងថាតើអ្នកអាចទៅរកព័ត៌មានបន្ថែមទៀត ពីកន្លែងណា ដើម្បីឲ្យបានដឹងពីរបៀប នៃការបង្កើតជំនាញទន់ទាំងនេះ?
- នៅពេលអ្នកសម្របសម្រួល បានសួរសំណួរទាំងអស់ខាងលើរួចហើយ អ្នកសម្របសម្រួល ត្រូវចាក់បញ្ចាំងរឿងវីដេអូខ្លីៗខាងក្រោមនេះឲ្យសិក្ខាកាមមើល៖
  - ការមានជំនឿចិត្ត: សារជារូបភាពគំនូរជីវចល ដែលនិយាយអំពីអត្ថប្រយោជន៍ នៃការមានជំនឿចិត្ត ។ [រឿងវីដេអូខ្លីមានរយៈពេល ៥២ វិនាទី]
    https://www.facebook.com/klahan9cambodia/videos/1024970697639928/
  - ការធ្វើផែនការ: សារជារូបភាពគំនូរជីវចល ដែលនិយាយអំពីអត្ថប្រយោជន៍ នៃការមានផែនការជីវិត ។ [រឿងវីដេអូខ្លីមានរយៈពេល ៤៧ វិនាទី]
    https://www.facebook.com/klahan9cambodia/videos/1035155313288133/
- អ្នកសម្របសម្រួល ត្រូវសួរសិក្ខាកាមថាតើអ្នកនៅមានសំណួរអ្វីផ្សេងទៀតដែរឬទេ ។
- អ្នកសម្របសម្រួល ត្រូវនិយាយរំលឹកឡើងវិញម្តងទៀត អំពី សារៈសំខាន់ នៃការរៀនមុខវិជ្ជាជំនាញទន់នេះក្នុងការទទួលបានការងារធ្វើ និង ការអាចរក្សាបានតួនាទីការងារយូរអង្វែង ។

## ការបញ្ចប់កម្មវិធីធ្វើលំហាត់:

អ្នកសម្របសម្រួល អាចបញ្ចប់សកម្មភាពនេះ ដោយសុំឲ្យក្រុមសិក្ខាកាមកំណត់ពីជំនាញទន់ផ្សេងៗគ្នា ដែលពួកគេ អាចនឹករកឃើញ ។

# ៤.១ ការអប់រំបណ្តុះបណ្តាលជំនាញ បច្ចេកទេស និង ជំនាញវិជ្ជាជីវៈ (TVET skills)

**ការអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈ** គឺជាការអប់រំ និង ការបណ្តុះបណ្តាល ដែលផ្តល់ចំណេះដឹង និង ជំនាញ សម្រាប់ការបំរើការងារ ។ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ គឺជាវិធីមួយដែលផ្តល់នូវអាជីពមានប្រាក់បៀវត្សរ៍ខ្ពស់ និង រកប្រាក់ចំណូលបានច្រើន ។ ការដែលមានវិជ្ជាជីវៈ ដែលមានកំរិតនៃការទទួលស្គាល់មួយ អាចនាំឲ្យមានការងារទទួលបានប្រាក់បៀវត្សរ៍ខ្ពស់ វិជ្ជាជីវៈទាំងនោះរួមមាន ជាងអគ្គិសនី ជាងម៉ាស៊ីន ឱសថការី និង ទន្តពេទ្យ ពីអាជីពដែលអាចទទួលបានប្រាក់ចំណូលខ្ពស់នេះ វាអាចនាំឲ្យទទួលបានតួនាទីជាអ្នកគ្រប់គ្រងទៀត ។

ការងារពាណិជ្ជកម្ម កំពុងតែមានតម្រូវការខ្ពស់នៅប្រទេសកម្ពុជា ហើយវាផ្តល់នូវជម្រើសក្នុងសិក្សាមុខវិជ្ជានេះនៅកំរិតសាកលវិទ្យាល័យ ដែលវាមិនមែនសុទ្ធតែជារឿងងាយស្រួលសម្រាប់មនុស្សគ្រប់គ្នានោះទេ គឺដោយសារតែវាមានតម្លៃខ្ពស់ វាទាមទារសមត្ថភាពក្នុងការសិក្សា ត្រូវការចំណាយពេលវេលា និង កន្លែងរស់នៅសមស្រប ។

## សកម្មភាពទី ១០



**ករណីសិក្សា៖**
**ការងារកាត់ដេរ**

រយៈពេល នៃការធ្វើលំហាត់: ១០ នាទី

## គោលបំណង នៃការធ្វើលំហាត់:

- ដើម្បីកំណត់ឲ្យបានដឹងថាតើអ្វីខ្លះជាជំនាញទន់
- ដើម្បីបង្ហាញសិក្ខាកាមឲ្យបានដឹងអំពីសារៈសំខាន់ នៃជំនាញទន់

## សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

https://www.facebook.com/klahan9cambodia/videos/vb.581450158658653/1050417325095265/?type=3&theater

## ដំណើរការ នៃធ្វើលំហាត់:

- អ្នកសម្របសម្រួល ត្រូវនិយាយប្រាប់ក្រុមសិក្ខាកាមអំពីការអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈ និង សួរពួកគេថាហេតុអ្វីបានជាវាមានសារសំខាន់ចំពោះយុវជននៅប្រទេសកម្ពុជា ។
- អ្នកសម្របសម្រួល ត្រូវចាក់បញ្ចាំងរឿងវីដេអូខ្លីៗពីបណ្តាញវេបសាយខាងលើឲ្យក្រុមសិក្ខាកាមទាំងអស់មើល (ហើយនៅមានអាសយដ្ឋានវេបសាយផ្សេងទៀតនៅក្នុងឯកសារអប់រំផងដែរ) ។
- អ្នកសម្របសម្រួល ត្រូវសួរសិក្ខាកាមថាតើពួកគេមានសំណួរអ្វីអំពីរឿងវីដេអូខ្លីៗនេះទៀតដែរឬទេ និង សុំឲ្យពួកគេធ្វើការពិភាក្សាជុំវិញសាច់រឿង នៃវីដេអូខ្លីៗនេះ ។
- អ្នកសម្របសម្រួល ត្រូវពន្យល់សិក្ខាកាមឲ្យបានយល់ថា ជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈនេះ (TVET skills) ជាជំនាញ ដែលគេកំពុងត្រូវការនៅក្នុងប្រទេសកម្ពុជា ហើយជាទូទៅយុវជន មិនសូវបានដឹងអ្វីជាមុខវិជ្ជាជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈ (TVET subjects) នោះទេ ហើយពួកគេមិនបានដឹងថាតើជំនាញអ្វីខ្លះ ដែលនាំឲ្យពួកគេមានការងារ និង ទទួលបានប្រាក់បៀវត្ស ឬ អត្ថប្រយោជន៍ ប៉ុន្មាននោះទេ ។

### ការបញ្ចប់កម្មវិធីធ្វើលំហាត់:

អ្នកសម្របសម្រួល ត្រូវសួរក្រុមសិក្ខាកាមមើលថាតើពួកគេអាចប្រាប់ពីប្រភេទ នៃការងារបានមកពីការអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈ (TVET) ដែលមិត្តភក្តិ ឬ សមាជិកគ្រួសាររបស់ពួកគេទទួលបានដែរឬទេ និង សួរពួកគេបន្ថែមទៀតថាតើពួកគេដឹងពីកន្លែង ដែលអាចទទួលការបណ្តុះបណ្តាលជំនាញ TVET នេះដែរឬទេ ។ អ្នកសម្របសម្រួល មិនត្រូវភ្លេចសរសេរឃ្លាទាំងនេះ នៅក្នុងផ្ទាំងក្រដាសផ្ទាំងធំនោះទេ ។



# សកម្មភាពទី ១១

**សាលាអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈ ឬ សាកលវិទ្យាល័យ តើអ្នកគួរជ្រើសរើសយកសាលាមួយណា?**

រយៈពេល នៃការធ្វើលំហាត់: **១៥ នាទី**

## គោលបំណង នៃការធ្វើលំហាត់:

គឺដើម្បីបញ្ជាក់បន្ថែមលើការអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈ រួមទាំងអ្វីៗដែលសិក្ខាកាម អាចធ្វើបាន និង ទីកន្លែងដែលសិក្ខាកាមអាចរកឃើញ ប្រសិនបើពួកគេជ្រើសរើសយកការអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈ (TVET) ។

## សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

https://www.facebook.com/klahan9cambodia/videos/861391057331227/

## ដំណើរការ នៃធ្វើលំហាត់:

- >> ចាក់បញ្ចាំងរឿងវីដេអូខ្លីៗពីវេបសាយខាងលើឲ្យក្រុមសិក្ខាកាមទាំងអស់មើល (ហើយអាស័យដ្ឋានវេបសាយនេះក៏មាននៅក្នុងឯកសារអប់រំដែរ)
- >> បន្ទាប់ពីមើលរឿងវីដេអូខ្លីៗរួច សួរសិក្ខាកាមនូវសំណួរខាងក្រោម ដោយទុកពេលឲ្យសិក្ខាកាមឲ្យបានគ្រប់គ្រាន់ ក្នុងការឆ្លើយសំណួរនីមួយៗ និង សុំឲ្យពួកគេពិភាក្សាពីចម្លើយទាំងនេះជាមួយនឹងសិក្ខាកាមក្រុមធំ៖
  - តើអ្នកអាចរៀនយកមុខវិជ្ជាអ្វីនៅសាលាអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈក្នុងការទទួលបានការងារធ្វើ និង អាជីពផ្សេងៗ
  - តើត្រូវទៅរៀននៅសាលាអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈនៅកន្លែងណា និង តើត្រូវទៅរកការងារធ្វើនៅឯណា
  - តើហេតុអ្វីបានជាសាលាអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈមានសារសំខាន់

### ការបញ្ចប់កម្មវិធីធ្វើលំហាត់:

តើមានសិក្ខាកាមណាក្នុងក្រុមមានការងារល្អ ដែលជាការងារបានមកពីជំនាញ នៃការអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈ (TVET job) ដែរឬទេ? តើក្នុងពេលថ្មីៗនេះ មានសិក្ខាកាមណាមានការងារធ្វើដែលអាចចាត់ទុកបានថា ជាការអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈ (TVET) ដែរឬទេ? តើមានសិក្ខាកាមណាអាចនិយាយប្រាប់ក្រុមសិក្ខាកាមរបស់យើងអំពីអ្វី ដែលអ្នកកំពុងធ្វើ ហើយតើអ្នកបានរៀនពីជំនាញបច្ចេកទេស និង ជំនាញវិជ្ជាជីវៈ (TVET skills) នេះពីកន្លែងណា?

# សកម្មភាពទី ១២



**ករណីសិក្សា:**
**ការងារជំនាញ**

រយៈពេល នៃការធ្វើលំហាត់: ៣០ នាទី

## គោលបំណង នៃការធ្វើលំហាត់:

- >> ដើម្បីជួយសិក្ខាកាមក្នុងការគិតពីជំនាញក្នុងការងារផ្សេងៗពីគ្នា
- >> ដើម្បីយល់ដឹងពីជំនាញអ្វី ដែលអាចជាន់គ្នា
- >> ដើម្បីឲ្យសិក្ខាកាម អាចកំណត់យកជំនាញផ្ទាល់ខ្លួន និង ជំនាញអ្វី ដែលពួកគេអាចត្រូវការ និង ជំនាញអ្វី ដែលពួកគេចង់ពង្រឹងវាបន្ថែមទៀត

## សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

កាតផ្ទុកព័ត៌មាន (flash card) សម្រាប់សកម្មភាពទី១២

## ដំណើរការ នៃការធ្វើលំហាត់:

- អ្នកសម្របសម្រួល ប្រើកាតផ្ទុកព័ត៌មាន ដែលអ៊ុតរួច បង្ហាញម្តងមួយៗផ្នែកខាងការងារឲ្យសិក្ខាកាមទាំងអស់មើល ។
- អ្នកសម្របសម្រួល ត្រូវសួរសិក្ខាកាមទាំងអស់ថាតើជំនាញទន់ប្រភេទណា ដែលពួកគេត្រូវការសម្រាប់ធ្វើការងារណាមួយពិតប្រាកដ ។
- អ្នកសម្របសម្រួល ត្រូវលើកទឹកចិត្តឲ្យសិក្ខាកាមហ៊ាននិយាយពីជំនាញ ដែលពួកគេត្រូវការសម្រាប់ការងារណាមួយ ដែលពួកគេចង់ធ្វើ ដូចមាននៅក្នុងបញ្ជីការងារ ដែលអ្នកសម្របសម្រួលបានចែកជូននេះ ។

## ផែនការសកម្មភាពរបស់ខ្ញុំ

ក្រោយមក អ្នកសម្របសម្រួល ត្រូវសុំឲ្យក្រុមសិក្ខាកាមត្រឡប់ទៅមើលក្នុងក្រដាស់តារាង "សកម្មភាពរបស់ខ្ញុំ" និងរំលឹកពួកគេឲ្យមើលការងារ ដែលពួកគេចូលចិត្ត ។ អ្នកសម្របសម្រួល ត្រូវសុំឲ្យសិក្ខាកាមនីមួយៗ ពិចារណាទៅលើសំណួរមួយចំនួន ដូចខាងក្រោមនេះ ៖

១. តើជំនាញអ្វីខ្លះ ដែលអ្នកគិតថា អ្នកត្រូវការសម្រាប់ការងារនេះ?
២. ដើម្បីកម្រិតពីសារសំខាន់ នៃទម្រង់នោះ អ្នកត្រូវវាយធ្វើការតម្លៃវា តាមរយៈការផ្តល់ពិន្ទុ ចាប់ពីកម្រិត ១ ដល់៥ ដែលជាកម្រិតពិន្ទុខ្ពស់ជាងគេ ។
៣. តើអ្នកគិតថា ជំនាញមួយណាដែលអ្នកមានហើយ?
៤. តើអ្នកគិតថា ជំនាញមួយណាដែលអ្នកត្រូវខំរៀនឲ្យបានពូកែ?

អ្នកសម្របសម្រួល ត្រូវប្រាប់សិក្ខាកាមឲ្យធ្វើការពិភាក្សា ដើម្បីរកឲ្យឃើញថាតើជំនាញមួយណា ដែលគេត្រូវ ការច្រើន តើជំនាញមួយណា ដែលពួកគេគិតថាជាជំនាញ ដែលសំខាន់បំផុតសម្រាប់ពួកគេ និង តើជំនាញ មួយណាដែលការងារត្រូវការវារហូត ។

## ការបញ្ចប់កម្មវិធីធ្វើលំហាត់:

**សួរទៅកាន់ក្រុម៖** ហេតុអ្វីបានជាគេគិតថាជំនាញសំខាន់? តើមានអ្នកណា នៅក្នុងក្រុមបានប្រើជំនាញ នៅក្នុងការងាររបស់ពួកគេ? សូមជួយអោយពួកគាត់ជួយចែករំលែកថាតើពួកគាត់ប្រើប្រាស់ជំនាញទៅក្នុង ការងារយ៉ាងដូចម្តេច?

## ចំណុចគន្លឹះសម្រាប់ជាជំនួយស្មារតីក្នុងការបណ្តុះបណ្តាល

យកល្អ សម្រាប់ក្រុមរបស់អ្នកជាអ្នកសម្របសម្រួល គួរគិតពិចារណាពីលទ្ធភាពរបស់សិក្ខាកាមក្នុងការអាន និងសរសេរ ។ អ្នកសម្របសម្រួល អាចនឹងចង់ប្រើតារាងខាងក្រោមនេះ ទុកជាទម្រង់គំរូ សម្រាប់សិក្ខាកាមប្រើប្រាស់ ។

| ការងារ | ជំនាញត្រូវការ | ១ | ២ | ៣ | ៤ | ៥ | ជំនាញ ដែលមានហើយ | ជំនាញ ដែលត្រូវខំរៀនថែម |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |

| បញ្ជីការងារ | ជំនាញដែលត្រូវការ |
|---|---|
| **១. សន្តិសុខ**<br><br>សន្តិសុខត្រួតពិនិត្យមើលតាមការដ្ឋាន ដើម្បីការពារចោរលួច ការពារការបំផ្លាញសម្បត្តិឯកជន ឬ សាធារណៈ ការពារអគ្គិភ័យ និង ការពារនូវស្ថានភាពគ្រោះថ្នាក់ជាច្រើនផ្សេងទៀត ។ ពួកគេទទួលខុសត្រូវមើលថែសុវត្ថិភាពដល់កម្មករ និយោជិត ឬ បុគ្គលិក ម្ចាស់ផ្ទះ ភ្ញៀវ និង មនុស្សជាច្រើនផ្សេងទៀត ដែលគេកំណត់ឲ្យមើលថែទីតាំងនោះ ។ | >> ការទំនាក់ទំនង<br>>> ការស្តាប់<br>>> សមត្ថភាពធ្វើការងារដោយឯករាជ្យ<br>>> សមត្ថភាពផ្នែកសុខភាពរាងកាយ<br>>> ភ្នែកភ្លឺល្អ<br>>> សមត្ថភាពរៀបចំខ្លួនឲ្យបានរៀបរយគ្រប់ពេលវេលា<br>>> មានចរិតសមរម្យ និង ទន់ភ្លន់<br>>> ចេះធ្វើតាមគេភ្លាមៗ និង មានចិត្តស្ងប់ក្នុងពេលមានស្ថានភាពបន្ទាន់ |
| **២. អ្នកមើលថែមនុស្ស**<br><br>អ្នកមើលថែមនុស្សជាអ្នកផ្តល់នូវជំនួយក្នុងការមើលថែមនុស្ស ដែលមានជម្ងឺ អ្នករបួស មនុស្សមានជម្ងឺផ្លូវចិត្ត ឬ អ្នកមនុស្សពិការ ឬ មនុស្សចាស់ ដែលងាយនឹងដួលដេក ។ | >> ដោះស្រាយបញ្ហា<br>>> មានការអត់ធ្មត់ ឬ ខន្តី<br>>> ការទំនាក់ទំនង<br>>> មានចរិតគួរឲ្យគោរព និង មានការឈឺឆ្អាលចេះជួយគេជួយឯង<br>>> មានឥរិយាបថវិជ្ជមាន និង រីករាយ<br>>> មានសមត្ថភាពធ្វើការបានល្អ បើទោះបិតក្នុងកាលៈទេសៈរងសម្ពាធផ្លូវចិត្ត និង រាងកាយអស់កម្លាំងក៏ដោយ |
| **៣. កម្មករសំណង់**<br><br>កម្មសំណង់ គឺជាមនុស្សម្នាក់ ដែលធ្វើការសាមញ្ញជាច្រើនមុខ ដែលទាមទារនូវកម្លាំងពលកម្មប្រើប្រាស់នៅក្នុងការដ្ឋានសំណង់ ។ ពួកគេកាន់នូវឧបករណ៍និងសម្ភារៈ ឬ ជួយតម្លើងគ្រឿងឧបករណ៍ផ្សេងៗ ទៀត ។ | >> ការងារសំណង់<br>>> ការចរចារ<br>>> ការដោះស្រាយបញ្ហា<br>>> ការទំនាក់ទំនង<br>>> ការធ្វើផែនការសាងសង់<br>>> ចេះធ្វើការងារជាក្រុម |
| **៤. អ្នកបំរើការផ្នែកបដិសណ្ឋារកិច្ច**<br><br>អ្នកបំរើការផ្នែកបដិសណ្ឋារកិច្ច ជាទូទៅបំរើសេវាជូនអតិថិជនជាច្រើនមុខរួមមាន ការបំរើមនុស្ស នៅតាមរង្គសាល បំរើតាមភោជនីយដ្ឋាន បំរើសេវាក្នុងការងារដឹកជញ្ជូន និង ការរៀបចំការប្រជុំ ។ | >> ផ្តល់សេវាជូនអតិថិជន<br>>> ការទំនាក់ទំនង<br>>> ការរៀបចំ<br>>> ជំនាញខាងការស្តាប់<br>>> ជំនាញភាសា<br>>> មានសមត្ថភាពធ្វើការហួសម៉ោង |
| **៥. កម្មកររោងចក្រកាត់ដេរ** | >> អ្នកបង្ហាញម៉ូដ<br>>> កាត់ដេរ<br>>> ការចរចារ<br>>> ការដោះស្រាយបញ្ហា<br>>> ការលក់ និង ដើរទីផ្សារ |

# ៤.២ ជំនាញទន់

ផ្នែកបន្ទាប់មកទៀត គឺជាផ្នែកដែលត្រូវអនុវត្តជាក់ស្តែង ស្តីពី ការរៀនជំនាញទន់ ថ្មីៗ និង ការពង្រឹងនូវជំនាញទន់ដែលមានស្រាប់ ។

ជំនាញទន់ មិនមានការទាក់ទងគ្នានឹងកម្មវិធីជាក់លាក់ នៃវិស័យសិក្សាធិការ ឬ វិស័យអាជីពណាមួយនោះទេ ប៉ុន្តែវាជាជំនាញ ដែលអាចយកទៅអនុវត្តបាននៅគ្រប់កន្លែងធ្វើការទាំងអស់ ។ វាជាជំនាញ ដែលសំខាន់សម្រាប់ការប្រើប្រាស់បានជោគជ័យនៅកន្លែងធ្វើការងារ ។ ជំនាញទន់ គឺជាជំនាញ ដែលលំបាកនឹងទទួលបានណាស់ និង លំបាកធ្វើការវាស់វែងទៀតផង ប៉ុន្តែវាសំខាន់ខ្លាំងណាស់ក្នុងការទទួលបានការងារធ្វើ និងរក្សាការងារនោះឲ្យនៅឋិតថេរទៀតផង ។

## សកម្មភាពទី ១៣

### ការប្រែក្លាយពីជំនាញឲ្យទៅជាការធ្វើការងារ

រយៈពេល នៃការធ្វើលំហាត់: ៣០ នាទី



### គោលបំណង នៃការធ្វើលំហាត់:

- ដើម្បីឲ្យសិក្ខាកាមយល់ព្រមលើនិយមន័យ នៃជំនាញទន់
- ដើម្បីឲ្យសិក្ខាកាមបានរៀនជំនាញទន់ចំនួន ៥ មុខជំនាញ
- ដើម្បីឲ្យសិក្ខាកាមកំណត់ដឹងថាតើនៅពេលណា ត្រូវប្រើប្រាស់ជំនាញទន់ទាំងនេះ

### សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

ជំនាញទន់នីមួយៗនៅក្នុងរឿងវីដេអូខ្លីៗ ត្រូវបានទាញយកចេញពីវេបសាយ ។

### ដំណើរការ នៃការធ្វើលំហាត់:

ជំនាញទន់នីមួយៗ មានវីដេអូ ពីកម្មវិធីក្លាហាន9 ដើម្បីចាក់បញ្ចាំងពីឧទាហរណ៍ នៃជំនាញទន់នោះ ឲ្យសិក្ខាកាមមើល ។ បន្ទាប់ពីមើលរឿងវីដេអូខ្លីៗរួចមក អ្នកសម្របសម្រួលអាចសរសេរនិយមន័យ នៃជំនាញទន់នៅលើផ្ទាំងក្រដាសផ្ទាំងធំ ។

បន្ទាប់ពីបានមើលករណីសិក្សាសម្រាប់ជំនាញទាំង ៥ រួចមក សកម្មភាពទី១៤នេះ ជួយសិក្ខាកាមឲ្យអនុវត្តនូវជំនាញទាំងនេះបាន ។

ចំពោះជំនាញទន់នីមួយៗខាងក្រោមនេះ មាននិយាយបន្តិចបន្តួចប៉ុណ្ណោះអំពីអ្វីទៅជាជំនាញទន់ និង សារៈសំខាន់ នៃជំនាញទន់នេះក្នុងការងារ ។ ដូច្នេះ អ្នកសម្របសម្រួលត្រូវប្រាកដថា បានមើលករណីសិក្សា ទាំងនេះ ជាមួយក្រុមសិក្ខាកាមទាំងអស់គ្នា ។ បន្ទាប់ពីរឿងវីដេអូខ្លីនីមួយៗ ត្រូវផ្អាកបង្ហាញសិន ហើយអ្នកសម្របសម្រួល ត្រូវធ្វើការសាកសួរមើលថាតើសមាជិកក្នុងក្រុមមានសំណួរអ្វីដែរឬទេ ដើម្បីចង់ដឹងមើលថាតើសិក្ខាកាមយល់បានច្រើនអំពីជំនាញទន់ទាំងនេះដែរឬទេ ។ ប្រសិនបើពួកគេត្រូវការព័ត៌មានអំពីជំនាញទន់ទាំងនេះច្រើនបន្ថែមទៀត ។



## ៤.២.១. ការទំនាក់ទំនង

លទ្ធភាពក្នុងការបញ្ជូនសារមួយ ឲ្យបានច្បាស់ ដោយអនុវត្តតាមរបៀប ឧបករណ៍ និងបច្ចេកទេសសមស្របមួយចំនួនក្នុងការធ្វើឲ្យអ្នកស្តាប់បានយល់ពីប្រភេទ នៃព័ត៌មាននោះ ។ លទ្ធភាពក្នុងការបង្កើត និង រក្សានូវទំនាក់ទំនងការងារ ឲ្យមានប្រសិទ្ធិភាពជាមួយមនុស្សគ្រប់លំដាប់ តាមរយៈ ក្រុមការងារល្អ ។

https://www.facebook.com/klahan9cambodia/videos/1066838606786470/

**[រឿងវីដេអូខ្លីមានរយៈពេល ៣ នាទី និង ២៧ វិនាទី]**

ស្ថាបនិក នៃសមាគមសហគមន៍អេកូទេសចរណ៍ បានពិភាក្សាគ្នាថាតើគាត់ ប្តូរពី ការធ្វើ ការឲ្យគេទៅជាការចាប់ផ្តើមបង្កើតសមាគមនេះនៅខេត្តសៀមរាបវិញដោយរបៀបណា និងថាតើគាត់អាចបញ្ចុះបញ្ចូល និង ធ្វើការជាមួយសណ្ឋាគារដោយរបៀបណា ដូចជា ទីភ្នាក់ងារទេសចរណ៍ ។ល។ ដើម្បីឲ្យពួកគេយល់ព្រមប្រើប្រាស់សេវារបស់គាត់ ហើយសេវារបស់គាត់ទាំងនោះ គឺជាកញ្ចប់សេវាទេសចរណ៍ សម្រាប់អ្នកទេសចរណ៍ ។



## ៤.២.២. ការចរចារ

លទ្ធភាពក្នុងការប្រើយុទ្ធសាស្ត្រមួយចំនួន ដែលមានឥទ្ធិពលលើគេ និង អាចបញ្ចុះបញ្ចូលអ្នកដទៃបាន និង មានលទ្ធភាពក្នុងការបកស្រាយ និង ជដែកដោះ ស្រាយបញ្ហាបានល្អ ដើម្បីបញ្ចុះបណ្តូលអ្នកដទៃឲ្យយល់ស្របតាមខ្លួន ។

https://www.facebook.com/klahan9cambodia/videos/1049202828550048/

**[រឿងវីដេអូខ្លីមានរយៈពេល ២ នាទី និង ៥២ វិនាទី]**

កូនស្រីរបស់អ្នកក្បាច់គុនខ្មែរដ៏ល្បីឈ្មោះម្នាក់ ប្តេជ្ញាចិត្តដើរតាមមាគ៌ារបស់ឪពុកនាង ដែលចំណង់ចំណូលចិត្តនេះ ផ្ទុយនឹងឆន្ទៈរបស់គ្រួសាររបស់នាង ។ ប៉ុន្តែនាងពុំបានបញ្ចុះបញ្ចូលពួកគេឲ្យនាងធ្វើតាមក្តីសុបិន្តរបស់នាងនោះទេ ។



## ៤.២.៣. ការដោះស្រាយបញ្ហា

លទ្ធភាពក្នុងការសម្រួលបញ្ហាស្មុគស្មាញ ការរៀបចំដំណើរការគំរោងឲ្យទៅជាផ្នែកៗ ពិនិត្យ និង វាយតម្លៃការងារទាំងនេះជាប្រព័ន្ធ ។ លទ្ធភាពក្នុងការយកគំនិតច្នៃប្រឌិត/ប្រែក្លាយវាឲ្យទៅជាការអនុវត្តជាក់ស្តែង។ អ្នកអាចមើលពីស្ថានភាព និង បញ្ហានានាដែលកំពុងមាននៅក្នុងសាច់រឿងនេះ និង បង្កើតដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត ។

https://www.facebook.com/klahan9cambodia/videos/1057335931070071/

**[រឿងវីដេអូខ្លីមានរយៈពេល ២ នាទី និង ៥៩ វិនាទី]**

គ្រូឧទ្ទេស និង អ្នកបកប្រែភាសាកាយវិការ បានពិភាក្សាពីរបៀបធ្វើយ៉ាងណា ឲ្យនាងអាចជំនះលើបញ្ហាប្រឈមនានា នៅពេលនាងចាប់ផ្តើមរៀនភាសាកាយវិការ ក្នុងពេលសង្គមមិនបានឲ្យតម្លៃលើអាជីពបែបនេះរួមទាំងសមាជិកគ្រួសាររបស់នាងផង និង នៅពេលដែលនាងធ្វើការជាអ្នកបកប្រែភាសាកាយវិការ ។



## ៤.២.៤. ជំនឿចិត្ត

អារម្មណ៍មានការជឿជាក់លើលទ្ធភាព គុណភាព និង សេចក្តីសម្រេចចិត្តផ្ទាល់របស់នរណាម្នាក់។ អារម្មណ៍មានទំនុកចិត្តលើខ្លួនឯង ការជានាខ្លួនឯង ការប្តេជ្ញាចិត្ត ភាពនឹងធឹង និង ការពឹងពាក់លើខ្លួនឯង ។

https://www.facebook.com/klahan9cambodia/videos/1066870546783276/

**[រឿងវីដេអូខ្លីមានរយៈពេល ១ នាទី និង ៥៧ វិនាទី]**

ចំណុចគន្លឹះសម្រាប់ជាជំនួយស្មារតីក្នុងការក្លាយខ្លួនជាមនុស្សដែលមានការ ជឿជាក់ដោយខ្លួនឯង ។
១) មានជំហរច្បាស់លាស់ ២) ត្រូវធ្វើយ៉ាងណាឲ្យការពោលអះអាងរបស់អ្នកឈរលើភស្តុតាងជាគោល
៣) ស្វែងរកការជួយគាំទ្រពីមិត្តភក្តិ និង ៤) ជឿលើខ្លួនឯង ។

## ៤.២.៥. ការធ្វើផែនការ



លទ្ធភាពក្នុងការគិតជាមុន ដើម្បីរៀបចំសកម្មភាពការងារឲ្យបានសមស្រប និង មានប្រសិទ្ធិភាព សម្រាប់ខ្លួនឯង និងសម្រាប់អ្នកដទៃ ។ លទ្ធភាពក្នុងការកំណត់អាទិភាព និង ធ្វើផែនការសកម្មភាពការងារ ដោយគិតដល់បញ្ហា និង កត្តាពាក់ព័ន្ធទាំងអស់ ដូចជា កាលកំណត់ បុគ្គលិក និង ធនធាន ដែលត្រូវការ ។

https://www.facebook.com/klahan9cambodia/videos/1049718365165161/

**[រឿងវីដេអូខ្លីរយៈពេល ២ នាទី និង ៣០ វិនាទី]**

អ្នកផលិតរូបភាពតុក្កតាស្រមោលអាយ៉ងម្នាក់ បានពិភាក្សាពីរបៀបធ្វើផែន ការត្រឡប់ចូលសាលាវិញ រយៈពេលពីរឆ្នាំបន្ទាប់ពីគាត់បានបញ្ចប់ការសិក្សានៅ វិទ្យាល័យ និង របៀប នៃការបែងចែក និង គ្រប់គ្រងពេលវេលា ដើម្បីរក្សាឲ្យបាននូវភាពប៉ិនប្រសព្វរបស់គាត់ និងបន្តរៀនយកបរិញ្ញាប័ត្រ អក្សរសាស្ត្រភាសាអង់គ្លេសរបស់គាត់ ។

## ៤.២.៦. ការសម្របខ្លួន



លទ្ធភាពក្នុងការធ្វើការក្នុងស្ថានភាពផ្សេងៗ អាចជាលក្ខណៈបុគ្គល ឬ ជាក្រុមប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។ សិក្ខាកាមអាចយល់ និង ចេះសម្របខ្លួនជា មួយអ្នកមានទស្សនៈផ្សេងៗ និង អ្នកមានទស្សនៈផ្ទុយនឹងខ្លួន ចំពោះបញ្ហា ដែល លើកយកមកធ្វើការពិភាក្សា ដោយចេះសម្របខ្លួនតាមអភិក្រមតាមការប្រែប្រួល នៃស្ថានភាពតម្រូវ និង ចេះកែប្រែ ឬ ទទួលយកការកែប្រែនៅក្នុងអង្គការរបស់ខ្លួនផ្ទាល់ ឬ ទៅតាមតម្រូវការនៃការងារ ដោយងាយស្រួល ។

https://www.facebook.com/klahan9cambodia/videos/1039256599544671/

**[រឿងវីដេអូខ្លីរយៈពេល ២ នាទី និង ៤៨ វិនាទី]**

ឃ្លីបវីឌីអូនេះ បង្ហាញពីរបៀបសម្របខ្លួនទៅតាមស្ថានភាពសាលា/ការងារ វាអាចជួយអ្នកឲ្យមានការជឿជាក់លើថាមពលរបស់អ្នកសម្រាប់ការងារណា ដែលអ្នករៀបចំនឹងធ្វើ ។

### ការបញ្ចប់កម្មវិធីធ្វើលំហាត់:

អ្នកសម្របសម្រួល ត្រូវសួរក្រុមសិក្ខាកាមអំពីជំនាញទន់អ្វី ដែលសិក្ខាកាមមានជំនាញ តើជំនាញទន់អ្វីខ្លះដែលសិក្ខាកាមចង់រៀន និង អាចដឹងផងដែរ ក្រៅពីនោះមានជំនាញខ្លះ ដែលសិក្ខាកាមមិនធ្លាប់ឮពីមុនមក ។

# សកម្មភាពទី ១៤



## ការយកជំនាញទៅអនុវត្តជាក់ស្តែង

រយៈពេល នៃការធ្វើលំហាត់: **៦០ នាទី**

### គោលបំណង នៃការធ្វើលំហាត់:

- សកម្មភាពនេះនឹងជួយសិក្ខាកាមឲ្យអនុវត្តជំនាញទន់ខ្លះ ដែលពួកគេបានរៀនពីរឿងវីដេអូខ្លីៗ
- វានឹងជួយសិក្ខាកាមឲ្យកំណត់ដឹងពីជំនាញ ដែលអាចជាន់គ្នាដោយរបៀបណា និង ដឹងពីសារៈសំខាន់ នៃសេចក្តីត្រូវការជំនាញទន់ជាច្រើន
- វានឹងជួយសិក្ខាកាមឲ្យមើលឃើញជំនាញ ដែលពួកគេត្រូវការសម្រាប់ការងារនៅថ្ងៃក្រោយ

### សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

តារាងសកម្មភាព នៃជំនាញទាំង ៥ ។

### ដំណើរការ នៃការធ្វើលំហាត់:

- អ្នកសម្របសម្រួល ត្រូវបែងចែកសិក្ខាកាមក្រុមធំឲ្យទៅជាក្រុមតូចៗ ។
- អ្នសម្របសម្រួល ត្រូវផ្តល់ឲ្យសិក្ខាកាមនូវសកម្មភាពមួយ ដែលបានមកតារាងសកម្មភាពជំនាញ ។
- អ្នកសម្របសម្រួល ត្រូវទុកពេលឲ្យក្រុមនីមួយៗ ចំនួន ៣០ នាទី ដើម្បីឲ្យក្រុមសិក្ខាកាមទាំងនោះធ្វើលំហាត់ តាមរយៈ សកម្មភាពរបស់ពួកគេ ។
- អ្នកសម្របសម្រួល ត្រូវសុំឲ្យសិក្ខាកាមគិតអំពីជំនាញមួយណា ដែលពួកគេមាននៅក្នុងសកម្មភាពរបស់ពួកគេ ។
- អ្នកសម្របសម្រួល ត្រូវហៅក្រុមសិក្ខាកាមទាំងអស់ឲ្យមកជុំគ្នាវិញ និង ទុកពេលឲ្យក្រុមនីមួយៗ ចំនួន ៥ នាទី ក្នុងការជជែកគ្នា តាមរយៈ សកម្មភាពរបស់ពួកគេ - អ្វីដែលពួកគេបានធ្វើ តើជំនាញអ្វីដែលពួកគេមាន និង តើពួកគេប្រឈមនឹងឧបសគ្គអ្វីខ្លះ ។
- ប្រសិនបើអ្នកមានពេល អ្នកអាចមើលលំហាត់ ដែលនិយាយអំពីជំនាញទន់ឲ្យបានច្រើន និង ធ្វើការអនុវត្តតាមលំហាត់ទាំងអស់នោះទៅ!

## ការបញ្ចប់កម្មវិធីធ្វើលំហាត់:

អ្នកសម្របសម្រួល ត្រូវសួរក្រុមសិក្ខាកាមអំពីជំនាញទន់អ្វី ដែលសិក្ខាកាមមានជំនាញ តើជំនាញទន់អ្វីខ្លះ ដែលសិក្ខាកាមចង់រៀន និង អាចដឹងផងដែរ ក្រៅពីលោមានជំនាញខ្លះ ដែលសិក្ខាកាមមិនធ្លាប់ពុំពីមុនមក ។

# សកម្មភាពជំនាញទន់ទាំង ៥

## សកម្មភាពជំនាញទន់ទី ១

តើនឹងមានអ្វីកើតឡើង ប្រសិនបើអ្នកជាប់គាំងនៅលើកោះខ្សាច់មួយដោយសារតែការលិចកប៉ាល់នៅទីនោះ? តើមានឧបករណ៍សម្ភារៈសំខាន់អ្វីសម្រាប់ស្រោចស្រង់ជីវិត? អ្នកមានពេលខ្លីត្រឹមតែ (១០នាទី) ប៉ុណ្ណោះ ក្នុងការធ្វើការសម្រេចជាក្រុម ។

ភារកិច្ចរបស់អ្នក គឺជ្រើសរើសយកឧបករណ៍សម្ភារៈចំនួន ១០ មុខ ដើម្បីជួយអ្នកឲ្យធ្វើការស្រោចស្រង់ជីវិតមនុស្សនៅលើកោះខ្សាច់ ។ ជាដំបូង អ្នកត្រូវសរសេរបញ្ជីឈ្មោះឧបករណ៍សម្ភារៈចំនួន ១០ មុខនោះនៅលើក្រដាសផ្ទាំងធំ ដែលអ្នកទាំងអស់គ្នាគិតថាសំខាន់ក្នុងការតោង និង កាន់ ដើម្បីជួយសង្គ្រោះជីវិតយើងឲ្យបានឡើងទៅដល់កោះ ។ បន្ទាប់មក អ្នកត្រូវធ្វើការវាយតម្លៃជាក្រុមក្នុងការជ្រើសរើសយកឧបករណ៍សម្ភារៈដែលសំខាន់បំផុតតែមួយមុខគត់ ចេញពីបញ្ជីឧបករណ៍សម្ភារៈទាំង ១០ របស់អ្នក ។

ឧទាហរណ៍ ឧបករណ៍មួយ ដែលអ្នកចង់យកនោះ គឺឈើគូសមួយប្រអប់ ឬ ដែកកេះមួយ ។

សកម្មភាពនេះ គឺជាមេរៀនដ៏ល្អបំផុតក្នុងការធ្វើការសម្រេចចិត្តជាក្រុម ក្នុងនាមជាសិក្ខាកាម ប្រាកដណាស់ថានឹងមិនមានគំនិតអ្វីខុសគ្នាប៉ុន្មានអំពីឧបករណ៍សម្ភារៈអ្វី ដែលត្រូវសរសេរចូលក្នុងបញ្ជីនេះក្នុងរយៈពេលមួយដ៏ខ្លីនោះទេ ។

### ជំនាញ:

ការចរចារ និង ការទំនាក់ទំនង

## សកម្មភាពជំនាញទន់ទី ២

**ប្រយ័ត្ន:** មុននឹងចាប់ផ្តើម អ្នកសម្របសម្រួលត្រូវជម្រាបសិក្ខាកាមថា អ្នកត្រូវមានការប្រុងប្រយ័ត្នខ្ពស់ ដោយមិនត្រូវធ្វើឲ្យសិក្ខាកាមណាមួយមានការឈឺចាប់ ដោយសារការមួលកដៃ ដោយជាន់លើអ្នកដទៃនោះទេ ។ល។ រៀបកន្លែងជារង្វង់មូលសម្រាប់មនុស្សពីប្រាំបីទៅដប់នាក់ (ឬច្រើនជាងនេះ រង្វង់នោះ ត្រូវរៀបចំទៅតាមទំហំនៃការចូលរួមរបស់សិក្ខាកាម)។ អ្នកសម្របសម្រួល ត្រូវពន្យល់ប្រាប់សិក្ខាកាមថា លំហាត់នេះសំខាន់ណាស់ ក្នុងការអនុវត្តតាមការណែនាំ និង ស្តាប់គ្នាទៅវិញទៅមកដោយប្រុងប្រយ័ត្ន ដើម្បីជៀសវាងកុំឲ្យសិក្ខាកាមណាមួយមានការឈឺចាប់ ។ អ្នកសម្របសម្រួល ត្រូវពន្យល់សិក្ខាកាមទៀតថា អ្នករាល់គ្នាត្រូវឈរជារង្វង់មូល ប្រើដៃទាំងពីរចាប់បន្តៗគ្នាជារង្វង់មូល និង ដោយចាប់ដៃគ្នាជាមួយមនុស្សចំនួនពីរនាក់ ។ ការងាររបស់អ្នក គឺដោះ "ចំណង" ដៃដែលកាន់ជាប់គ្នានោះ ហើយក្រោយមក កាន់ដៃគ្នាពទ្ធវាជារង្វង់មូលឡើងវិញ ។ ឥឡូវនេះ អ្នកសម្របសម្រួល ត្រូវប្រាប់សិក្ខាកាមឲ្យយកដៃស្តាំរបស់ខ្លួនចាប់ដៃមនុស្សម្នាក់ និង ដៃឆ្វេងចាប់ដៃមនុស្សម្នាក់ទៀត ។ បន្ទាប់មក ប្រាប់ពួកគេឲ្យធ្វើសាកមើល ដោយយឺតៗ និង ដោយប្រុងប្រយ័ត្ន ក្នុងការដោះរង្វង់ដៃនេះ ដែលពួកអ្នកកាន់គ្នាជារង្វង់មូលនេះ ។ ប្រសិនបើក្រុមសិក្ខាកាម ធ្វើបានល្អនៅពេលនេះ ត្រូវសាកធ្វើអ្វី ដែលប្លែកជាងនេះ ដូចជាការធ្វើវាដោយមិនមានការនិយាយរកគ្នាក្នុងពេលធ្វើលំហាត់ ឬ គ្រាន់តែនិយាយខ្សឹបៗដាក់គ្នាតែប៉ុណ្ណោះ ។

នេះជាសកម្មភាពល្អណាស់ ដែលជាវគ្គបង្ហាញឲ្យសិក្ខាកាម អាចពិនិត្យមើលថាតើពួកគេអាចធ្វើការទំនាក់ទំនងជាមួយអ្នកផ្សេង ទៀតដោយរបៀបណា តើត្រូវសហការគ្នាដូចម្តេចនិង តើយុទ្ធសាស្រ្តអ្វី ដែលអាចប្រើបាន ល្អបំផុត ។

**ជំនាញ:**

ការធ្វើការងារជាក្រុម ការទំនាក់ទំនង និង ការដោះស្រាយបញ្ហា

## សកម្មភាពជំនាញទន់ទី ៣

ល្បែងកសាងក្រុមការងារនេះ អាចទាមទារឲ្យមានគណៈកម្មការអង្កេតការ និង សិក្ខាកាមចំនួន ៤ ក្រុម ។ គណៈកម្មការអង្កេតការ ដឹកនាំសិក្ខាកាម ឲ្យធ្វើតាមសកម្មភាព ដូចខាងក្រោមនេះ៖

- រៀបចំសម្ភារៈប្រើប្រាស់នៅលើតុទាំង ៤ ដោយឡែកៗពីគ្នា ។
- ជម្រាបសិក្ខាកាមថា អ្នកនឹងត្រូវបែងចែកជា ៤ ក្រុម ។
- ធ្វើការប្រកាសណែនាំក្រុមនីមួយៗថា អ្នកទាំងអស់គ្នា ត្រូវប្រជែងជាមួយនឹងក្រុមដទៃទៀត ដើម្បីដណ្តើមយកភាពល្បីល្បាញរបស់ក្រុមខ្លួន ។ ការវាស់វែងលទ្ធផល នៃការប្រកួតប្រជែងនេះ ត្រូវធ្វើឡើង តាមរយៈ នៃការសង្កេតមើលការប្រើប្រាស់ជំនាញទន់របស់អ្នករាល់គ្នាក្នុងការអនុវត្តសកម្មភាព ដើម្បីបង្កើតបាននូវកេរ្តិ៍ឈ្មោះល្អ ។ ក្រុមដែលអាចឈ្នះបាន គឺអាស្រ័យលើតវិយាបថ នៃការកសាងក្រុម ក្នុងការបង្កើតបាននូវផលិតផល ដែលមានគុណភាពល្អបំផុត និង ភាពល្បីល្បាញ ខ្ពស់បំផុត ។
- សុំលើកទឹកចិត្តឲ្យក្រុមទាំងអស់ អនុវត្តជំនាញទន់ទាំងនេះ រួមមាន ការទំនាក់ទំនង ការចរចារ ការដោះស្រាយបញ្ហា ជំនឿចិត្ត ការធ្វើផែនការ និង ការសម្របខ្លួនក្នុងកសាងស្នាដៃ ។

- ទុកពេលឲ្យសិក្ខាកាមចំនួន ១០ នាទី សម្រាប់បង្កើតនូវស្នាដៃ ដែលពួកគេអាចធ្វើបាន ។
- ចាក់បទភ្លេងកន្ទ្រាក់អារម្មណ៍ក្នុងពេល ដែលពួកគេកំពុងធ្វើសកម្មភាពកសាងក្រុម ។
- ទុកពេលឲ្យគណៈកម្មការអង្កេតការចំនួន ៥ នាទី ដើម្បីបង្ហាញពីការដាក់ពិន្ទុ និង លទ្ធផលនៃការប្រកួតប្រជែង ។
- លើកទឹកចិត្តឲ្យសិក្ខាកាម រីករាយអបអរទទួលយកលទ្ធផលរបស់ពួកគេ មិនថា លទ្ធផលនោះជាលទ្ធផល ដែលឈ្នះ ឬចាញ់ក៏ដោយ ប៉ុន្តែ ពួកគេអាចរៀនពីការអនុវត្តរបស់ពួកគេ និង មតិរិះគន់ពីគណៈកម្មការអង្កេតការ ។

**ជំនាញ:**

ការទំនាក់ទំនង ការចរចារ ការដោះស្រាយបញ្ហា ជំនឿចិត្ត ការធ្វើផែនការ និង ការសម្របខ្លួន

## សកម្មភាពជំនាញទន់ទី ៤

នេះជាសកម្មភាពឆាប់រហ័ស និង ងាយៗ ដែលបង្ហាញពីសេចក្តីណែនាំដូចគ្នា ដែលត្រូវបកស្រាយខុសគ្នាដោយមនុស្សផ្សេងគ្នា តាមរបៀបណា និងការគូសបញ្ជាក់ពីសារសំខាន់ នៃការទំនាក់ទំនងឲ្យបានច្បាស់លាស់ ។

### ការណែនាំ:

អ្នកសម្របសម្រួល ត្រូវចែកក្រដាសខ្នាត letter size/A4 មួយសន្លឹកឲ្យសិក្ខាកាមនីមួយៗ ។
អ្នកសម្របសម្រួល ត្រូវប្រាប់ក្រុមសិក្ខាកាមថា ខ្ញុំនឹងធ្វើការណែនាំអ្នកទាំងអស់គ្នាពីរបៀបបត់ក្រដាស ក្នុងការបង្កើតបានជារូបអ្វីមួយ ។
អ្នកសម្របសម្រួល ត្រូវប្រាប់សិក្ខាកាមទៀតថា ខ្ញុំនឹងណែនាំអ្នក ហើយអ្នកត្រូវបិទភ្នែក និង មិនអាចសួរសំណួរអ្វី បានក្នុងពេលនេះទេ ។
អ្នកសម្របសម្រួល ត្រូវចាប់ផ្តើមធ្វើការណែនាំក្រុមសិក្ខាកាមឲ្យបត់ និង ច្រៀកក្រដាស់ បន្ទាប់មក សុំសិក្ខាកាមឲ្យលាក្រដាសចេញវិញ និង ធ្វើការប្រៀបធៀបមើលថាតើវាមានរាង្គដូចម្តេច ។

### ការពន្យល់សង្ខេបៗ និង ការពិភាក្សា

អ្នកសម្របសម្រួល ត្រូវចង្អុលបង្ហាញថា ក្រដាសនីមួយៗ មើលទៅមានសភាពខុសៗគ្នា បើទោះជាអ្នកបានធ្វើការណែនាំដូចៗគ្នាទៅសិក្ខាកាមគ្រប់គ្នាក៏ដោយ ។ បើអញ្ចឹង តើវាមានន័យដូចម្តេច?
អ្នកសម្របសម្រួល ត្រូវសួរក្រុមសិក្ខាកាម ប្រសិនបើអ្នកសម្របសម្រួល គិតថា លទ្ធផលនៃការបត់ក្រដាស់នេះអាច ល្អជាងមុន ប្រសិនបើសិក្ខាកាមបើកភ្នែករបស់គេ ឬ ប្រសិនបើ ពួកគេត្រូវបានអនុញ្ញាតឲ្យសួរសំណួរទៅវិញនោះ ។
ការទំនាក់ទំនង តាមរយៈ ការបញ្ជូនសារមួយឲ្យអ្នកដទៃស្តាប់យល់នោះ មិនមែនជាការងាយទេ យើងទាំងអស់គ្នាបកស្រាយព័ត៌មាន ដែលយើងទទួលបានផ្សេងៗគ្នា ។ នេះហើយជាហេតុ ដែលថា ការទំនាក់ទំនងជារឿងសំខាន់ណាស់ក្នុងការសួរ និង បញ្ជាក់ឲ្យបានយល់គ្នា ដើម្បីធ្វើយ៉ាងណាឲ្យសារ ដែលយើងបានទំនាក់ទំនងគ្នានោះ មិនត្រូវមានការល្អៀងខ្លឹមសារដើមទេ ។

**ជំនាញ:** ការធ្វើទំនាក់ទំនង

## សកម្មភាពជំនាញទន់ទី ៥ : ល្បែងព្រះអាទិត្យរះ

១. អ្នកសម្របសម្រួល ត្រូវចែកក្រដាសមួយសន្លឹក និង ខ្មៅដៃមួយឲ្យសមាជិកក្រុម និង សុំឲ្យសិក្ខាកាម សរសេរឈ្មោះរបស់ពួកគេនៅចំកណ្ដាលសន្លឹកក្រដាសនោះ ។
២. បន្ទាប់មក អ្នកសម្របសម្រួល ត្រូវសុំឲ្យសិក្ខាកាមគូររូបព្រះអាទិត្យរះ នៅជុំវិញឈ្មោះរបស់ពួកគេជាមួយនឹងខ្សែធ្នូតបន្ទាត់មួយចំនួនឲ្យស៊ីគ្នានឹងចំនួនសមាជិកក្រុមនៅក្នុងក្រុមរបស់ខ្លួន រួមទាំងរូបសិក្ខាកាមខ្លួនឯងផង ។
៣. បន្ទាប់មក សមាជិកក្រុមនីមួយៗ ត្រូវហុចសន្លឹកក្រដាស់ ដែលមានរូបព្រះអាទិត្យរះនេះទៅឲ្យសិក្ខាកាមម្នាក់ទៀតពីមួយទៅមួយ ដែលនៅខាងស្ដៃដៃរបស់ពួកគេ ហើយសមាជិកក្រុម សរសេរអ្វីដែលមានលក្ខណៈវិជ្ជមានអំពីមនុស្សនោះ នៅលើគំនូសបន្ទាត់ នៃសន្លឹកក្រដាសនោះ ។
៤. បន្ទាប់មកទៀត សមាជិកក្រុមនោះ ហុចក្រដាស់រូបព្រះអាទិត្យរះនោះទៅមនុស្សម្នាក់ទៀត ដែលខាងស្ដាំដៃរបស់ខ្លួន និង ហុចបែបនេះទៅមនុស្សបន្តបន្ទាប់ទៀត ។
៥. សន្លឹកក្រដាសរូបព្រះអាទិត្យរះទាំងនេះ ត្រូវបានហុចបញ្ជូនស់ត្រនិចនាឡិកាជុំវិញក្រុមនីមួយៗ រហូតទាល់តែក្រុមទាំងអស់បានសរសេរចំណុចវិជ្ជមាននៅលើក្រដាសរូបព្រះអាទិត្យនីមួយៗអំពីសមាជិកគ្រប់ក្រុមរួចរាល់ ។
៦. នៅពេលក្រដាសរូបព្រះអាទិត្យ ត្រូវបានសរសេរចំណុចវិជ្ជមានរួចរាល់ហើយ ត្រូវហុចក្រដាស់នេះទៅឲ្យម្ចាស់ដើមវិញ ហើយពួកគេនឹងសរសេរចំណុចនូវចំណុចវិជ្ជមានអំពីខ្លួនឯង ។ (អ្នកអាចរំលងផ្នែកនេះបាន ប៉ុន្តែ ខ្ញុំគិតថា ចំណុចនេះ វាជម្រុញឲ្យយើងមានជំនឿចិត្ត និង យល់ដឹង ហើយត្រូវលើកទឹកចិត្តសមាជិកក្រុមនីមួយៗឲ្យមានការពេញចិត្តនឹងលទ្ធផលខ្លួនឯងក៏ដូចជាលទ្ធផលរបស់អ្នកដទៃដែរ) ។
៧. បន្ទាប់មក សមាជិកក្រុមនីមួយៗ ត្រូវអានក្រដាសរូបព្រះអាទិត្យរះរបស់ពួកគេឲ្យបានឮៗ ដើម្បីឲ្យសមាជិកក្រុមដទៃស្ដាប់បានផង ។

## ការសន្និដ្ឋាន

នេះបានពិតជាការបំបែកផ្ទាំងទឹកកកដ៏ធំមួយមែន ។ វាជួយបង្កើតបានបរិយាកាសវិជ្ជមានដ៏អស្ចារ្យមួយក្នុងក្រុម និង ក្នុងបន្ទប់បណ្ដុះបណ្ដាលរបស់អ្នកមែន ។ វាមិនត្រឹមតែជួយជម្រុញឲ្យអ្នកមានជំនឿចិត្តខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានពង្រឹង និងពង្រីកស្មារតីក្រុមដែរ រឹតចំណងសាមគ្គីភាពក្រុម និង ការលើកទឹកចិត្តក្រុម ។

## ជំនាញ:

ការមានជំនឿចិត្តខ្លួនឯង

# សកម្មភាពទី ១៥



## សម្ភាសន៍ការងារ ដែលបានដាក់ពាក្យធ្វើការនោះ

រយៈពេល នៃការធ្វើលំហាត់: ៣០ នាទី

### គោលបំណង នៃការធ្វើលំហាត់:

- ដើម្បីឲ្យសិក្ខាកាមទទួលបាននូវអ្វីដែលពួកគេបានរៀនសូត្រកន្លងមក និង ត្រៀមរៀបចំចម្លើយសម្រាប់ឆ្លើយសំណួរនៅពេលធ្វើសម្ភាសន៍ពាក់ព័ន្ធនឹងការងារដែលពួកគេបានដាក់ពាក្យ ។

### សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

https://www.facebook.com/klahan9cambodia/videos/vb.581450158658653/1056732987797032/?type=3&theater

### ដំណើរការ នៃការធ្វើលំហាត់:

- អ្នកសម្របសម្រួល ត្រូវចាក់បញ្ចាំងរឿងវីដេអូខ្លីៗពីក្នុងវេបសាយខាងលើឲ្យសិក្ខាកាមទាំងអស់មើល (ហើយអាស័យដ្ឋាន នៃបណ្ដាញវេបសាយនេះក៏មាននៅក្នុងឯកសារអប់រំដែរ) ។
- បន្ទាប់ពីបានមើលរឿងវីដេអូខ្លីនេះរួច សុំឲ្យសិក្ខាកាម ពិភាក្សាអំពីអ្វីដែលជាភាពខុសគ្នា និង ថាតើពួកគេអាចត្រៀមខ្លួន ដើម្បីធ្វើការសម្ភាសន៍ដោយរបៀបណា ។
- អ្នកសម្របសម្រួល ត្រូវចែកសំណួរសម្រាប់ការសម្ភាសន៍ ដែលបានមកពីបញ្ជីតារាងសកម្មភាពឲ្យសិក្ខាកាមនីមួយៗ ។
- អ្នកសម្របសម្រួល ត្រូវទុកពេលឲ្យសិក្ខាកាមចំនួន ១៥ នាទី ដើម្បីត្រៀមរៀបចំចម្លើយ ។
- អ្នកសម្របសម្រួល ត្រូវជួយរំលឹកសិក្ខាកាមអំពីចំណុចគន្លឹះសម្រាប់ជាជំនួយស្មារតី ដូចបានរៀបរាប់នៅក្នុងរឿងវីដេអូខ្លី ដែលពួកគេបានមើលជុំវិញការសម្ភាសន៍ និង ដោយសារចំណុចគន្លឹះទាំងនោះពួកគេអាចសរសេរនូវចម្លើយរបស់ពួកគេបាន ។
- ក្នុងរយៈពេល ១៥ នាទីក្រោយមក អ្នកសម្របសម្រួល ត្រូវបែងចែកសិក្ខាកាមជាក្រុមតូចៗ ដែលក្នុងមួយក្រុមមានគ្នាចំនួនពីរនាក់ ហើយបន្ទាប់មក សុំឲ្យពួកគេប្ដូរវេនគ្នាធ្វើជាអ្នកសម្ភាសន៍ម្ដង និង ធ្វើជាអ្នកត្រូវគេសម្ភាសន៍ម្ដង ។
- អ្នកសម្របសម្រួល ត្រូវប្រាប់សិក្ខាកាមឲ្យផ្ដល់នូវមតិរិះគន់ឲ្យគ្នាទៅវិញទៅមកបន្ទាប់ពីបញ្ចប់សកម្មភាពនេះ ។
- អ្នកសម្របសម្រួល អាចផ្ដល់យោបល់ឲ្យសិក្ខាកាមធ្វើលំហាត់នេះសារចុះសារឡើង ដើម្បីឲ្យដឹងថាតើ ពួកគេមានជំនឿចិត្តក្នុងការធ្វើលំហាត់នេះលើកទីពីរដែរឬទេ ។

### ការបញ្ចប់កម្មវិធីធ្វើលំហាត់:

វាជាការល្អក្នុងការលើពីក្នុងក្រុមថា ៖ តើពួកគាត់គួរធ្វើអ្វីខ្លះនៅពេលពួកគាត់ត្រូវទៅសម្ភាសន៍ការងារមួយ? មូលហេតុអ្វីបានជាការរៀបចំអោយបានល្អទុកជាមុន មានសារៈសំខាន់មុនពេលទៅសម្ភាសន៍ការងារ?

## ចំណុចគន្លឹះសម្រាប់ជាជំនួយស្មារតីក្នុងការបណ្តុះបណ្តាល

នៅពេលសិក្ខាកាមម្នាក់បង្ហាញពីជំនាញទន់របស់គាត់ តាមរយៈមេរៀនដែលគាត់បានរៀន អ្នកសម្របសម្រួលត្រូវប្រាកដថា បាននិយាយអំពីជំនាញទន់នេះ ដើម្បីឲ្យសិក្ខាកាមអាចចាំ នៅពេលពួកគេប្រើប្រាស់ជំនាញទាំងនោះ ។

## សំណួរសម្ភាសន៍សម្រាប់សកម្មភាពទី១៥ (ប័ណ្ណព័ត៌មាន)

**សំណួរ:** សុំប្រាប់ខ្ញុំជួយរៀបរាប់ប្រាប់ខ្ញុំអំពីខ្លួនអ្នកឲ្យបានពីរនាទីមើល?

**ចម្លើយ:** អ្នកអាចនិយាយអំពីជំនាញ និង បទពិសោធន៍របស់អ្នក ដែលអាចសមនឹងការងារដូចម្តេច ។ និយាយអំពីចំណាប់អារម្មណ៍ និង ចំណូលចិត្តរបស់អ្នក ហើយតើជំនាញ និង បទពិសោធន៍ទាំងនោះ ជួយអ្នកដោយដូចម្តេចទៅនឹងការងារ ដែលអ្នកបានដាក់ពាក្យធ្វើការនោះ ។

**សំណួរ:** ហេតុអ្វីបានជាអ្នករកការងារធ្វើ?

**ចម្លើយ:** ចម្លើយដែលល្អបំផុតនោះ គឺជាចម្លើយដែលបង្ហាញអ្នកពីចំណាប់អារម្មណ៍ពីអ្វី ដែលអ្នកនឹងរៀន និងទទួលបានបទពិសោធន៍ពីការងារនៅកន្លែងដែលអ្នកកំពុងដាក់ពាក្យសុំធ្វើការនោះ ។ វាក៏ជាការល្អដែរក្នុងការឆ្លើយដោយមានគោលដៅ និង ផែនការពាក់ព័ន្ធនឹងលុយដែលអ្នកបានមក ការងារនោះ ។ និយោជកនឹងមើលឃើញថា អ្នកជាមនុស្សមានការតាំងចិត្តធ្វើការ ដើម្បីសម្រេចនូវគោលដៅរបស់អ្នក ។

**សំណួរ:** ហេតុអ្វីបានជាអ្នកចង់បានការងារបែបនេះ?

**ចម្លើយ:** នេះជាឱកាសល្អមួយក្នុងការបង្ហាញថា អ្នកបានធ្វើការសិក្សាអំពីក្រុមហ៊ុន ឬ និយោជក ដែលអ្នកបានដាក់ពាក្យមកធ្វើការ ។

**សំណួរ:** តើអ្នកមានចំណុចខ្លាំងអ្វីខ្លះ?

**ចម្លើយ:** ឧទាហរណ៍មួយចំនួន នៃចំណុចខ្លាំងនោះ គឺ មានភាពរីករាយ មានការជឿទុកចិត្ត មានគំនិតច្នៃប្រឌិត មានវិន័យ ចេះអត់ធ្មត់ មានឆន្ទះ មានការប្តេជ្ញាចិត្ត និង មានភាពស្មោះត្រង់ ។ល។

**សំណួរ:** តើអ្នកមានជំនាញអ្វីខ្លះមកប្រើប្រាស់ក្នុងការងារនេះ?

**ចម្លើយ:** រៀបចំបញ្ជី នៃមុខជំនាញរបស់អ្នកមុនពេលអ្នកចូលទៅសម្ភាសន៍ ។ បញ្ជីនេះ អាចរាប់បញ្ចូលទាំងការអប់រំ ជំនាញកំព្យូទ័រ និង ជំនាញភាសារបស់អ្នក ហើយនិងជំនាញទន់ដែលអ្នកបានរៀន ដូចជាការធ្វើទំនាក់ទំនង ការដោះស្រាយបញ្ហា ក្រោយមក អ្នកក៏អាចធ្វើបញ្ជី នៃលក្ខណ៍ឋានរបស់អ្នក ដូចជា ជាមនុស្សរោះរាយរាក់ទាក់ ហ្មត់ចត់ ស្វាហាប់ និង មានថាមវន្ត ។

**សំណួរ:** តើអ្នកអាចរៀបរាប់ពីលទ្ធភាពក្នុងការធ្វើការជាក្រុមដោយរបៀបណា?

**ចម្លើយ:** ចំណុចនេះ ជាចំណុចសំខាន់ដែលអ្នកត្រូវនិយាយបញ្ចុះបញ្ចូលអ្នកសម្ភាសន៍ អំពីរបៀបដែលអ្នកត្រូវធ្វើការជាក្រុម ។ អ្នកអាចគិតរកឧទាហរណ៍នៅពេលអ្នកធ្វើការក្នុងក្រុមឲ្យបានជោគជ័យ និង អ្វីដែល អ្នកត្រូវធ្វើក្នុងក្រុម ។

**សំណួរ:** តើសមិទ្ធផលដែលអ្នកសម្រេចបានធំបំផុតជាអ្វី?

**ចម្លើយ:** ចំណុចនេះ អ្នកអាចលើកយកឧទាហរណ៍ពីសាលា ការងារនៅផ្ទះ ឬ ការងារនៅអង្គភាពផ្សេងៗ ។ វាក៏ជាឱកាសមួយក្នុងការនិយាយអំពីចំណុចជោគជ័យខ្លះៗដែលអ្នកបានធ្វើ ។

**សំណួរ:** តើអ្នកមានសំណួរអ្វីដែរឬទេ?

**ចម្លើយ:** មុននឹងបញ្ចប់ការសម្ភាសន៍ អ្នកអាចមានសំណួរខ្លះ ដែលត្រូវសួរទៅក្រុមអ្នកសម្ភាសន៍ ។ វាអាចជាឱកាសមួយសម្រាប់អ្នកសួរក្រុមអ្នកសម្ភាសន៍នូវសំណួរជាច្រើនទៀតអំពីតួនាទីភារកិច្ចក្នុងការងារ អំពីក្រុមហ៊ុន ឬ សួរថាតើដំណើរការ នៃការជ្រើសរើសនេះស៊ីពេលប៉ុន្មាន ។ វាក៏បង្ហាញឲ្យនិយោជកដឹងថា អ្នកមានចំណាប់អារម្មណ៍នឹងការងារ ហើយអ្នកក៏ជាមនុស្សដែលបានត្រៀមរៀបចំខ្លួនក្នុងការសម្ភាសន៍ដែរ ។

## គ្រាប់អង្កាំ (ពណ៌ខៀវ)

នៅចុងបញ្ចប់ នៃមេរៀននេះ សុំឲ្យសិក្ខាកាមរើសយកអង្កាំពណ៌ខៀវ និង ដោតវាចូលក្នុងខ្សែ ។ សុំរំលឹកសិក្ខាកាមថា អង្កាំពណ៌ខៀវនេះ តំណាងឲ្យជំនាញទន់ ដែលពួកគេត្រូវការ ដើម្បីឲ្យពួកគេទទួលបានជោគជ័យក្នុងការងាររបស់ពួកគេ ។ សុំរំលឹកពួកគេផងដែរថា អង្កាំពណ៌ខៀវមួយគ្រាប់ តំណាងឲ្យជំនាញទន់ចំនួនប្រាំមួយ ។ អ្នកក៏អាចសុំឲ្យពួកគេនិយាយពីជំនាញទន់ទាំងប្រាំមួយនោះឡើងវិញ ក្នុងពេលកំពុងមើលអង្កាំពណ៌ខៀវរបស់ពួកគេ ។ លើកទឹកចិត្តសិក្ខាកាមឲ្យសហការជាមួយអ្នកអង្គុយជិតខ្លួន ក្នុងការដោតអង្កាំចូលក្នុងខ្សែ ដោយជួយគ្នាទៅវិញទៅមកក្នុងការចងខ្សែអង្កាំនោះព័ទ្ធជុំវិញកដៃរបស់ពួកគេ ហើយពិភាក្សាគ្នាថាតើខ្សែអង្កាំនោះមានន័យអ្វីចំពោះពួកគេ ។



# ០៩

# ការគ្រប់គ្រងប្រាក់របស់អ្នក



ការចាក់បញ្ចាំងរឿងវីដេអូបំផុសគំនិត (Inspirational video)

https://www.facebook.com/klahan9cambodia/videos/1064893473647650/

## គោលបំណង៖

- ការវាយតម្លៃខ្លួនឯងអំពីថាតើអ្នកប្រើប្រាស់ និង គ្រប់គ្រងចាត់ចែងលុយកាក់ដោយរបៀបណា
- យល់ពីអ្វីជាគោលបំណង នៃការសន្សំលុយ
- បញ្ចូលទស្សនៈទាន នៃថវិកាគោល និង ការសន្សំលុយឲ្យសម្រេចតាមគោលបំណង



# ៥.១. ការបែងចែកថវិកា

ណែនាំក្រុមសិក្ខាកាមឲ្យបានស្គាល់អ្វីជាលុយ ។ ពន្យល់ប្រាប់ក្រុមសិក្ខាកាមថា លុយគឺជាមធ្យោបាយទូទាត់សម្រាប់កិច្ចខិតខំប្រឹងប្រែង ឬ ការធ្វើការងារ ។ នៅពេលអ្នកចាប់ផ្តើមធ្វើការ អ្នកនឹងមានលុយ ។ ចេះពីរបៀបគ្រប់គ្រង និង ចាត់ចែងលុយកាក់ឲ្យមានប្រសិទ្ធិភាព គឺជារឿងសំខាន់ណាស់សម្រាប់អនាគតរបស់អ្នក ។ ហើយបើអ្នកមានចំណូលចិត្តក្នុងការបើកអជីវកម្មផ្ទាល់ខ្លួនវិញ វាក៏ជារឿងសំខាន់ដែរ ។

នៅពេលអ្នកចាប់ផ្តើមធ្វើការឲ្យគេ អ្នកត្រូវចុះកិច្ចព្រមព្រៀង ឬ កិច្ចសន្យាការងារ ដែលអ្នកគួរទទួលបានបៀវត្សរ៍ ឬ ប្រាក់ឈ្នួលទៀងទាត់តាមកាលកំណត់ ។ អ្នកនឹងមានការចំណាយមួយចំនួននៅពេលអ្នកមានការងារធ្វើ ។ អ្នកអាចត្រូវការទិញសម្លៀកបំពាក់ ថ្មីៗ ចំណាយលើការធ្វើដំណើរ ឬ ទិញសម្ភារៈ ឬ ឧបករណ៍ថ្មីៗ ។ ការចំណាយទាំងនេះ អាចនឹងមានការកើនឡើងយ៉ាងឆាប់រហ័ស ដូច្នេះ អ្នកត្រូវប្រាកដថា មានការត្រៀមខ្លួនជាស្រេច និង បែងចែកថវិកាក្នុងការជួយអ្នកគ្រប់គ្រង និង ចាត់ចែងលុយកាក់របស់អ្នក ។ វាជាគំនិតល្អណាស់ក្នុងការធ្វើផែនការចំណាយរៀងរាល់ថ្ងៃ ។ រៀបចំគោលដៅសន្សំលុយ និង គ្រប់គ្រងចាត់ចែងលុយកាក់របស់អ្នកដោយប្រុងប្រយ័ត្ន ។

ធ្វើការពិភាក្សាជាមួយក្រុមសិក្ខាកាមអំពីរបៀប ដែលពួកគេត្រូវគ្រប់គ្រង និង ចាត់ចែងលុយកាក់របស់ពួកគេ ។

១) តើពួកគេដឹងទេថាតើអ្វីទៅជាការបែងចែកថវិកា? បើពួកគេឆ្លើយថាដឹង សួរពួកគេទៀតថា តើអ្នកយល់អ្វីខ្លះអំពីការបែងចែកថវិកានេះ?
២) តើពួកគេដឹងទេថាតើហេតុអ្វីបានជាការបែងចែកថវិកាជារឿងសំខាន់?
៣) តើមាននរណាមួយគោលបំណងក្នុងការចំណាយថវិការបស់ខ្លួនដែរឬទេ? ឬ តើមាននរណា សន្សំលុយសម្រាប់ទិញអ្វីមួយដែរទេ? (សំណួរនេះ អាចជាសំណួរ ដែលងាយសម្រាប់ពួកគេឆ្លើយ)។

## សកម្មភាពទី ១៦



**ករណីសិក្សា៖**
**ការធ្វើផែនការថវិកា**

រយៈពេល នៃការធ្វើលំហាត់: **២០នាទី**

### គោលបំណង នៃការធ្វើលំហាត់:

- ដើម្បីកំណត់ដឹងថាតើអ្វីទៅជាផែនការថវិកា
- ដឹងពីរបៀបបែងចែកថវិកាដែលអាចជួយអ្នកបាន
- ដឹងពីរបៀបដែលអ្នកអាចចាប់ផ្តើមធ្វើផែនការថវិកា

## សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

https://www.facebook.com/klahan9cambodia/videos/1045319052271759/

## ដំណើរការ នៃការធ្វើលំហាត់:

- អ្នកសម្របសម្រួល ត្រូវចាក់បញ្ចាំងរឿងវីដេអូខ្លីៗពីបណ្តាញវេបសាយខាងលើឲ្យសិក្ខាកាមទាំងអស់មើល (ហើយអាស័យដ្ឋាន នៃវេបសាយនេះក៏មាននៅក្នុងឯកសារអប់រំដែរ) ។
- អ្នកសម្របសម្រួល ត្រូវសួរសិក្ខាកាមមើលថាតើពួកគេមានសំណួរអ្វីពាក់ព័ន្ធនឹងរឿងវីដេអូនេះដែរឬទេ ។ នៅពេលសិក្ខាកាមឆ្លើយសំណួរទាំងអស់រួចហើយ អ្នកសម្របសម្រួល ឲ្យសិក្ខាកាមមើលចំណុចខាង
- ក្រោមនេះម្តងមួយៗ ដោយទុកពេលឲ្យសិក្ខាកាមសួរសំណួរ/ពិភាក្សាគ្នាពីចំណុចមួយទៅចំណុចមួយ ៖
    - ការបែងចែកថវិកា គឺជាផែនការសរសេរ ដែលជួយអ្នកឲ្យបានដឹងថាតើអ្នកបានចំណាយលុយចំនួនប៉ុន្មាន ហើយអ្វីខ្លះដែលអ្នកត្រូវចំណាយលើវា ។
    - ផ្នែកដ៏សំខាន់ នៃថវិកា គឺប្រាក់ចំណូល (ប្រាក់ចំណូល ឧទាហរណ៍ លំហូរ នៃប្រាក់ នៃប្រាក់ចំណូលដែលបានមកពីថ្លៃឈ្នួល ឬ បៀវត្សរ៍) និង ការចំណាយ (ប្រាក់ចំណាយ ឧទាហរណ៍ ការចំណាយលើវិក័យប័ត្រផ្សេងៗ និង ម្ហូបអាហារ)។
    - ក្រោយពីអ្នកបានបញ្ចប់ការធ្វើការបែងចែកថវិការួចមក គណនាលើចំណូល និង ចំណាយ ដើម្បីឲ្យឃើញចំនួនសរុបលើចំណូល និង ចំណាយទាំងនោះ ។
    - បន្ទាប់មក អ្នកត្រូវធ្វើប្រមាណវិធី យកចំណាយដកនឹងចំណូលរបស់អ្នក ។
    - ប្រសិនបើអ្នកមានចំនួនលុយនៅសល់ នេះគេហៅថា ចំនួនលុយនៅសល់ពីការចំណាយ ។ ប្រសិនបើការចំណាយរបស់អ្នកច្រើនជាងចំណូល នេះគេហៅថា ចំណាយលើសចំណូល ។
    - ប្រសិនបើអ្នកមានចំណាយលើសចំណូល អ្នកត្រូវកាត់បន្ថយការចំណាយ ឬ ត្រូវបង្កើនចំណូលរបស់អ្នក ។
    - សម្រាប់ការធ្វើការបែងចែកថវិកាសម្រាប់ការធ្វើការងារវិញ អ្នកក៏ត្រូវធ្វើតាមរបៀបនេះដែរ ។

### ថ្លៃចំណាយប្រចាំសប្តាហ៍

| ថ្លៃធ្វើដំណើរ | សម្លៀកបំពាក់ | ថ្លៃផ្ទះ | ថ្លៃទឹក | គ្រឿងទេស | ថ្លៃភ្លើង | ហ្គាស | ថ្លៃទូរស័ព្ទ |
|---|---|---|---|---|---|---|---|
| ៤០០០០រៀល | ៣០០០០រៀល | ៨០០០០រៀល | ១០០០០រៀល | ៣០០០០រៀល | ២០០០០រៀល | ១៥០០០រៀល | ៨០០០រៀល |

តើអ្នកសល់ប៉ុន្មានបន្ទាប់ពីការចំណាយទាំងអស់នេះ?

## ការបញ្ចប់កម្មវិធីធ្វើលំហាត់:

វាជារឿងមួយដែលមានប្រយោជន៍ដែរក្នុងការពិភាក្សាគ្នាថាតើក្រុមសិក្ខាកាមចំណាយលុយលើអ្វីខ្លះក្នុងមួយសប្តាហ៍ៗ ដូចជា ការចំណាយលើរបស់របរប្រើប្រាស់ក្នុងផ្ទះ គ្រឿងទេស មធ្យោបាយធ្វើដំណើរ ថ្លៃទឹក ថ្លៃភ្លើង ថ្លៃហ្គាស់ ថ្លៃសេវាអ៊ិនធើណែត និង សម្លៀកបំពាក់ ។ល។ តើនៅមានរបស់អ្វីផ្សេងទៀត ដែលសិក្ខាកាមត្រូវចំណាយលុយលើវាដែរទេ?

អ្នកសម្របសម្រួល ត្រូវសួរក្រុមសិក្ខាកាម ប្រសិនបើមានសិក្ខាកាមណាមួយមានការបែងចែកថវិការ ហើយនៅក្នុងខ្ទង់ថវិកានោះមានរាប់បញ្ចូលរបស់អ្វីជាការចំណាយក្នុងនោះហើយឬនៅ? អ្នកអាចធ្វើតាមចំណុចនេះម្តង ហើយអ្នកអាចនឹងមានការសប្បាយចិត្តក្នុងការជជែកជាមួយក្រុមសិក្ខាកាមយើងទាំងអស់គ្នា ។

# ៩.២. ការសន្សំលុយ

សុំអានអត្ថបទខាងក្រោមនេះ ឲ្យក្រុមសិក្ខាកាមស្តាប់ទាំងអស់គ្នា ហើយក្រោយមក សួរសំណួរដល់សិក្ខាកាម អំពីអត្ថបទខាងក្រោមនេះ ដើម្បីចាប់ផ្តើមពិភាក្សាលើការសន្សំប្រាក់ ៖

“ **ហេង** មានជំនាញក្នុងការអនុវត្តតាមការបែងចែកថវិការបស់គាត់ ។ គាត់បំរើការជាអ្នកថែសួន ហើយគាត់ទើបតែបានទទួលការតម្លើងប្រាក់ឈ្នួល ៤០ ដុល្លារ ក្នុងរយៈពេលពីរសប្តាហ៍ ។ មានន័យថា គាត់កើនលុយបានចំនួន ៤០ ដុល្លារទៀត ដែលជាលុយ ដែលគាត់មិនទាន់បានដាក់បញ្ចូលក្នុងផែនការថវិការបស់គាត់នៅឡើយទេ” ។

- តើ **ហេង** គួរធ្វើអ្វីសម្រាប់លុយ ដែលគាត់ទទួលបានបន្ថែមមកទៀតនេះ?

អ្នកអាចប្រើសំណួរនេះ ក្នុងការពិភាក្សាពីរបៀប ដែលគាត់ត្រូវចំណាយលុយលើអ្វីៗ ដែលគាត់ចូលចិត្ត ដូចជា ស្បែកជើង និង សម្លៀកបំពាក់ ឬ យ៉ាងហោចណាស់ ក៏គាត់អាចទុកលុយបានមកបន្ថែមនេះទៅក្នុងកម្មវិធីនៃប្រាក់សន្សំរបស់គាត់ ។

## សកម្មភាពទី ១៧



**ចំណុចគន្លឹះសម្រាប់ជាជំនួយស្មារតី ក្នុងការសន្សំប្រាក់**

រយៈពេល នៃការធ្វើលំហាត់: **១៥ នាទី**

### គោលបំណង នៃការធ្វើលំហាត់:

- ដើម្បីជួយកំណត់ឲ្យបានដឹងពីសារៈសំខាន់ នៃការសន្សំប្រាក់
- ដើម្បីកំណត់ឲ្យបានដឹងថាតើសិក្ខាកាមមានគោលដៅ នៃការសន្សំប្រាក់ហើយឬនៅ
- ដឹងពីរបៀបដែលអ្នកអាចចាប់ផ្តើមធ្វើការដើម្បីសម្រេចគោលដៅ នៃការសន្សំប្រាក់របស់អ្នក

### សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

https://www.facebook.com/klahan9cambodia/videos/953238501479815/

## ដំណើរការ នៃការធ្វើលំហាត់:

- >> អ្នកសម្របសម្រួល ត្រូវចាក់បញ្ចាំងរឿងវីដេអូខ្លីពីវេបសាយខាងលើឲ្យសិក្ខាកាមទាំងអស់មើល (ហើយអាស័យដ្ឋាន នៃវេបសាយនេះក៏មាននៅក្នុងឯកសារអប់រំដែរ)
- >> អ្នកសម្របសម្រួល ត្រូវសួរសិក្ខាកាមមើលថាតើពួកគេមានសំណួរអ្វីពាក់ព័ន្ធនឹងរឿងវីដេអូនេះដែរឬទេ ។
- >> នៅពេលសិក្ខាកាមឆ្លើយសំណួរទាំងអស់រួចហើយ អ្នកសម្របសម្រួល ឲ្យសិក្ខាកាមមើលចំណុចខាងក្រោមនេះម្តងមួយៗ ដោយទុកពេលឲ្យសិក្ខាកាមសួរសំណួរ/ពិភាក្សាគ្នាពីចំណុចមួយទៅចំណុចមួយ ៖
  - ការសន្សំលុយ គឺជាការយកលុយខ្លះទុកសម្រាប់ប្រើប្រាស់នាពេលអនាគត ។
  - ការសន្សំលុយ គឺជាការជួយអ្នកក្នុងការចំណាយទិញរបស់របរ ដែលត្រូវចំណាយលុយច្រើន ។
  - ការដែលបានសន្សំលុយ គឺវាបានជួយអ្នកនៅពេលដែលអ្នកត្រូវការចំណាយបន្ទាន់ ឬ ត្រូវការចំណាយ ដោយមិនមានការត្រៀងទុកមុន ។
  - ការសន្សំលុយ គឺជាការជួយអ្នកឲ្យធ្វើផែនការ ។
  - ព្យាយាមសន្សំលុយឲ្យបានញឹកញាប់តាមដែលអាចសន្សំបាន ។
  - ផែនការសន្សំលុយនឹងជួយអ្នកឲ្យបានដឹងពីរបៀបដែលអ្នកអាចសន្សំលុយបានញឹកញាប់ប៉ុណ្ណា ។
  - ប្រសិនបើអ្នកអាចធ្វើបាន ចូរសន្សំលុយរបស់អ្នកនៅកន្លែងដែលមានសុវត្ថិភាពដូចជានៅធនាគារ ។
  - សន្សំលុយ ដើម្បីទិញរបស់អ្វីមួយ ដែលអ្នកចង់បាន និង កំណត់នូវគោលដៅ នៃការចំណាយថវិកានោះ ។
  - សន្សំលុយសម្រាប់ពេលមានអាសន្ន មានន័យថា អ្នកបានត្រៀមខ្លួនសម្រាប់រឿងរ៉ាវអ្វីមួយ ដែលអ្នកមិនបានគ្រោងថាវានឹងកើតមានឡើង ។

## ការបញ្ចប់កម្មវិធីធ្វើលំហាត់:

អ្នកសម្របសម្រួល ត្រូវនិយាយប្រាប់ក្រុមសិក្ខាកាមថា ការសន្សំប្រាក់ មិនមែនជារឿងដែលយើងមិនអាចធ្វើបាននោះទេ ។ សំខាន់ គឺត្រូវសម្រេចឲ្យបាននូវគោលដៅនៃការសន្សំប្រាក់លើកទី១ របស់អ្នកជាជាងការរៀបចំគោលដៅធំពេក ព្រោះថាការចាប់ផ្តើមសន្សំដំបូងនេះនឹងជួយឲ្យអ្នកអនុវត្តការសន្សំប្រាក់ ។

# ៥.៣. ប្រាក់បំណុល និង ប្រាក់កម្ចី

ប្រធានបទនេះ និយាយអំពីប្រាក់បំណុល ។ ប្រធានបទនេះ នឹងពន្យល់អំពីអ្វីទៅជាប្រាក់បំណុល និង អ្វីទៅជាការសងប្រាក់បំណុលវិញ ។ ប្រធានបទនេះ នឹងមើលវិធី ដែលអ្នកអាចខ្ចីលុយគេ និង តើវានឹងមានរឿងអ្វីកើតឡើងនៅពេលលុយដែលអ្នកបានខ្ចីគេនោះ បែរជាមិនបានសងគេវិញទាន់ពេល ។

អ្នកត្រូវមានការប្រុងប្រយ័ត្នខ្ពស់នៅពេលសម្រេចចិត្តថានឹងត្រូវធ្លាក់ខ្លួនជាបបំណុលគេ ។ ប្រសិនបើអ្នកទទួលយកប្រាក់កម្ចី វិធីល្អបំផុត ក្នុងការគ្រប់គ្រង និង ចាត់ចែងប្រាក់បំណុលរបស់អ្នក គឺមិនត្រូវសងប្រាក់បំណុលវិញយឺតយ៉ាវនោះទេ ។ ប្រសិនបើអ្នកមិនអាចសងប្រាក់បំណុលរបស់គេទាំងអស់បានទេ គឺត្រូវព្យាយាមសងគេឲ្យបានខ្លះ និង អ្នកគួរទាក់ទងជាមួយម្ចាស់បំណុលរបស់អ្នក ដោយត្រូវប្រាប់គេឲ្យបានដឹងថាអ្នកអាចបង់ប្រាក់កម្ចីនេះបានខ្លះតែប៉ុណ្ណោះ ។ សំខាន់ គឺអ្នកត្រូវធ្វើអ្វីម្យ៉ាង ប្រសិនបើអ្នកមានបញ្ហាក្នុងការសងប្រាក់បំណុលទៅឲ្យម្ចាស់បំណុលវិញ ។ អ្នកមិនត្រូវប្រងើយកន្តើយនឹងរឿងនេះទេ ។ ត្រូវប្រាប់ម្ចាស់បំណុលឲ្យបានដឹងថា អ្នកកំពុងជួបនូវបញ្ហា និង ព្យាយាមសងបំណុលនេះ តាមអ្វីដែលខ្លួនមានលទ្ធភាពសងតែប៉ុណ្ណោះ ។

ករណីសិក្សាខាងក្រោមនេះ នឹងបង្ហាញពីការអប់រំលើប្រាក់កម្ចី និង ក្រុមលេងអ្នកតុងទីន ដើម្បីសន្សំប្រាក់ ។

## សកម្មភាពទី ១៨

**ប្រាក់បំណុល និង ប្រាក់កម្ចី**



រយៈពេល នៃការធ្វើលំហាត់: ៣០ នាទី

**គោលបំណង នៃការធ្វើលំហាត់:**

- ដើម្បីបានដឹងពីការផ្តល់ព័ត៌មានគួរពិចារណាមុននឹងទទួលយកប្រាក់កម្ចី

**សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)**

https://www.facebook.com/klahan9cambodia/videos/878856675584665/

https://www.facebook.com/klahan9cambodia/videos/878934012243598/

## ដំណើរការ នៃការធ្វើលំហាត់:

- អ្នកសម្របសម្រួល ត្រូវចាក់បញ្ចាំងរឿងវីដេអូខ្លីពីបណ្តាញវេបសាយខាងលើឲ្យសិក្ខាកាមទាំងអស់មើល (ហើយអាស័យដ្ឋាន នៃបណ្តាញវេបសាយនេះក៏មាននៅក្នុងឯកសារអប់រំដែរ)
- បន្ទាប់ពីមើលរឿងវីដេអូខ្លីៗរួច អ្នកសម្របសម្រួល ត្រូវសួរសិក្ខាកាមនូវសំណួរមួយចំនួន ដូចខាងក្រោមនេះ ។
- ក្រុមរបស់អ្នកអាចសរសេរចម្លើយរបស់សិក្ខាកាមទុកផង ឬ អ្នកអាចដាក់ពាក្យថា យក នៅផ្នែកណាមួយក្នុងបន្ទប់ និង ដាក់ពាក្យថា មិនយក នៅផ្នែកម្ខាងទៀត នៃបន្ទប់ ហើយដែលសិក្ខាកាមអាចដើរទៅរកផ្នែកណាមួយ ដែលពួកគេយល់ស្របជាមួយនឹងលក្ខខ័ណ្ឌនោះ ។

- តើពួកគេទទួលយកប្រាក់កម្ចីក្នុងគោលដៅសិក្សាអប់រំដែរឬទេ?
    - បើចម្លើយឆ្លើថា មិនយក សួរតទៀតថា ហេតុអ្វីបានជាមិនយកប្រាក់កម្ចីនេះ?
    - បើចម្លើយឆ្លើយថា យក
        - តើមានជម្រើសអ្វីផ្សេងក្នុងការទទួលយកប្រាក់កម្ចីពីគ្រឹះ ស្ថានមីក្រូហិរញ្ញវត្ថុដែរឬទេ (MFI)?
        - ប្រសិនបើពួកគេត្រូវទទួលយកប្រាក់កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬ ធនាគារ តើមានសិក្ខាកាមប៉ុន្មាននាក់ ក្នុងការទៅមើលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងនោះ ដើម្បីសិក្សាឲ្យបានយល់ពីអត្រាការប្រាក់ ថ្លៃសេវាពាក់ព័ន្ធផ្សេងៗ ឬ ការទាមទារនូវតម្រូវការអ្វីខ្លះ ដើម្បីឲ្យពួកគេមានសិទ្ធិទទួលបានប្រាក់កម្ចីនោះ មុននឹងសម្រេចចិត្តទទួលយក ប្រាក់កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុណាមួយ ។
        - តើមានការដាក់វត្ថុអ្វីបញ្ចាំ ដើម្បីជានាប៉ំណុលដែរឬទេ?
        - តើរយៈពេលយូរប៉ុន្មាន ទើបត្រូវសងបំណុលគេឲ្យរួច?
        - តើវានឹងទទួលបានអ្វីពីប្រាក់កម្ចី ឬ ការវិនិយោគលើការអប់រំនេះមកវិញ?

អ្នកសម្របសម្រួល ត្រូវពន្យល់សិក្ខាកាមថា នេះគឺជាដំណើរការមួយ នៅពេលដែលពួកគេចង់ទទួលយកប្រាក់កម្ចី ដោយសារមូលហេតុមួយចំនួន ពីព្រោះ ៖

១) ប្រាក់កម្ចី មានន័យថា ប្រាក់បំណុល ហើយបំណុល គឺជាប្រាក់ ដែលអ្នកជំពាក់គេ និង ត្រូវសងគេវិញ ហើយពេលខ្លះ អាចនឹងត្រូវសងការប្រាក់ខ្ពស់ទៀតផង ។
២) អ្នកអាចនឹងជួបនូវបញ្ហាមួយចំនួន ប្រសិនបើអ្នកមិនសងប្រាក់បំណុលរបស់អ្នកទេ ។
៣) ប្រសិនបើអ្នកមិនសងប្រាក់បំណុលរបស់អ្នកទេ អ្នកអាចនឹងបាត់បង់នូវអ្វីដែលជាវត្ថុបញ្ចាំដើម្បីជានាបំណុលនោះ ។
៤) ឥណទាន គឺជាលុយដែលអ្នកខ្ចីគេ ហើយលុយនេះ ក៏អ្នកត្រូវសងគេវិញដែរ ។
៥) ឥណទាន មានការចំណាយលើសេវាជាច្រើនផ្សេងទៀត ។
៦) ការទទួលនូវប្រាក់កម្ចីឥណទានច្រើនពេក អាចបណ្តាលឲ្យប្រាក់កម្ចីឥណទាននេះមានបញ្ហាច្រើន ។
៧) គ្រឹះស្ថានហិរញ្ញវត្ថុ និង ធនាគា គឺជាគ្រឹះស្ថានផ្តល់នូវប្រាក់កម្ចីឥណទាន ។
៨) អ្នកត្រូវបង់ការប្រាក់ ថ្លៃសេវា និង ប្រាក់ពិន័យផ្សេងៗក្នុងការប្រើប្រាស់ប្រាក់កម្ចីឥណទាននេះ ។
៩) ត្រូវសួរសំណួរជាច្រើន មុននឹងចុះហត្ថលេខាលើកិច្ចសន្យា នៃប្រាក់កម្ចីឥណទាន ។

បន្ទាប់ពីសិក្ខាកាមម្នាក់ៗបានបញ្ចប់ការមើលចំណុចខាងលើរួចហើយ អ្នកសម្របសម្រួល ត្រូវសួរសិក្ខាកាមថាតើពួកគេធ្លាប់ឮអំពីការលេងតុងទីនដែរទេ ។ រំលឹកពួកគេថា ការលេងតុងទីន ក៏ជាប្រាក់បំណុលមួយប្រភេទដែរ នៅពេលអ្នកសម្រេចចិត្តលេងតុងទីន ។ ត្រូវទទួលស្គាល់ថា អ្នកលេងតុងទីនខ្លះ គឺដើម្បីសន្សំលុយ ប៉ុន្តែសូមបញ្ជាក់ថា ការសន្សំលុយបែបនេះ មានហានិភ័យខ្ពស់ខ្លាំងណាស់ ព្រោះថាសមាជិកទាំងអស់នៃសមាគមសន្សំប្រាក់បែបនេះ មិនបានចុះហត្ថលេខាលើក្រដាសស្នាម ឬ កិច្ចសន្យា លេងតុងទីននោះទេ និង ក្នុងករណីជាច្រើន អ្នកក៏មិនបានពិនិត្យផ្ទៀងផ្ទាត់នូវសារៈតា របស់អ្នកលេង ទាំងអស់នោះដែរ ។

## ការបញ្ចប់កម្មវិធីធ្វើលំហាត់:

អ្នកសម្របសម្រួល ត្រូវរំលឹកក្រុមសិក្ខាកាមម្តងហើយម្តងទៀតថា ការទទួលយកប្រាក់កម្ចី និង ការមិនអាចសងគេវិញ តាមផែនការ ឬ កាលវិភាគ នៃការសងប្រាក់ទេ វាអាចធ្វើឲ្យអ្នកឋិតក្នុងស្ថានភាពថប់ក្នុងអារម្មណ៍ជាខ្លាំង ។ រំលឹកក្រុមសិក្ខាកាមទៀតថា ប្រសិនបើសិក្ខាកាមណាមួយកំពុងឋិតក្នុងស្ថានភាពហិរញ្ញវត្ថុបែបនេះ សិក្ខាកាមនោះ ប្រាកដជាមានការបារម្ភណ៍អំពីបញ្ហានេះ ដូច្នេះសិក្ខាកាមនោះ ត្រូវនិយាយជាមួយជនណាមួយ ដែលខ្លួនមានការជឿជាក់ ។

# ៥.៤. ការបែងចែកថវិកា

ដូចយើងបានរៀនពីខាងដើមស្រាប់ហើយថា ការបែងចែកថវិកា គឺផែនការសរសេរ ដែលជួយអ្នកឲ្យបានដឹងថា តើអ្នកមានលុយចំនួនប៉ុន្មាន និង តើអ្នកត្រូវការចំណាយវាលើអ្វីខ្លះ ។ ការបែងចែកថវិកា ជួយអ្នកឲ្យតាមមើលនូវអ្វីដែលអ្នកកំពុងចំណាយ ចំណែកឯការបែងចែកថវិកាសម្រាប់ការធ្វើការងារវិញ អ្នកក៏ត្រូវការយកលំនាំតាមវានេះដែរ ។

ក្នុងការធ្វើផែនការថវិការ អ្នកត្រូវធ្វើសេចក្តីសម្រេចអំពីការចំណាយ ។ ផ្នែកនេះ នឹងមើលថាតើអ្នកត្រូវបញ្ចូលអ្វីនៅក្នុងខ្ទង់ថវិការបស់អ្នក ដោយត្រូវគិតពីអ្វី ដែលសំខាន់ ឬ អ្វីដែលមិនសំខាន់ ។




## សកម្មភាពទី ១៩

### ការចំណាយតាមតម្រូវការ និង ការចំណាយតាមការចង់បាន

រយៈពេល នៃការធ្វើលំហាត់: **២០ នាទី**

## គោលបំណង នៃការធ្វើលំហាត់:

- សកម្មភាពនេះនឹងជួយក្រុមសិក្ខាកាមឲ្យបានយល់ពីភាពខុសគ្នារវាងអ្វីសំខាន់ (របស់ត្រូវការ) ក្នុងការដាក់បញ្ចូលក្នុងខ្ទង់ថវិកា និង អ្វីដែលមិនសំខាន់ ។
- ដើម្បីកំណត់ឲ្យសិក្ខាកាមបានដឹងថា មានរបស់ដែលអ្នកត្រូវការ ដើម្បីរស់ ដូចជា ម្ហូបអាហារ ទឹក និង ជម្រក (ផ្ទះ ឬ បន្ទប់ជួល) ។
- ដើម្បីកំណត់ឲ្យសិក្ខាកាមបានដឹងថា មានរបស់ដែលមិនសំខាន់ (របស់ចង់បាន) ។ អ្នកអាចចង់បានរបស់ទាំងនេះ ប៉ុន្តែ របស់ទាំងនោះ មិនមែនជារបស់ដែលអ្នកត្រូវការ ដើម្បីបំរើដល់ជីវិតរស់នៅនោះទេ ។

## សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

កាតផ្ទុកព័ត៌មានសម្រាប់សកម្មភាពទី២០

## ដំណើរការ នៃការធ្វើលំហាត់:

- >> សិក្ខាកាមធ្វើការរួមគ្នាជាក្រុមតូចៗដែលមានគ្នាពីរនាក់ ។ ក្នុងក្រុមតូចនីមួយៗ ទទួលបានកាតផ្ទុកព័ត៌មានមួយឈុត ។ បន្ទាប់ពីទទួលបានកាតផ្ទុកព័ត៌មានមួយឈុតនេះហើយ សិក្ខាកាម ត្រូវប្រមូលរបស់ ក្នុងកាតផ្ទុកព័ត៌មាននោះ ដើម្បីគិតមើលថាអ្វីជារបស់ដែលត្រូវការ និង ប្រមូលរបស់ក្នុងកាតព័ត៌មានមួយទៀត ដែលសិក្ខាកាម ត្រូវគិតពីរបស់អ្វីដែលខ្លួនចង់បាន ។ សិក្ខាកាមក៏អាចប្រមូលរបស់ទាំងអស់នោះ ដាក់ឲ្យ នៅជាច់ៗពីគ្នា ដើម្បីកំណត់ឲ្យដឹងថា អ្វីដែលពួកគេយល់ស្របតាម និង អ្វីដែលមិនគួរយល់ស្របតាម ។
- >> អ្នកសម្របសម្រួល ត្រូវពិភាក្សាជាមួយក្រុមសិក្ខាកាមពីរបៀប ដែលពួកគេធ្វើសេចក្តីសម្រេចចិត្តរបស់ពួកគេ ។
- >> បន្ទាប់មក អ្នកសម្របសម្រួល ត្រូវសួរក្រុមសិក្ខាកាមនីមួយៗថាតើពួកគេអាចកំណត់អាទិភាព នៃ "របស់ត្រូវការ" ដែលត្រូវដាក់បញ្ចូលក្នុងបញ្ជី នៃរបស់ដែលត្រូវជ្រើសរើសនោះបានដែរឬទេ ?
- >> អ្នកសម្របសម្រួល ត្រូវជួយសិក្ខាកាមឲ្យបានយល់ថា ពួកគេត្រូវដាក់បញ្ចូលរបស់សំខាន់ៗនៅក្នុងខ្ទង់ថវិការបស់ពួកគេ ។
- >> នៅពេលក្រុមសិក្ខាកាមទាំងអស់បានបញ្ចប់សកម្មភាពទាំងនេះ អ្នកសម្របសម្រួល ត្រូវនាំក្រុមសិក្ខាកាមទាំងអស់ឲ្យមកជួបជុំគ្នាវិញ និង ធ្វើការប្រៀបធៀបអំពីលទ្ធផលរបស់ពួកគេ ។ តើបញ្ជីមួយណាដែលមានគំនរ នៃ "របស់ត្រូវការ" ឬ "របស់ចង់បាន" ធំជាងគេ? តើរបស់អ្វីខ្លះដែលពួកគេឯកភាពជាមួយសកម្មភាពនេះ នឹងជួយក្រុមសិក្ខាកាមឲ្យបានយល់ពីភាពជាមួយ? សួរក្រុមសិក្ខាកាមទាំងអស់មើលប្រសិនបើពួកគេត្រូវយករបស់អ្វីពីរយ៉ាងចេញពីបញ្ជី នៃគំនរ "របស់ត្រូវការ" និង ដាក់វាទៅក្នុងបញ្ជី នៃគំនរ "របស់ចង់បាន" តើពួកគេជ្រើសរើសយកអ្វីខ្លះ?

### ការបញ្ចប់កម្មវិធីធ្វើលំហាត់:

បន្តការពិភាក្សានូវសំណួរ ដូចជា ៖

- >> តើអ្នកគ្រប់គ្នាត្រូវការរបស់ដូចគ្នាឬ?
- >> តើមនុស្សធំត្រូវការរបស់ដូចគ្នានឹងកុមារដែរឬ?
- >> ប្រសិនបើមានការជ្រើសរបស់ផ្សេងគ្នា តើរបស់ទាំងនោះជារបស់អ្វីទៅ?

## ប័ណ្ណព័ត៌មានសម្រាប់សកម្មភាពទី១៩

| របស់ត្រូវការ | | របស់ចង់បាន | |
|---|---|---|---|
| >> របស់របរប្រើប្រាស់ក្នុងផ្ទះ | >> គ្រឿងទេស | >> បារី | >> ទូរស័ព្ទចល័ត |
| >> មធ្យោបាយធ្វើដំណើរ | >> ថ្លៃភ្លើង | >> ក្បាលឌីវីឌី (DVD's) | >> ហ្គេមវីដេអូ (Video games) |
| >> ថ្លៃហ្គាស់ | >> ថ្លៃទឹក | >> ការ៉េម | |
| >> ថ្លៃអ៊ីនធើណែត | >> ថ្លៃសម្លៀកបំពាក់ | >> គ្រឿងអលង្ការ | |
| >> ថ្លៃឱសថ | | | |

# គ្រាប់អង្កាំ (ពណ៌ក្រហម)

នៅចុងបញ្ចប់ នៃមេរៀននេះ សុំឲ្យសិក្ខាកាមរើសយកអង្កាំពណ៌ក្រហមមួយគ្រាប់ រួចដោតវាចូលក្នុងខ្សែ ។ ចូររំលឹកសិក្ខកាម ចំពោះការដែលមានអង្កាំក្រហមគឺបញ្ជាក់ពីហានិភ័យដែលមានន័យថា ពួកគេអាចក្លាយជាអ្នកជំនាញក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ពួកគេ។ពួកគេដឹងហើយថាតើអ្វីទៅជាប្រាក់បំណុលនោះ តើវាអាចនាំឲ្យផលវិបាលអ្វីខ្លះ ប្រសិនបើពួកគេមិនអាចសងប្រាក់បំណុលគេវិញបានទេ ។ តើពួកគេអាចសន្សំលុយរបស់ពួកគេតាមការបែងចែកថវិកាត្រឹមត្រូវពីចំណូលរបស់ពួកគេដោយរបៀបណា ហើយតើពួកគេអាចបែងចែកភាពខុសគ្នារវាងអ្វី ដែលពួកគេចង់បាន និង អ្វីដែលពួកគេត្រូវបានដោយរបៀបណា ។ ជម្រុញឲ្យសិក្ខាកាមសហការជាមួយអ្នកដែលអង្គុយជិតខ្លួន ដើម្បីជួយដោតគ្រាប់អង្កាំចូលក្នុងខ្សែ និងជួយគ្នាទៅវិញទៅមកក្នុងការចងខ្សែអង្កាំនោះព័ទ្ធជុំវិញកដៃរបស់ពួកគេ រួចពិភាក្សាគ្នាថា តើខ្សែអង្កាំនោះមានន័យយ៉ាងណាចំពោះពួកគេ ។



# ០៦

# ជំហានបន្ទាប់

# ក្នុងការសម្រេចគោលបំណងរបស់អ្នក



ការចាក់បញ្ចាំងរឿងវីដេអូបំផុសគំនិត (Inspirational video)
https://www.facebook.com/klahan9cambodia/videos/1027876534016011/

## គោលបំណង៖

- បង្ហាញសកម្មភាព ក្នុងការជួយដល់ផែនការសម្រាប់ការធ្វើការងារ និង ការសន្សំលុយដើម្បីឲ្យបានសម្រេចគោលបំណង ។
- កំណត់នូវចំណុចគ្រោះថ្នាក់សំខាន់ៗ (ឧ. បងប្រុសរបស់ខ្ញុំចង់ខ្ចីលុយគេ ដោយសារប្រពន្ធគាត់ មានផ្ទៃពោះ ឬ ឈឺ ) ។
- ធ្វើការពិភាក្សាពីលក្ខខ័ណ្ឌរបស់វា តាមរយៈ ការប្រើពាក្យ “នៅពេលណា, ប្រសិនបើ) ឧ. ចំណុចគ្រោះថ្នាក់ដែលនឹងអាចកើតឡើង ។ វិធីរក្សានូវទំនាក់ទំនងតាមរយៈការបង្ហាញផ្លូវ ទីភ្នាក់ងារជាតិមុខរបរ និង ការងារ




## សកម្មភាពទី ២០

### ផែនការសកម្មភាពរបស់ខ្ញុំ

រយៈពេល នៃការធ្វើលំហាត់: ៤៥ នាទី



## គោលបំណង នៃការធ្វើលំហាត់:

- ដើម្បីលើកទឹកចិត្តសិក្ខាកាមឲ្យរៀបរាប់ពីគោលដៅរបស់ពួកគេ និង កំណត់សកម្មភាពក្នុងការបង្កើតគោលដៅនេះ
- ដើម្បីឲ្យសិក្ខាកាមចែករំលែកនូវគោលដៅនេះជាមួយនឹងមិត្តភក្តិ និង សមាជិកគ្រួសាររបស់ពួកគេ
- ដើម្បីផ្តល់នូវទិដ្ឋភាពទូទៅ នៃអ្វីដែលពួកគេបានរៀន

## សម្ភារៈសិក្សា (រួមមាន ការប្រើប្រាស់ខ្លឹមសារ នៃមេរៀន)

តារាងអត្ថបទសកម្មរបស់ខ្ញុំសម្រាប់ចែកឲ្យសិក្ខាកាមម្នាក់ៗ

## ដំណើរការ នៃការធ្វើលំហាត់:

ក្នុងពេលធ្វើសកម្មភាពនេះ សិក្ខាកាម ត្រូវចំណាយពេលបំពេញតារាងផែនការសកម្មភាពរបស់ខ្ញុំ ។ អ្នកសម្របសម្រួល ត្រូវឲ្យសិក្ខាកាមយកផែនការសកម្មភាព ដែលជារបស់ពួកគេចេញមក និង សុំឲ្យពួកគេបំពេញវាជាក្រុមដែលមានគ្នាពីរនាក់ ឬ ធ្វើម្នាក់ឯង ឲ្យពួកគេធ្វើយ៉ាងម៉េចក៏បាន ឲ្យតែពួកគេយល់ថាមានភាពងាយស្រួលសម្រាប់ពួកគេ ។ សុំឲ្យពួកគេបិទភ្នែក និង សុំឲ្យពួកគេពិតជាគិតពីអ្វី ដែលពួកគេត្រូវធ្វើ ដើម្បីឲ្យបានសម្រេចគោលដៅរបស់ពួកគេ ។

ឥឡូវនេះ អ្នកសម្របសម្រួល ត្រូវសួរសិក្ខាកាមនូវសំណួរ ដូចខាងក្រោមនេះ ៖

- តើជំនាញអ្វីខ្លះដែលអ្នកចង់រៀន?
- តើអ្នកត្រូវការនរណាឲ្យមកជួយអ្នក?
    - តើអ្នកចង់ធ្វើឲ្យគោលដៅរបស់អ្នកបានសម្រេចនៅពេលណា? តើអ្នកមានបានកំណត់ថ្ងៃខែច្បាស់លាស់ដែរឬទេ? តើហេតុអ្វីបានជាអ្នកសម្រេចជ្រើសរើសយកថ្ងៃនេះ?
- តើអ្នកអាចប្រឈមនឹងឧបសគ្គអ្វីខ្លះក្នុងដំណើរផ្លូវដ៏វែងឆ្ងាយនេះ ហើយតើអ្នកអាចជំនះ ឧបសគ្គ
- ទាំងអស់នេះបានដោយរបៀបណា?

ប្រសិនបើអ្នកមានការជឿជាក់ ល្មមក្នុងការធ្វើបែបនេះ ហេតុអ្វីបានជាអ្នកមិនចែករំលែកនូវគោលដៅ និង សកម្មភាព ដែលអ្នកនឹងត្រូវធ្វើ និង នៅពេលណាទើបអ្នកចែករំលែកនូវគោលដៅ និង សកម្មភាពនេះ ជាមួយសិក្ខាកាមផ្សេងទៀតក្នុងក្រុម មិត្តភក្តិ សមាជិកគ្រួសារ ឬ អ្នកអង្គុយជិតអ្នក ។

## ឧទាហរណ៍៖

**ខ្ញុំឈ្មោះ សេរី** អាយុ១៩ឆ្នាំ រស់នៅខេត្តបាត់ដំបង ។
ខ្ញុំមានគោលដៅបើកហាងកាហ្វេនៅពេលខ្ញុំមានអាយុ២១ឆ្នាំ ។
នេះជាសកម្មភាពមួយចំនួនដែលខ្ញុំត្រូវធ្វើមាន ៖

១. រៀនបន្ថែមទៀតពីការចាប់ផ្តើមបើកអាជីវកម្មផ្ទាល់ខ្លួនរបស់ខ្ញុំ ជាមួយនឹងមជ្ឈ មណ្ឌលស្វែងរកការងារឲ្យធ្វើរបស់ទីភ្នាក់ងារជាតិមុខរបរ និង ការងារ (NEA) នៅខេត្តបាត់ដំបង ។

២. ឧបសគ្គមួយដែលខ្ញុំអាចនឹងប្រឈមនោះ គឺឪពុកម្តាយរបស់ខ្ញុំ ។ មុននឹងខ្ញុំអនុវត្តជំនាញក្នុងការចរចាររបស់ខ្ញុំ ខ្ញុំត្រូវត្រៀមខ្លួនជាស្រេច ហើយការធ្វើបែបនេះ ខ្ញុំអាចនិយាយជាមួយឪពុកម្តាយរបស់ខ្ញុំអំពីគំនិតរបស់ខ្ញុំ ព្រោះថា ឪពុកម្តាយរបស់ខ្ញុំមានគម្រោងផ្សេងពីខ្ញុំ ។

៣. សុំបំពេញនូវផែនការហិរញ្ញវត្ថុ និង ថវិកាគោល ដោយត្រូវមើលរឿងវីដេអូខ្លីៗពីកម្មវិធីក្លាហាន9 ដែលមាននិយាយអំពីគន្លឹះសម្រាប់ជាជំនួយស្មារតីក្នុងការសន្សំប្រាក់ ប្រសិនបើអ្នកចង់ចាប់ផ្តើមបើកអាជីវកម្មផ្ទាល់ខ្លួនរបស់អ្នក ។

៤. បញ្ចប់ការហាត់ហ្វឹកហ្វឺនក្នុងវិស័យបដិសណ្ឋារកិច្ចរបស់ខ្ញុំនៅមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងខេត្តបាត់ដំបង ។

### ការបញ្ចប់កម្មវិធីធ្វើលំហាត់:

សកម្មភាពភាគច្រើន រៀបរាប់អំពីការចែករំលែកនូវគោលដៅ និង ការងាររបស់ពួកគេ ។ អ្នកសម្របសម្រួល ត្រូវលើកទឹកចិត្តសិក្ខាកាមឲ្យនិយាយគ្នាអំពីផែនការសកម្មភាពរបស់ពួកគេជាមួយនឹងសិក្ខាកាម ដែលអង្គុយជិតពួកគេ មិត្តភក្តិ ឬ សមាជិកគ្រួសាររបស់ពួកគេ ។ ប្រសិនបើពួកគេចង់បាន និង ពួកគេមាន សមត្ថភាពក្នុងការធ្វើផែនការសកម្មភាពនិង គោលដៅនេះ ពួកគេអាចថត ឬ កត់ត្រាទុកក្នុងទូរស័ព្ទចល័ត របស់ពួកគេ និង ចែករំលែកវាក្នុងបណ្តាញទំនាក់ទំនងសង្គមរបស់ពួកគេ ។

### ចំណុចគន្លឹះសម្រាប់ជាជំនួយស្មារតីក្នុងការបណ្តុះបណ្តាល:

អ្នកសម្របសម្រួល ត្រូវប្រាប់ក្រុមសិក្ខាកាមឲ្យនិយាយអំពីផែនការរបស់ពួកគេជាមួយនឹងក្រុមសិក្ខាកាម ឬ ជាមួយមនុស្សទុកចិត្ត ដែលអាចជួយពួកគេបាន ។

ត្រូវប្រាកដថា អ្នកសម្របសម្រួល បញ្ចប់វគ្គបណ្តុះបណ្តាលនេះ ដោយរក្សាយបាននូវថាមពល និង ភាព សប្បាយ រីករាយ ។ អ្នកអាចចាក់ចម្រៀងស្តាប់ ឬ ថតរូបជាក្រុមទុកអនុស្សាវរីយ៍ និង បង្ហោះទុកក្នុងគេហទំព័រ ហ្វេសប៊ុក នៃកម្មវិធីក្លាហាន9 ។

## គ្រាប់អង្កាំ (ពណ៌លឿង)

នៅចុងបញ្ចប់ នៃមេរៀននេះ សុំឲ្យសិក្ខាកាមរើសយកអង្កាំពណ៌លឿង រួចដោតវាចូលក្នុងខ្សែ ។ ចូររំលឹក សិក្ខាកាមថា អង្កាំពណ៌លឿងនេះ តំណាងឲ្យផែនការសកម្មភាពរបស់ពួកគេ ដែលពួកគេនឹងធ្វើ ដើម្បីសម្រេច គោលបំណងរបស់ពួកគេ ដែលពួកគេបានកំណត់វា កាលពីមុនការចាប់ផ្តើម នៃវគ្គបណ្តុះបណ្តាលនេះ ។ ក្នុង ពេលជាមួយគ្នានេះដែរ ពួកគេក៏គិតអំពីផែនការ “ខ” ឬ ផែនការ “គ” ទៀតផង ប្រសិនបើការងារនោះ វាមិន ប្រព្រឹត្តទៅតាមអ្វីដែលពួកគេចង់បាន ។ សុំប្រាប់សិក្ខាកាមឲ្យគិតផងដែរអំពីបរាជ័យ និង ត្រូវចាត់ទុកវា ថាជា មេរៀន ដើម្បីឲ្យពួកគេអាចធ្វើអ្វីផ្សេងពីនេះ នាពេលអនាគត និង មិនប្រព្រឹត្តនូវកំហុសដដែលៗ ។ ជម្រុញឲ្យ សិក្ខាកាម សហការជាមួយអ្នកអង្គុយក្បែរខ្លួនពួកគេ ដើម្បីឲ្យជួយដោតអង្កាំចូលខ្សែ រួចជួយគ្នាទៅវិញទៅមក ក្នុងការចងខ្សែអង្កាំនោះព័ទ្ធជុំវិញកដៃរបស់ពួកគេ និង ពិគ្រោះគ្នាមើលថាតើខ្សែអង្កាំនោះមានន័យដូចម្តេច ចំពោះពួកគេ ។



នេះជាអង្កាំចុងក្រោយហើយ ដែលសិក្ខាកាមទទួលបាន ។ ឥឡូវនេះ ពួកគេគួរទទួលបានខ្សែដៃគ្រាប់អង្កាំ ដែលមានប្រាំពណ៌ផ្សេងគ្នា ។ រំលឹកសិក្ខាកាមឲ្យបានដឹងថាតើអង្កាំនីមួយៗតំណាងឲ្យអ្វី និង ពន្យល់ពួកគេថា ខ្សែដៃនេះ ជាគ្រឿងរំលឹករូបកាយឲ្យបានដឹងអំពីក្តីស្រមៃរបស់ពួកគេ និង ជំនាញ ដែលឥឡូវនេះ ពួកគេត្រូវប្រែ ក្លាយពីក្តីស្រមៃឲ្យទៅជាបានសម្រេចគោលបំណងរបស់ពួកគេទៅវិញ ។

**Website:** http://klahan9.com.kh

**Facebook:** https://www.facebook.com/klahan9cambodia

**YouTube:** https://www.youtube.com/c/klahan9Cambodia